
តម្រា
វិញ្ញាណទី ៦
ចិរញ្ញាណោ រុន វ៉ាណា

# តម្រាវញ្ញាណទី៦

{-ចិរញ្ញាណោ រុន រ៉ាណា-}

៙នមោពុទ្ធាយ សិទ្ធំ៙

# ឧបត្ថិកថាសង្ខេប

ខ្ញុំព្រះករុណាសូមនមស្សការ ព្រះរតនត្រ័យទាំង៣គឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ដោយត្បូង.។ការចងក្រងសៀវភៅនេះឡើងដោយមានបុព្វហេតុជាច្រើនរួមមានដោយសង្ខេបគឺ៖

- ដើម្បីថែរក្សាវប្បធម៌ខ្មែរបុរាណ កុំឱ្យបាត់បង់
- ដើម្បីជួយកែសម្រួលដល់បងប្អូនដែលមានគោលបំណងចង់សិក្សា ។

ខ្ញុំក៏សង្ឃឹមថា បងប្អូនអ្នកអានចូលចិត្ត ព្រោះថាខ្ញុំបានស្រាវជ្រាវ ពីគម្ពីផ្សេងៗនិងបទពិសោធន៍ផ្ទាល់ខ្លួន មកបញ្ចូលគ្នាដោយកុំឱ្យបងប្អូនពិបាកក្នុងការសិក្សា។

ព្រោះសម័យបច្ចុប្បន្ននេះ មានគ្រូបោកប្រាស់ច្រើនណាស់ ចឹងហើយបានជាខ្ញុំសំរេចចិត្តចំណាយពេលវេលា សរសេរសៀវភៅនេះឡើង ។

ថ្ងៃសុក្រ ៨កើត ខែបុស្ស ឆ្នាំខាលចត្វាស័ក ព.ស.២៥៦៦

ត្រូវនឹងថ្ងៃទី៣០ ខែធ្នូ គ.ស.២០២២

**អ្នករៀបរៀង**

ចិរញ្ញាណោ~**ទូន វ៉ាណា**

# ១/.អំពីឆ្នាំទាំង១២

## ១.ឆ្នាំជូត

( ធាតុទឹក ពង្សទេវតាប្រុស )



បុរសស្ត្រីណាកើតក្នុងឆ្នាំនេះ (នាមសត្វកណ្ដុរ ពង្សទេវតាប្រុស)
១.មានភាពក្លាហ៊ានមោះមុតពុះពារគ្រប់ឧបស័គ្គសម្រេចការងារដោយខ្លួនឯង
២.ចូលចិត្តការរាប់អាន និងឈឺឆ្អាលចំពោះរឿងអ្នកដទៃ
៣.ច្រើនតែអភ័ព្វដោយសារជួយយកអាសារគេហើយទទួលផ្ដល់អកត្តញ្ញូមកវិញ
៤.ធ្វើដំណើរទៅណា ច្រើនមានមនុស្សឆោមរោមកុះករ
៥.បើការរាជការភាគច្រើនបានបុណ្យសក្តិធំនិងមានមន្ត្រីចូលចិត្តរាប់អានច្រើន
៦.បុរសស្ត្រីដែលកើតឆ្នាំគួរតែរកស៊ីតាមជើងគោក ទើបប្រសើរ។

# ២.ឆ្នាំឆ្លូវ

(ឆ្នាំឆ្លូវជាតុជី ពង្សមនុស្សប្រុស)



បុរសស្ត្រីណាកើតក្នុងឆ្នាំឆ្លូវ (នាមសត្វគោ ពង្សមនុស្សប្រុស)

១.ភាគច្រើនជាមនុស្សអភ័ព្វគួរព្រេង,ហត់នឿយខាងដើមច្រើន លុះដល់ចុងក្រោយបានល្អគាប់ប្រសើរឡើងវិញ

២.បើរកស៊ីផ្នែកជំនួញនិងទទួលផលមធ្យម

៣.បើធ្វើការរាជការ ភាគច្រើនបានបុណ្យសក្តិល្មម

៤.ជាមនុស្សចូលចិត្តមានស្នេហា និងដើរលេងច្រើន

៥.ចូលចិត្តដើររកស៊ីឆ្ងាយ ភាគច្រើនធ្វើមុខរបរជួញដូរ

៦.បើជាបុរសឃើញស្ត្រីភាគច្រើនអួតពីកម្លាំង បើស្ត្រីអួតពីសម្រស់ខុសពីឆ្នាំដទៃទៀត๛

## ៣.ឆ្នាំខាល

(ឆ្នាំខាល ជាតុឈើ ពង្សយក្សស្រី)



បុរសស្ត្រីណាកើតក្នុងឆ្នាំខាល (នាមសត្វខ្លា ពង្សយក្សស្រី)

១.ជាមនុស្សច្រើនអភ័ព្វញាតិ

២.ជាមនុស្សដែលគេ ច្រណែននិទ្ទាច្រើន និយាយអាក្រក់ពីខ្លួនច្រើន

៣.បើមានលាភភាគច្រើនជាលាភធំ

៤.បើធ្វើការ នឹងបានមុខដំណែងធំ នឹងមានគេជួយយកអាសារ

៥.ប្រកបមុខរបររកស៊ីលក់ដូរ នឹងបានល្អប្រសើរ

៦.ភាគច្រើនជាមនុស្សមិនសូវចូលចិត្តដើរឆ្ងាយទេ

៧.មានគេឱ្យលាភជារឿយៗ

# ៤.ឆ្នាំថោះ

( ឆ្នាំថោះ ជាតុទឹក ពង្សមនុស្សស្រី )



បុរសស្រ្តីណាកើតក្នុងឆ្នាំថោះ ( នាមសត្វទន្សាយ ពង្សមនុស្សស្រី )

១.ភាគច្រើនជាមនុស្សស្លូតបូតរាប់អានញាតិមិត្តច្រើន

២.ជាមនុស្សមានប្រាជ្ញា តែភាគច្រើនខ្ជិលសិក្សា

៣.រកស៊ីតឹងតែងណាស់

៤.បើរាប់អានអ្នកធំ ភាគច្រើនអភ័ព្វខ្លួន

៥.បើរកស៊ីលក់ដូរ នឹងទទួលផលបង្គួរ បើរកស៊ីឆ្ងាយមិនសូវទទួលល្អ

៦.ជាមនុស្សមានសន្ដានចិត្តចិត្ត មិនសូវចងគំនុំគុំគួនឡើយ

៧.ចូលចិត្តផ្គប់ផ្គន់គេ បើធ្វើការរាជការ នឹងបានជាធំ

៨.ច្រើនជាមនុស្ស មានជម្ងឺច្រើន ចូលចិត្តនិយាយលេងសើចច្រើន៚

## ៥.ឆ្នាំរោង

(ឆ្នាំរោង ធាតុមាស ពង្សទេវតាប្រុស)



បុរសស្ត្រីណាកើតក្នុងឆ្នាំរោង (នាមសត្វនាគ ពង្សទេវតាប្រុស)

១.ភាគច្រើនជាមនុស្សឫទ្ធិអំណាចខ្ពស់ ជាមនុស្សមានរាសីខ្ពស់

២.មានវោហាស័ព្ទច្រើន អ្នកផងគោរពរាប់អាន

៣.ជាមនុស្សឆាប់ខឹង តែឆាប់រសាយកំហឹង មិនចងគំនុំ

៤.បើរកស៊ីជួញដូរ មិនសូវល្អទេ

៥.បើធ្វើការរាជការរមែងបានជាធំ

៦.ចូលចិត្តដើរឆ្ងាយ លុះចាស់ជរាច្រើនមានលាភចូល

៧.ជាមនុស្សអភ័ព្វពីដំបូង លុះចុងក្រោយទើបប្រសើរវិញ

# ៦.ឆ្នាំម្សាញ់

( ឆ្នាំម្សាញ់ ធាតុភ្លើង ពង្សមនុស្សប្រុស )



បុរសស្ត្រីណាកើតក្នុងឆ្នាំម្សាញ់ ( នាមសត្វពស់ ពង្សមនុស្សប្រុស )

១.ភាគច្រើនជាមនុស្សជួយយកអាសារគេ ចូលចិត្តនិយាយចរចារ ច្រើនតែអត់ប្រយោជន៍

២.ធ្វើការច្រើនខ្ជីខ្ជារ ជាមនុស្សមិនចូលចិត្តការរាប់អានច្រើន

៣.តែបើរាប់អានគឺសម្លឹងមើលតែផលប្រយោជន៍ អ្វីមួយពីបុគ្គលនោះ

៤.បើសេពជាមួយអ្នកធំ នឹងបានផលមធ្យម

៥.ធ្វើការរាជការមិនសូវល្អទេ

៦.ទ្រព្យសម្បត្តិល្អមធ្យម តែចិត្តកំណាញ់បន្តិច តែមុននិងឱ្យត្អូញត្អែរជាមុនសិន

## ៧.ឆ្នាំមមី

(ឆ្នាំមមី ជាតុភ្លើង ពង្សទេវតាប្រុស)



បុរសស្ត្រីណាកើតក្នុងឆ្នាំមមី (នាមសត្វសេះ ពង្សទេវតាប្រុស[១])

១.ជាមនុស្សចូលចិត្តនៅស្ងប់ស្ងាត់ច្រើន តែចូលចិត្តលេងច្រើន

២.មានភាពស្មោះត្រង់ ក្លាហាន

៣.ជាមនុស្សនិយាយច្រើនរឿងការងារ តែមិនខ្ជិលទេ

៤.អ្នកផងស្រឡាញ់រាប់អានច្រើន មានលាភជារឿយៗ

៥.បើធ្វើការរាជការ នឹងបានជាធំ រកស៊ីល្អបង្គួរ ដើតឆ្ងាយមិនសូវល្អឡើយ

៦.ជាមនុស្សហត់នឿយច្រើន ភាគច្រើនសូវចង់បានរបស់គេទេ៚

១-បើតាមក្បួនពិភេក្សហោរា ពង្សទេវតាស្រី បើតាមក្បួនបុរាណគឺទេវតាប្រុស

# ៨.ឆ្នាំមមែ

(ឆ្នាំមមែ ធាតុមាស ពង្សទេវតាស្រី)



បុរសស្ត្រីណាកើតក្នុងឆ្នាំមមែ (នាមសត្វពពែ ពង្សទេវតាស្រី)

១.ជាមនុស្សមានចិត្តក្លាហានមុះមុត

២.ធ្វើដំណើរទៅណាមកណា ច្រើនមានគេស្រលាញ់រាប់អានច្រើន

៣.លាភសក្ការៈ ភាគច្រើនមានមនុស្សនាំយកមកឱ្យ

៤.បើធ្វើការច្រើនបានធំ បើមានទុក្ខទោសនឹងអ្នកជួយយកអាសារ

៥.ជាមនុស្សអាស្រ័យល្អចំពោះអ្នកដទៃ

៦.តែត្រង់សម្ដីគួរតែកុំនិយាយពាក្យឥតប្រយោជន៍ច្រើនពេក អាចមានទុក្ខទោសដល់ខ្លួន៚

## ៩.ឆ្នាំវក

(ឆ្នាំវក ធាតុដែក ពង្សយក្សប្រុស)



បុរសស្ត្រីណាកើតក្នុងឆ្នាំវក (នាមសត្វស្វា ពង្សយក្សប្រុស)

១.ជាមនុស្សមានគេរាប់អានច្រើន លាភសក្ការៈច្រើនបានមកពីគ្រូទ្ធាចារ្យ

២.ជាមនុស្សបានវោហាស័ព្ទច្រើន

៣.ចូលលេងសើចញ៉េះញ៉ោះច្រើនឥតប្រយោជន៍ ប៉ុន្តែឧស្សាហ៍

៤.លំបាកពីដំបូង លុះចុងក្រោយទើបល្អប្រសើរ

៥.បើរាប់អានអ្នកធំ និងបានផលល្អបង្គួរ

៦.បើរកស៊ីជួញដូរ ល្អប្រសើរណាស់៚

## ១០.ឆ្នាំរកា

(ឆ្នាំរកា ជាតុដែក ពង្សយក្សប្រុស)



បុរសស្ត្រីណាកើតក្នុងឆ្នាំរកា (នាមសត្វមាន់ ពង្សយក្សប្រុស)

១.ជាមនុស្សមានភាពក្លាហានមុះមុត តែឆេវឆាវបន្តិច

២.ជាមនុស្សស្មោះត្រង់ មានប្រាជ្ញា អាចសម្រេចកិច្ចការទាំងពួងបានយ៉ាងប្រសើរ តែឆាប់ចាញ់បោកពាក្យលួងលោម

៣.ច្រើនមានមនុស្សដទៃច្រណែន និយាយអាក្រក់ពីខ្លួន

៤.លាភសក្ការៈភាគច្រើនមានចាស់ព្រឹទ្ធាចារ្យនាំយកមកឱ្យ

៥.បើធ្វើការរដ្ឋឬសេពគប់អ្នកធំ នឹងទទួលផលល្អបង្គួរ

៦.បើប្រកបមុខរបរលក់ដូរនឹងបានផលល្អប្រសើរ៚

# ១១.ឆ្នាំច

( ឆ្នាំច ធាតុដី ពង្សយក្សស្រី )



បុរសស្ត្រីណាកើតក្នុងឆ្នាំច ( នាមសត្វឆ្កែ ពង្សយក្សស្រី )

១.ជាមនុស្សក្លាហាន ស្មោះត្រង់ ស្លូតបូតតាមមនុស្ស

២.ជាមនុស្សដែលគេរាប់អានច្រើន ចូលចិត្តច្រើន មានគេជួយច្រើន

៣.តែលាភសក្ការៈ បានដោយក្រលំបាកជាខ្លាំង

៤.បើសេពគប់អ្នកធំ មន្ត្រីនាហ្មឺន នឹងបានល្អដោយមានស្រីជួយផ្គូចផ្តើម

៥.បើធ្វើការរដ្ឋមិនសូវល្អទេ តែបើរកស៊ីលក់ដូរ បានផលល្អណាស់

៦.ជាមនុស្សនិយាយច្រើនៗតែមិនសូវធ្វើ

៧.ជាមនុស្សឆាប់ខឹង តែមិនចងគំនុំទេ៚

# ១២.ឆ្នាំកុរ

( ឆ្នាំកា ជាតុទឹក ពង្សមនុស្សស្រី )



បុរសស្ត្រីណាកើតក្នុងឆ្នាំច ( នាមសត្វឆ្កែ ពង្សយក្សស្រី )

១.ជាមនុស្សខ្ជិលច្រអូសបន្តិច តែព្យាយាម និងស្មោះត្រង់តែឆាប់ខឹង

២.បើមានភ័យអាសន្ននឹងមានគេជួយយកអាសារ

៣.ជាមនុស្សដែលមានគេរាប់អានចូលចិត្តច្រើន

៤.បើជាមនុស្សប្រុស ច្រើនបានលាភពីមនុស្សស្រីផ្តល់ឱ្យខ្លួន

៥.បើធ្វើការច្រើនមានធ្វើធំ នឹងមានឈ្មោះល្បីល្បាញ៕

១/តើការទស្សទាយរបស់ខ្ញុំយ៉ាងណាដែរ ចូលផ្តល់មតិខាងក្រោម

| |
|---|
| |
| |
| |
| |
| |
| |
| |
| |
| |
| |
| |
| |
| |
| |
| អរគុណសម្រាប់មតិ |

## ២/.អំពីថ្ងៃកំណើត(ទេពនិករ)

## ១.ថ្ងៃអាទិត្យ (រវិវារ)

## (បាបគ្រោះ)



បុរសស្ត្រីណា កើតត្រូវនឹងថ្ងៃអាទិត្យ (ទេពនិករមានភាពឆេវឆាវ)

១.ជាមនុស្សមានភ័ព្វសំណាងល្អ បើមានទុក្ខទោសអ្វីតែងមានអ្នកជួយ

២.ជាមនុស្សមិនសូវលោភលន់រឿងលាភសក្ការៈច្រើន

៣.មានចិត្តស្រលាញ់រាប់អានបងប្អូន មានបញ្ញាឈ្លាសវៃ និងមុះមុត

៤.ធ្វើការច្រើន បើមិនហើយមិនឈប់ មិនគិតពេលវេលា

៥.ចូលស្ងប់ស្ងាត់ច្រើនជាងរញ៉េរញ៉ៃ

៦.ជាអ្នកមានវោហាស័ព្ទច្រើនគួរសណ្តាប់

៧.វាសនាបុណ្យសក្តិ កើតឡើងពីការប្រឹងរបស់ខ្លួន

៨.ជាមនុស្សសម្បូរ ញាតិមិត្ត ច្រើន៚

(គួរប្រើសម្លៀកបំពាក់ពណ៌ក្រហមទើបសមគួរ)

## ២.ថ្ងៃចន្ទ (សោមវារ)

## (សុភគ្រោះ)



បុរសស្ត្រីណា កើតត្រូវនឹងថ្ងៃចន្ទ (ទេពនិករមានភាពទន់ភ្លន់)

១.ជាមនុស្សមានភាពទន់ភ្លន់ តែមិនច្បាស់លាស់ អាចមានកិច្ចកល

២.បើមានមិត្តភក្តិ ច្រើនបានល្អតែដំបូង លុះចុងក្រោយសោះអង្គើយដាក់គ្នា

៣.ជាមនុស្សជួយយកអាសារ តែមិនបានសម្រេចនាំឱ្យមានទុក្ខទោសដល់ខ្លួន

៤.លាភសក្ការៈបានមក តែមិនស្ថិតស្ថេរគង់វង់ទេ

៥.ជាមនុស្សមានថ្វីមាត់ច្រើន និយាយអ្វីច្រើនមានគេយកចិត្តទុកដាក់ស្តាប់

(គួរប្រើសម្លៀកបំពាក់ពណ៌លឿងទើបសមគួរ)

# ៣.ថ្ងៃអង្គារ (មង្គលវារ)
## (បាបគ្រោះ)



បុរសស្ត្រីណា កើតត្រូវនឹងថ្ងៃអង្គារ (ទេពនិករមានភាពឆេវឆាវ)

១.ជាមនុស្សមានចិត្តឆេវឆាវខ្លាំង ជាមនុស្សចូលចិត្តប្រើកម្លាំង (តាមមនុស្ស)

២.លាភសក្ការៈរកបាន ដោយការខំប្រឹងប្រែងដោយខ្លួនឯង អាចរក្សាទ្រព្យបាន

៣.ជាមនុស្សវាចាស្រទន់ ជាទីស្រលាញ់នៃអ្នកផងទាំងឡាយ

៤.តែបើពឹងពាក់ផ្អាក់អាស្រ័យអ្នកទាំងឡាយច្រើនមិនបានផល

(គួរប្រើសម្លៀកបំពាក់ពណ៌ក្រហមដាំទើបសមគួរ)

**៤.ថ្ងៃពុធ (ពុធវារ)**

**(សុភគ្រោះ)**



បុរសស្ត្រីណា កើតត្រូវនឹងថ្ងៃពុធ (ទេពនិករមានភាពសុភាពរាបសារ)

១.ជាមនុស្សមានគំនិតគិតវែងឆ្ងាយ សន្សំសំចៃ

២.ជាមនុស្សសល់ទ្រព្យសម្បត្តិច្រើន

៣.បើសេពគប់មិត្តច្រើនមិនសូវសមប្រកបឡើយ មានគេច្រណែនច្រើន

៤.ជាមនុស្សមើលស្រាល ការងារ បុគ្គលជំពូកនេះ ធ្វើគុណដល់ហើយរមែងបានទោសមកវិញ

៥.ជាមនុស្សមានបញ្ញាច្រើន ចូលចិត្តនិយាយចរចារ

(គួរប្រើសម្លៀកបំពាក់ពណ៌ស្លឹកឈើចាស់ទើបសមគួរ)

# ៥.ថ្ងៃព្រហស្បតិ៍ (គុរុវារ)
## (សុភគ្រោះ)



បុរសស្ត្រីណា កើតត្រូវនឹងថ្ងៃព្រហស្បតិ៍ ( ទេពនិករមានភាពស្ងប់ស្ងាត់ )

១.ជាមនុស្សមានបញ្ញា ភាពជាអ្នកដឹងនាំ រមែងជាអ្នកធំ

២.ជាមនុស្សប្រាជ្ញា ជាមនុស្សសំដីតិច

៣.មិនសូវចូលចិត្តនិយាយចរចារពាក្យឥតប្រយោជន៍ទេ

៤.មានចិត្តពុះពារគ្រប់ឧបស័គ្គ

៥.តែភាគច្រើនចូលចិត្តល្បែងភ្នាល់ផ្សេងៗ

( គួរប្រើសម្លៀកបំពាក់ពណ៌ស្លាទុំទើបសមគួរ )

## ៦.ថ្ងៃសុក្រ (សុក្រវារ)
## (សុតគ្រោះ)



បុរសស្ត្រីណា កើតត្រូវនឹងថ្ងៃសុក្រ (ទេពនិករមានភាពផ្អែមផ្អែម)
១.ជាមនុស្សមានកិរិយាមាយាទគួរឱ្យរាប់អានចូលចិត្ត
២.ជាមនុស្សមានលាភជារឿយៗ
៣.កាលនៅតូចជាមនុស្សអភ័ព្វញាតិ តែលុះធំជាមនុស្សសម្បូរលាភ
៤.ជាមនុស្សប្រកាន់ពាក្យសំដីដែលខ្លួននិយាយ
៥.បើជាមនុស្សប្រុស ច្រើនធ្វើឱ្យស្រីៗ ចូលចិត្តស្រឡាញ់

(គួរប្រើសម្លៀកបំពាក់ពណ៌ត្រាវ ឬពណ៌ស ទើបសមគួរ)

# ៧.ថ្ងៃសៅរ៍ (សនិវារ)

## (បាបគ្រោះ)



បុរសស្ត្រីណា កើតត្រូវនឹងថ្ងៃសៅរ៍ ( ទេពនិករមានភាពឆេវឆាវខ្លាំង )

១.ជាមនុស្សមានចិត្តឆេវឆាវ ហ៊ានស៊ីហ៊ានសង

២.ជាមនុស្សមានចិត្តកំណាញ់ តែចេះយកចិត្តគាប់គួរ ចំពោះញាតិ

៣.ធ្វើការអ្វីច្រើនខ្ជីរខ្ជារ

៤.បើសេពគប់មិត្តភក្តិ ច្រើនមានទុក្ខទោសដល់ខ្លួន

៥.ជាមនុស្សទុកចិត្តជាងាយ

៦.ច្រើនតមទាស់ តមមាត់ជាមួយបងប្អូនឯង

( គួរប្រើសម្លៀកបំពាក់ពណ៌ស្វាយ ទើបសមគួរ )

# តើការទស្សន៍ទាយរបស់ខ្ញុំយ៉ាងណាដែរ

| |
|---|
| |
| |
| |
| |
| |
| |
| |
| |
| |
| |
| |
| |
| |
| |
| |
| អរគុណចំពោះមតិ |

# ក្បួនយាត្រា

| យប់,ព្រឹក | ពេញពន្លឺ | ថ្ងៃត្រង់ | រសៀល | ល្ងាច | យប់ |
|---|---|---|---|---|---|
| អាទិត្យ | ៤ | + | ន | ២ | ១ |
| ចន្ទ | ១ | ៤ | + | ន | ២ |
| អង្គារ | ២ | ១ | ៤ | + | ន |
| ពុធ | ន | ២ | ១ | ៤ | + |
| ព្រហ. | + | ន | ២ | ១ | ៤ |
| សុក្រ | ៤ | + | ន | ២ | ១ |
| សៅរ៍ | ១ | ៤ | + | ន | ២ |

១.ក្បួនក្រឡានេះ គឺជាក្បួនមួយប្រភេទដែលមានតាំងតែពីបុរាណមកម្លេះ ដោយពួកគាត់ប្រើវាសម្រាប់ធ្វើដំណើរទៅណាមកណាថា តើបានសុខឬទុក្ខ ខាងក្រោមនេះជារបៀបនៃការមើលក្បួនខាងលើ៖

គួរសំគាល់ត្រង់ចំណុចខាងលើគឺបែងចែកជា២គឺ ល្អនិងអាក្រក់ (ក្នុង១ថ្ងៃរាប់ពីព្រឹកដល់យប់មានអាក្រក់២ពេល និងល្អ៣ពេល .។

- លេខ៤ លេខ+ លេខ២ ជាក្រុមខាងល្អ ធ្វើដំណើរមានលាភ និងបានសុខ
- លេខ១ និងអក្សរ ន ជាក្រុមអាក្រក់

ឧទាហរណ៍ថា បងប្អូនចង់ចេញដំណើរថ្ងៃអាទិត្យ គឺរាប់បណ្តោយតាមលំដាប់ថ្ងៃអាទិត្យ ឱ្យត្រូវវេលាល្អ (ពេញពន្លឺជាដើម)

# ក្បួនទាយរបស់ដែលបាត់

❖ ខាងក្រោមនេះ ជាអក្សរសម្រាប់ទាយ ចូលបងប្អូនឱ្យម្ចាស់ដែលបាត់របស់នោះលុបត្រង់អក្សរណាមួយ សឹមបងប្អូនទាយតាមអត្ថន័យអក្សរនោះចុះ។

| | |
|---|---|
| **អ** | **ម** |
| **ស** | **ហ** |

៙ ការទាយតាមអត្ថន័យអក្សរដែលបានលុបនោះ៖

១/.បើលុបត្រូវអក្សរ **អ** មានន័យថា របស់ដែលបាត់នោះនឹងមិនអាចរកឃើញវិញឡើយ៙៚

២/.បើលុបត្រូវអក្សរ **ម** មានន័យថា របស់ដែលបាត់នោះនឹងលេចលឺដំណឹងដែលមិនបានរបស់នោះមកវិញទេ៙៚

៣/.បើលុបត្រូវអក្សរ **ស** មានន័យថា របស់ដែលបាត់នោះនឹងរកឃើញវិញភ្លាម៙៚

៤/.បើលុបត្រូវអក្សរ **ហ** មានន័យថា របស់នោះអាចរកឃើញដោយពិបាក និងចំណាយពេលយូរ៙៚

( កុំប្រើដោយមិនមានការសំខាន់ឬសាកល្បងលេង )

# ក្បួនចេកមាស

❖ បើតាមក្បួនបុរាណចឹងលោកដាក់ជារូបដើមចេកទេ តែដើម្បីឱ្យបងប្អូនងាយសិក្សា ងាយយល់ចឹងហើយបានជាខ្ញុំដាក់រូបបាត់ដៃ និងតំណាងឱ្យដើមចេកតែម្តងទៅ




❖ បុរាណលោកនិយមប្រើក្បួននេះសម្រាប់មើលគួរស្រករតើល្អឬអាក្រក់ប៉ុន្តែខ្ញុំវិញគឺប្រើខុសពីលោក មិនមែនខ្ញុំចេះតែកែប្រែទេ តែបានសិក្សាអំពីសំណាក់គ្រូបាអាចារ្យមកដែរ៖

❖ ឧទាហរណ៍៖លេខ១គល់ចេក លេខ២ជាងបាក់ លេខ៣ស្តេច លេខ៤មន្ត្រី លេខ៥សេដ្ឋី លេខ៦អ្នកមាន លេខ៧អ្នកក្រ លេខ៨ទូកលិច ជាដើម។

❖ បើមនុស្សប្រុសលោកឱ្យរាប់ពីលេខ១ទៅលេខ២រហូតគ្រប់អាយុរបស់ខ្លួន( ១ដល់៨,១ជុំស្មើអាយុ៨ឆ្នាំ ជុំទី២ត្រូវរាប់លេខ១ជាលេខ៩រហូតដល់លេខ៨( ១៦ )នោះមានន័យថាអ្នកបានរាប់ដល់អាយុ១៦ឆ្នាំហើយ។

○ **អត្ថន័យមានដូចខាងក្រោម៖**

១/.លេខ១ បើមានជម្ងឺ នឹងជាវិញ ប៉ុន្តែត្រូវចំណាយពេលយូរ៚

២/.លេខ២ វិនាស ហិនហោច ក្តៅក្រហាយ បើមានជម្ងឺត្រូវព្យាបាលជាប្រញាប់

៣/.លេខ៣ ស្តេច មានន័យថា នឹងគេជួយទំនុបបំរុង មានអំណាច តែត្រូវប្រយ័ត្នចំពោះទង្វើរផង

៤/.លេខ៤ មន្ត្រី មានន័យថា នឹងមានអ្នកធំកំពុងជួយយកអាសារអ្នក តែកុំលោភលន់

៥/.លេខ៥ សេដ្ឋី មានន័យថា នឹងរកស៊ីលក់ដូរ ចំណេញច្រើន សុខចម្រើន តែប្រយ័ត្នចោះមិត្តភ័ក្តមួយចំនួន

៦/.លេខ៦ អ្នកមាន មានន័យថា អ្នកទទួលបានលាភជារឿយៗ តែប្រយ័ត្នសម្តី

៧/.លេខ៧ អ្នកក្រ មានន័យថា អ្នកនឹងអាចជួបរឿងលំបាកមួយរយៈ

៨/.លេខ៨ ទូលលិច រកស៊ីច្រើនតែខាតបង់ ឬអ្នកកំពុងកើតទុក្ខរឿងរកស៊ីបើមាន

ជម្ងឺច្រើនឈឺធ្ងន់ធ្ងរ តែអាចជាសះស្បើយវិញ៙៚

❖ក្បួនខាងលើនេះខ្ញុំបានប្រើវាអស់រយៈពេល៤ឆ្នាំមកហើយ ខ្ញុំសង្កេតឃើញថា ពិតជាមានអនុភាពមែន ដោយយើងអាចដឹងគ្រោះល្អអាក្រក់មុនជាពិសេសយើងអាចមើលវាបានចំពោះអ្នកចង់សិក្សាមន្តវិជ្ជាការ តើអាយុប៉ុន្មានដែលសិក្សាទៅមានអនុភាព ពេលណាមិនមានអានុភាព៙៚

## **ជោគតាតាំង១២ឆ្នាំ(គ្រោះល្អឬអាក្រក់)**

នេះជាគំរូតារាងដួងជតាទាំង១២ឆ្នាំ




ស្រីរាប់ពីចេតិយទៅឆ័ត្រប្រាក់ **ផ្ទុយគ្នា** ប្រុសរាប់ចេតិយទៅនាគរាជ

❖ចូររាប់អាយុរបស់អ្នកតើឆ្នាំនេះអ្នកស្ថិតនៅអាយុប៉ុន្មានហើយ រួចសឹមរាប់ដួងជតាខាងលើឱ្យគ្រប់អាយុបច្ចុប្បន្ន ឧទាហរណ៍ថា អ្នកអាយុ១២ឆ្នាំ ចឹងបើជាមនុស្សប្រុសគឺត្រូវត្រង់នឹងឆ័ត្រប្រាក់ហើយ បើស្រីអាយុ១៣ឆ្នាំ នឹងរាប់ដល់ត្រឹមចេតិយហើយ ចូរអានអត្ថន័យខាងក្រោម៖

១.**ចេតិយ** ទំនាយថា៖ និងមានភ័ព្វសំណាង មានលាភចូលជារឿយហើយមួយទៀត អ្នកផងស្រលាញ់ចូលចិត្តច្រើន បើមានក្ដីជាប់ខ្លួនរមែងឈ្នះ។

២.**នាគរាជ និងរាហ៊ូ** ទំនាយថា៖ មិនល្អទេ មានជម្ងឺដង្កាត់ច្រើន កំពុងមានសត្រូវកំពុងប៉ុនបង់ធ្វើបាបអ្នក អ្នកជិតខាងនិយាយចាក់រុកអ្នកពីមាត់មួយទៅមាត់មួយ។

៣.**មេមត់** ទំនាយថា៖ នឹងមានគេនាំលាភយកមកឱ្យជារឿយ ហើយមានគេចូលចិត្តស្រឡាញ់ច្រើន.។

៤.**ពិម្ពិសារ** ទំនាយថា៖ នឹងមានរឿងធំ មានទុក្ខទោសដល់ខ្លួនគួរតែប្រយ័ត្ន.។

៥.**ពេន្ធ្យប្លា** ទំនាយថា៖ ល្អណាស់ហោង បើគិតកិច្ចអ្វីច្រើនបានសម្រេចដូចបំណង.។

៦.**ទេវតាចរ** ទំនាយ៖ នឹងត្រូវធ្វើដំណើរ ល្អ អាក្រក់ លាភឥតលាភ ល្អល្មមគួរសម.។

៧.**ឆត្រ័មាស** និង**ឆត្រ័ប្រាក់** ទំនាយថា៖ ល្អណាស់ និងមានអ្នកធំគាប់ចិត្ត បើរកស៊ីច្រើនចំណេញធំ ហើយមួយទៀតនឹងមានមនុស្សចំលែកនាំលាភមកឱ្យ.។

៨.**ផ្ទះប្លួន** និង**ប្រសាទមាស** ទំនាយថា៖ ល្អណាស់ វត្ថុបំណងដែលប៉ុនប៉ងចង់បាននោះ នឹងបានសម្រេច រកស៊ីលក់ដូរល្អគាប់ប្រសើរ.។

៩.**មនុស្សកំបុតក្បាល** ទំនាយថា៖អាក្រក់ណាស់ ចូរកុំតតាំងជាមួយអ្នកមានល្បិច ឬអ្នកមានអំណាច ប្រយ័ត្នមានទុក្ខទោសដល់ខ្លួន ឬមានគ្រោះអាសន្នអ្វីមួយកើតឡើងគួរប្រយ័ត្ន បើរកស៊ីច្រើនតែខាតបង់ខ្លាំង ។

❖ក្បួនខាងលើនេះខ្ញុំបានសិក្សាវាតាំងពីនៅកុមារ ហើយបានប្រើវារហូតមក វាពិតជាមានអានុភាពពិតមែន យ៉ាងដូចថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២២នេះចឹង.។សូមមិនបញ្ចេញទេ

# អំពីឆ្នាំដែលត្រូវសិក្សាមន្តអាគម

គ្រង់ចំណុចនេះបងប្អូនអ្នកអានច្បាស់ជាឆ្ងល់ហើយថា តើការសិក្សាមន្តអាគមចាំបាច់ត្រូវកំណត់ឆ្នាំដែរមែនទេ ចម្លើយនោះគឺ វាពិតមែនហើយ គឺចាំបាច់ណាស់ ............

ក៏ប៉ុន្តែមិនមែនរៀនមិនបានទេ គឺរៀនបាន ហើយការរៀនបាននោះទៀតសោតគឺបានត្រឹមការពារខ្លួនឯង និងអាចជួយសង្គ្រោះអ្នកដទៃបានដែរ (ត្រឹមជម្ងឺធម្មតាបាន) .....។

- សម្រាប់ឆ្នាំដែលត្រូវសិក្សាមន្តវិជ្ជាការ ឱ្យខ្លាំងពូកែអាចបង្ក្រាប់ពពួកផ្លូវងងឹតបាននោះ រួមមាន៖

១.ឆ្នាំ **ឆ្លូវ** នាមសត្វគោ ពង្សមនុស្សប្រុស អាចសិក្សាបាន

២.ឆ្នាំ **ខាល** នាមសត្វខ្លា ពង្សយក្សស្រី អាចសិក្សាបាន

៣.ឆ្នាំ **រោង** នាមសត្វនាគ ពង្សទេវតាប្រុស អាចសិក្សាបាន

៤.ឆ្នាំ **ម្សាញ់** នាមសត្វពស់ ពង្សមនុស្សប្រុស អាចសិក្សាបាន

៥.ឆ្នាំ **មមី** នាមសត្វសេះ ពង្សទេវតាប្រុស អាចសិក្សាបាន

៦.ឆ្នាំ **មមែ** ចំពោះឆ្នាំនេះ អាចសិក្សាបាន តែត្រូវការប្រតិបត្តិច្រើន ជាពិសេសការបរិកម្មដង្ហើម និងមានសតិ .។

- ចំពោះឆ្នាំដទៃទៀត ក៏អាចសិក្សាបានដូចគ្នាដែរ តែឆ្នាំទាំងនោះជាប្រភេទសត្វដង្ហើមខ្លី ចឹងការសិក្សា បានត្រឹមជាអាវុធការពារខ្លួនប៉ុណ្ណោះ ពិបាកក្នុងការជួយការពារអ្នកដទៃណាស់ តែកុំទាន់អន់ចិត្តអី មានវិធីទេតើ បងប្អូនអាចរៀនជាក្រុមបាន ចាប់ពី៣-៤នាក់ឡើង ហើយមុននឹងរៀនជាមួយគ្នា (ក៏ត្រូវជាមនុស្សដែលដឹងចិត្តថ្លើមគ្នា ចេះជួយក្នុងណាទាំងអស់ មិនថាមានឬក្រ) ហេតុអីបានជាត្រូវរកមនុស្សបែបនិងមកសិក្សាជាមួយ ចម្លើយដែលត្រូវឆ្លើយនោះខ្លីទេគឺ ចង្កឹះមួយដើមគេងាយកាច់បំបាក់ណាស់ មួយទៀតបើមានសិស្សរួមគ្រូណាឈឺ ដោយត្រូវសីល្ប៍ខ្មៅរបស់គេ ត្រូវឱ្យគ្រូឬសិស្សរួមគ្រូមើល ទើបអាចជាសះស្បើយ . តម្រូការដែលឱ្យសិក្សាជាមួយមនុស្សដឹងចិត្តគ្នានោះគឺ មានចិត្តជួយដោយមិនគិតថាបើអត់វាប្រហែលជាអញ់បានប្រមូលលាភម្នាក់ឯងហើយ.។យល់

- ចំពោះអ្នកដែលមានឆ្នាំ ដែលអាចសិក្សាបាននោះក៏ដូចគ្នាដែរ អ្នកប្រកាន់ពាក្យថា ភ្នំខ្ពស់មានដើមឈើដុះពីលើ ថាដើមឈើទៅវាដុះលើភ្នំនៅហើយ ចុះសត្វចាបនោះវិញ។

- **ចំពោះការសិក្សាមន្តអាគម តម្រូការនោះរួមមាន៖**

១.ជាមនុស្សស្មោះត្រង់ មានស្មារតី និងគោលជំហរច្បាស់លាស់

២.សិក្សាមន្តវិជ្ជាការ ដោយសប្បាយចិត្ត[១] និងទំនុកចិត្ត

៣.ការដឹងគុណ គោរពគុណចំពោះអ្នកដែលបានបង្រៀនអ្នក

៤.មិនមែនជាមនុស្សប្រព្រឹតល្បែងអបាយមុខ និងក្បត់ជាតិ

៥.ជាមនុស្សមានសេចក្ដីសន្ដោស ចំពោះជីវិតសព្វសត្វ

៦.ជាមនុស្សមិនអួតអាង មិនវង្វេងក្នុងកាម

៧.ជាមនុស្សមិនចងបានរបស់គេ គេឱ្យប៉ុន្មានយកប៉ុណ្ណឹង

៨.ជាមនុស្សមានសេចក្ដីស្រលាញ់ គោរពចំពោះមាតា បិតា ភរិយាខ្លួន មិនប្រមាថភរិយាគេ .។

បើបងប្អូនអាចធ្វើបានចាំសិក្សា ជៀសវៀងប្រើគាថាមិនបានផល

១.សិក្សាដោយមិនមានគំនិតបៀតបៀនអ្នកដទៃ

# អំពីអាការៈអ្នកមានតួអង្គស្នងរូប

❖ចំពោះជំនឿមួយនេះវាបានជះឥទ្ធិពលទាំងតែពីបុរាណមកម្លេះ ប៉ុន្តែខ្ញុំអាចប្រាប់បងប្អូនបានខ្លះៗដែរអំពីអាការៈ លក្ខណៈ និងភាសាអ្នកមានតួអង្គ

❖បើបងប្អូនបើកចិត្តក្នុងការអានសៀវភៅមួយក្បាល ខ្ញុំសង្ឃឹមថា បងប្អូនអាចវិភាគមនុស្សដែលមានតួអង្គមកស្នងបាន ទាំងមិនទាំងអស់នោះ.។

❖ជាទូទៅមនុស្សដែលត្រូវជ្រើសរើសមកបន្តវេន ភាគច្រើនគឺអស់លោកទាំងនោះរមែងបីបាច់ថែរក្សាតាំងពីក្នុងផ្ទៃមកម្លេះ មនុស្សមួយចំពួក ទោះបីជាជួបរឿងអ្វី ក៏ត្រូវបានអ្វីមួយមកជួយរារាំងមិនខានឡើយ តែបងប្អូនមិនដឹង។

❖ចំពោះអាការៈរួមមានដូចជា៖

១.ឈឺ មិនដឹងមូលហេតុ ឈឺរាប់ឆ្នាំ ទៅពេទ្យរហូតតែពេទ្យថាមិនឈឺអី

២.ខុសប្លែកពីអ្នកដទៃ ត្រង់ចំណុចនេះ មនុស្សដែលមានស្នង ភាគច្រើនជាមនុស្សដែលស្ងៀមស្ងាត់(តាមមនុស្ស)

៣.មានអាការៈ ព្រឺសម្បុរ ពេលមានហេតុការណ៍អ្វីមួយ

៤.ពេលទៅបុណ្យសព អាចមានអារម្មណ៍ថា មនុស្សដែលស្លាប់បានហៅ

៥.ជាមនុស្ស មិនអាត្មានិយមចេះជួយគេ ។ល។

❖តើបងប្អូនមានអាការៈដូចម្តេចដែរ ?

ចំពោះចំណុចទី១ បើឈឺរហូតទៅពេទ្យហើយមិនជា មានអារម្មណ៍ថាអស់កម្លាំង.។ រំលងបាន២-៣ឆ្នាំ ឈឺកាន់តែខ្លាំង ពីមុនឈឺដែរតែអាចដេកលក់បាន តែដល់ឈឺបាន២-៣ឆ្នាំ ស្រាប់តែដេកមិនលក់ កើយក្នើយដូចកើយលើថ្ម ដណ្តប់ភួយដូចដេកក្នុងទឹក និយាយម្នាក់ឯង និយាយភាសាផ្សេង ថ្ងៃខ្លះមិនអាចគ្រប់គ្រងខ្លួនឯងបាន ចិត្តចង់តែនិយាយ ។ល។ ចំណុចនេះ បងប្អូនគួរតែទៅរកគ្រូខ្មែរ ខាងហោរា ឬអ្នកស្នង តែជាមនុស្សដែលយើងទុកចិត្តផង (ភ្នំមួយមិនអាចមានខ្លា២ទេ ចំពោះមនុស្ស១ចំនួន)គួរតែប្រយ័ត្ន.។

# អំពីការបើកតួអង្គ(បើកញាណ)

❖ត្រង់ចំណុចខ្ញុំសូមបញ្ជាក់បន្តិចថា៖ការបើកតួអង្គ នោះមិនស្រួលនោះទេ កាលបើយើងបើកហើយត្រូវបដិបត្តិ ត្រូវរៀបចំអាសនៈ ត្រូវធ្វើខ្លួនជាមនុស្សថ្មី ត្រូវសម្របតាម វិញ្ញាណដែលលោកមកនៅក្នុងខ្លួនយើង.។

❖តួអង្គឬស្នងរូបខ្លះ អាចនិយាយជាភាសាខ្មែរ ឬបាលី ខ្ញុំគិតថាល្អណាស់ ព្រោះមនុស្សឥឡូវនេះមិនសូវជឿរឿងអស់និងទេ គេអាចថាយើងឆ្កួតបាន ខ្ញុំសូមជូនពាក្យដល់បងប្អូន អ្នកណានិយាយអីនិយាយទៅ សំខាន់យើងដឹងខ្លួនឯងច្បាស់ សំខាន់យើងមិនបានបៀតបៀនអ្នកណាឡើយ សុំតែសុខ ។

❖ចូលមករឿងយើងវិញ នៅពេលដែលយើងរៀបចំពិធីបើកតួអង្គនោះ និងមានបាតុភូតចំលែកកើតឡើង នៅពេលរៀបចំពិធី៖ យ៉ាងដូចជា ភ្លៀងខុសធម្មតា ផ្គររន្ទះ ផ្គរលាន់គ្រហឹមពេញមេឃ ឬពពកខ្មៅជាដើម (ទៅតាមកម្លាំងតួអង្គរបស់យើង)

❖គាថា ដែលគ្រូអ្នកទទួលភារៈជាអ្នកបើកកាយ ថ្វាយខ្លួនរបស់យើងដល់តួអង្គឱ្យចូលមកនៅរួមតែមួយនោះគឺ គេឱ្យយើងទន្ទេញបាលីមួយមាត់ថា៖ *សសសសសសសសសសសសសសសសសស*(អានជាបាលី)រហូតដល់យើង មានអាការៈឈឺចុកចាប់ក្នុងដើមទ្រូង ស្ទើរតែលោតបេះដូងចេញមកក្រៅហើយ មានអារម្មណ៍ថា ព្រឺសម្បុរ ត្រជាក់ចុងដៃចុងជើង នោះមានន័យថាតួអង្គលោកអញ្ជើញមកនៅជិតយើងហើយ នៅតែយើងសម្រេចចិត្តថា ទទួលឬអត់ ។

បើទទួលចូលធ្វើចិត្តឱ្យសប្បាយៗ កុំមានៈ កុំរឹងត្អឹង នាំតែឈឺចាប់ខ្លួនឯងទេ ជួនកាលអាចសន្លប់ទៀតផង បើយើងទប់មិនព្រមទទួលយកនោះ។

ជំហានបន្ទាប់ គ្រូអ្នកបើកញាណនោះ នឹងសួរយើងជាភាសាអ្នកស្នងថា **៖ណាំខ ត្នល័យចៈ**[១] បើមិនឆ្លើយទេ ចាំមើលទៅ តើអាការៈនោះយ៉ាង...ខ្ញុំពិបាកប្រាប់ណាស់តែវាមិនសប្បាយទេ.។

១.តាមភាសាតួអង្គទេ

មូលហេតុនោះ គឺថា យើងខ្លាចនិយាយខុស តែកុំភ័យបើគ្រូគេហ៊ាន ឱ្យនិយាយ នោះមានន័យថា តួអង្គបានសន្ថិតក្នុងខ្លួនយើងហើយ បើយើងមិនឆ្លើយ យើងឈឺចាប់ដូចជា ដូចមានអ្វីមកធ្វើឱ្យដើមទ្រូងយើងស្ទះចឹង។ល។

ខ្ញុំពិបាកពណ៌នារឿងនេះឱ្យបានក្បោះក្បាយណាស់ ទាល់ដែលយើងបាន យើងជាអ្នកជួបខ្លួនឯងទើបដឹង។

នៅពេលដែលយើងបើកហើយ យើងមានអារម្មណ៍ថា ធូរស្បើយ ស្រាលខ្លួន ដេកលក់ស្រួល ។ តែត្រូវបដិបត្តិរាល់ថ្ងៃ បើតួអង្គឱ្យយើងសូធ្យអ្វីយើងត្រូវសូធ្យតាម លោក ដូចជា និយាយភាសាស្នងរូបម្នាក់ឯង សូធ្យគាថាស្នងរូបជាដើមនៅពេលយូរ ទៅ បើការបដិបត្តិបានល្អ (ស្គាល់ចិត្តថ្លើមគ្នា) ពេលខ្លះតួអង្គលោកអាចឱ្យយើង ឃើញពពួកវិញ្ញាណខ្មោចព្រាយបិសាចដទៃបាន អាចដឹងរឿងមុន អាចជួយគេបាន។ ល។

ចំណុចដែលបងប្អូនត្រូវចងចាំ អំពីតួអង្គ បងប្អូនអាចសំគាល់អ្នកស្នងបាន ថាពិតឬបោកប្រាសដោយគ្រាន់តែស្ដាប់ភាសា វិភាគនិងអាការៈបងប្អូនៈ

១.តួអង្គមិននិយាយភាសាបច្ចុប្បន្នទេ ព្រោះពួកលោក ជាមនុស្សសម័យ មុន ចឹងហើយភាសាបានវិវត្តន៍មកជាច្រើនសម័យកាល.ចំពោះតួអង្គខ្លះក៏មាន និយាយជាភាសាខ្មែរដែរ តែជាអ្នកស្នងត្រកូលឬអ្នកតាជាដើម។

២.ពេលគាត់និយាយជាភាសាតួអង្គនោះយើងមានអារម្មណ៍ ព្រឺសម្បុល ជា ពិសេសពេលដែលគាត់ទាយដួងជតា ហើយគាត់សួរថា ត្រូវឬទេ ។

ចឹងខ្ញុំសុំសង្ខេបប៉ុណ្ណេះចោះព្រោះពិបាកពណ៌នាណាស់

# អំពីគ្រូបៀនឬស្នងត្រកូល

❖រឿងនេះខ្ញុំពណ៌នាតែអំពីរឿងដែលខ្ញុំបានជួបប្រទះទេ ព្រោះបច្ចុប្បន្ននេះខ្ញុំជា អ្នកដែលបន្តវេនដូនតារបស់ខ្ញុំ ដែលមានអាយុកាល តាំងពីសតវត្សរ៍១៥មកម្លេះ.។

❖អ្នកស្នងត្រកូល ជាពាក្យមួយដែលប្រើទូទៅរួមមានដូចជាៈ ស្នងត្រកូលសេដ្ឋី ស្នងត្រកូលស្តេច ស្នងវង្សត្រកូលជាដើម តែក្នុងនេះខ្ញុំលើកអំពីការស្នងត្រកូលគ្រូខ្មែរឬគ្រូមន្តអាគមជាដើម

❖គ្រូបៀននេះមានច្រើនប្រភេទណាស់ មានតូច មានធំ តាមលំដាប់កម្រិតមន្តអាគមរបស់គាត់ ។

❖អ្នកដែលមានគ្រូបៀនកាន់នោះមានអាការៈដូចជាៈ

១.អស់កម្លាំង បរិភោគយ៉ាងណា ក៏នៅតែមានអារម្មណ៍ថា អស់ម្លាំងដដែល

២.ស្រវាំងភ្នែក ភ្នែកដូចមនុស្សចាស់ចឹង

៣.ជាមនុស្សចូលចិត្តសិក្សាខាងមន្តអាគម ថ្នាំខ្មែរ វិជ្ជាហោរាជាដើម។ល។

តើបងប្អូនមានអាការៈដូចនេះទេ ជួនកាលវាអាច ខុសប្លែកពីនេះដែរ បើគ្រូបៀនមកកាន់នោះ តូចឬសន្ធំសង្ខារជាដើម។

❖បើបងប្អូនមានគ្រូបៀន ឬស្នងពីត្រកូលហើយមិនបាច់រកមានគ្រូបច្ចុប្បន្ននោះទេ (តែបើមានក៏កាន់តែល្អបានអ្នកជួយពន្យល់ពីគាថា ផ្សេងជៀសវៀងប៉ះអថ័នខ្មៅ) ព្រោះយើងមានគ្រូស្រាប់ គ្រាន់តែសិក្សាគាថាមន្តវិជ្ជាទៅបានហើយ.។ តែបញ្ជាក់ថា បើបងប្អូនសិក្សាគាថាអ្វីមួយត្រូវអុជធូបអញ្ជើញគ្រូផង ឱ្យមកជួយប្រសិទ្ធីគាថាឱ្យខ្លាំងពូកែ តែបើបងប្អូនសិក្សាពីនរណាម្នាក់ដែលបានបង្ហាញគាថាដល់បងប្អូននោះ បងប្អូនត្រូវតែបដិបត្តិអ្នកនោះ ដើម្បីកុំឱ្យគាថាសាបរលាប យ៉ាងដូចជាការរំលឹកគុណគាត់ជាដើម នៅពេលយើងប្រើមន្តគាថានោះទើបល្អប្រសើរមានសិរីមង្គលឈ្នះសត្រូវបាន.។បងប្អូនជឿតាមខ្ញុំទៅៈកុំអំនួត ព្រោះថាគាថាទាំងអស់សុទ្ធតែម្ចាស់របស់វា ហើយបងប្អូនអាចគិតបាន បើមនុស្សធម្មតានោះមិនអាចរាយមន្តបានខ្លាំងពូកែយ៉ាងនេះទេ ។ ត្រូវអត់អ្នកអាន ខ្ញុំមានបទពិសោធន៍មុនបងប្អូនចឹងខ្ញុំត្រូវតែប្រាប់ព្រោះថាខ្ញុំជាគ្រូផងជារាមច្បងរបស់បងប្អូនផង។ អានដោយគិតពិចារណាទើបយល់ពីអ្វីដែលខ្ញុំនិយាយ๛

# អំពីដើមកំណើតគាថានៅខ្មែរ

បងប្អូនដឹងហើយថាប្រវត្តិសាស្ត្រខ្មែរ របស់យើងមានអំណាច និងរឿងអាថ៌កំបាំងយ៉ាងណា.........................។

នៅដើមសតវត្សរ៍ទី១ មានបុរសម្នាក់ជាជនជាតិខ្មែរ បានចេញសាងផ្នួសបួសជាបព្វជិតក្នុងពុទ្ធសាសនា រហូតលោកបានសិក្សាចប់នូវគម្ពីរ កច្ចាយនៈ ចប់ដោយបរិបូរណ៍ ហើយលោកបានលាចាកសិក្ខាបទ មកបួសជាឥសីវិញរហូតបានសម្រេចអភិញ្ញា៥ ចឹងលោកក៏បានសម្រេចចិត្ត តាក់តែងរាយមន្តគាថាឡើងដោយមានពពួកទេវបុត្ត ទេវតាទាំងឡាយផង មកប្រសិទ្ធីមន្តគាថានោះឱ្យខ្លាំងពូកែ ដោយលោកបានយកអក្សរ **ន** ជាគោលគាថាទាំងអស់របស់លោក ឧទាហរណ៍ថា **នមពទ** ជាដើម។

រហូតដល់បច្ចុប្បន្នក៏នៅមានអ្នកមិនជឿរឿងទាំងអស់នេះដែរ តែបើយើងវិភាគបន្តិចនិងយល់ហើយ អំពីព្រះរាជាមុនៗ អំពីមេទ័ពធំៗ យ៉ាងដូចជាលោកតាឃ្លាំងមឿង ភក្តីសង្គ្រាមហុក ជាដើមនោះមិចវិញ ចោះក្រឡាហោមគងនោះវិញមិចដែរ ។តែជឿអ្វី ត្រូវប្រើបញ្ញាផង ប្រយ័ត្នទឹកភ្នែកណា.៚

ចឹងកុំឱ្យខាត់ពេលវេលា យើងមកសិក្សាទាំងអស់គ្នាអំពីក្បួនយ័ន្តនិងមន្តគាថាទាំងអស់គ្នា ៚

៙ កុំជឿអ្វី ដែលយើងមិនបានគិតពិចារណា ៙

# ការសិក្សាមន្តអាគមតាមកម្រិតនិងរបៀបសិក្សា

❖កុលបុត្រខ្មែរទាំងអស់គ្នាដែលគោលបំណងចង់សិក្សាមន្តវិជ្ជាសម្រាប់ ជាខែលការពារខ្លួននោះត្រូវតែរៀបចំសក្ការៈថ្វាយគ្រូបាអាចារ្យសិន ដើម្បីឱ្យមន្តអាគមខ្លាំងពូកែ

❖ អំពីអត្ថន័យនៃការរៀបចំអាសនៈ

១.បាយសី ៣ ថ្នាក់ តំណាងគុណព្រះរតនត្រ័យ

២.បាយសី ៥ ថ្នាក់ តំណាងគុណព្រះពុទ្ធទាំង៥អង្គ

៣.បាយសី ៧ ថ្នាក់ តំណាងគុណញាតិទាំង៧សន្តាន(មួយទៀតសម្រាប់ថ្វាយគ្រូរបៀន)

៤.បាយសី ៩ ថ្នាក់ តំណាងគុណ មគ្គ៤ ផល៤ និព្វាន១

៥.បាយសី ១២ ឬ ២១ ថ្នាក់តំណាងគុណមាតា១២/២១សម្រាប់បិតា។ល។

ជាទូទៅបាយសីបងប្អូនត្រូវរៀបនោះ ត្រឹម៧ថ្នាក់ក៏បាន ៩ថ្នាក់ក៏បាន តាមសទ្ធារបស់បងប្អូន អ្វីដែលសំខាន់នោះគឺ ការបដិបត្តិទេ ។ល។

❖ អំពីប្រណាមដែលត្រូវគោរពតាមនោះខ្ញុំបានលើកមកសរសេររួចហើយក្នុងទំព័រមុននេះនេះ

❖ ការសិក្សាមន្តគាថាមិនមែនស្រួលដូចយើងហូបបាយទេ សូមលើកឧទាហរណ៍ថា ក្មេងមត្តេយ្យចូលរៀនអក្សរដំបូងគឺពិបាកណាស់ ទម្រាំបានចេះអានអក្សរ ចោះយើងវិញចាញ់ការព្យាយាមរបស់ក្មេងៗទាំងនោះដែរមែនបើការសិក្សាគាថាស្រួលនោះ ម្លោះហើយមានគ្រូខ្លាំងៗជាច្រើនហើយមិនមែនបានតែអួតនោះទេ | អ្វីដែលខ្ញុំចង់ប្រាប់ចង់សរសេរបន្តទៀតនោះគឺ បើបងប្អូនមិនអាចបដិបត្តិបាន មិនបាច់រៀនទេខាត់ពេលណាស់ ឧទាហរណ៍ដូចក្មេងមត្តេយ្យចឹងបើមិនព្យាយាមប្រកបអក្សរទេ កុំសង្ឃឹមថាចេះអានអក្សរនោះ បងប្អូនក៏ដូចគ្នាដែរ បើចង់ឱ្យគាថាខ្លាំងពូកែអាចប្រើការបាន នោះត្រូវព្យាយាមផង របស់ដែលល្អរបស់ដែលពូកែ គឺត្រូវការមនុស្សមានឆន្ទៈ និងការព្យាយាម មិនមែនមនុស្សខ្ជិល មែនជាមនុស្សភ្លើងចំបើងទេ

❖ ការបដិបត្តិ

ការបដិបត្តិនោះខ្ញុំគិតថា មិនពិបាកទេ

១.ថ្វាយបង្គំព្រះរតនត្រ័យ ព្រឹក ល្ងាច ព្រឹកពេលជិតភ្លឺ ល្ងាចពេលចូលដេក ការថ្វាយបង្គំព្រះរតនត្រ័យនេះសំខាន់ណាស់ យ៉ាងហោចណាស់បាន សូធ្យនមោ ៣ ចប់ក្នុង១ថ្ងៃ ព្រោះវាធ្វើឱ្យគាថារបស់យើងពូកែ មានពពួកទេវតាតាមរក្សាទៀត។

២.ការរក្សាសច្ចៈ

ត្រង់នេះខ្ញុំគិតជាល្អណាស់ ព្រោះមនុស្សម្នាក់ត្រូវតែនិយាយពាក្យ មានន័យថា និយាយមិចធ្វើចឹង មិនបាតដៃខ្នងដៃ ។

៣.រក្សាសីល

ការរក្សាសីលនោះខ្ញុំរឹតតែសរសើរថែមទៀតហើយព្រោះថា សីលជាអាវក្រោះ ដែលពូកែណាស់ ការរក្សាសីលនោះយើងអាចត្រឹមសីល៥បាន តែមិនមែនរាល់ថ្ងៃទេ គឺ១សីលម្តង ព្រោះថាកាលណាបើយើងមានភាពមេត្តាហើយពពួកសត្វទាំងអស់ រមែងគោរព រាប់អានស្រឡាញ់ចូលចិត្តយើងមិនខាន តែមិនទាំងអស់នោះទេ ចំពោះមនុស្សមួយចំនួនដូចអាប ធ្មប់ជាដើម។

**ត្រូវចំណុចទាំងនេះបើយើងបដិបត្តិបានល្អហើយកុំភ័យរឿងអានុភាពមន្តគាថានោះ ច្បាស់ណាស់គឺ៩០%ប្រើបានផល ១០%អត់បានផល។**

មិនបានជា១០%ទៀតមិនបានផល ពីព្រោះពេលប្រើគាថាចិត្តយើងរវើរវាយមិនស្ងប់ បើដោះអំពីគឺយើងខ្លាចចាញ់ មិនទុកចិត្តខ្លួនឯង ចឹងហើយបានខ្ញុំតែងតែឱ្យសិស្សរបស់រៀនបរិកម្មដង្ហើម រៀបមានសតិ មានទំនុកចិត្តលើគ្រូរបស់គ្រូ លើគាថាដែលបានសិក្សា ហើយកុំឆ្ងល់ច្រើនពេក អត់ប្រយោជន៍ដល់ការរៀនទេ.។

## ជំហានដំបូងបំផុតនៃការសិក្សា

ជំហានដំបូងនោះគឺដាច់ខាតត្រូវសិក្សាគាថាថ្វាយបង្គំព្រះរតនត្រ័យថ្វាយបង្គំអារាធនាគ្រូមកគង់លើអាសនៈសិនះ

គាថាថ្វាយគ្រឿងសក្ការៈ

**ឥមេហិ ទីបធូបា ទិសក្ការេហិ ពុទ្ធំ ធម្មំ សង្ឃំ អភិបូជយាមិ មាតាបិតា ទិនំ គុណវន្តានញ្ច មយ្ហញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ។**

ថ្វាយបង្គំ រួចលើកសក្ការៈបូជារបស់ដាក់លើអាសនៈ

រួចមកសូធ្យនមោ

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស** ៣ចប់

*គាថាសរសើរព្រះនាមព្រះពុទ្ធជាម្ចាស់*

**ឥតិបិសោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោភគវាតិ។ តំ អរហាទិគុណសំយុត្តំ ពុទ្ធំ សិរសា នមាមិ តញ្ច ពុទ្ធំ ឥមេហិ សក្ការេហិ អភិបូជយាមិ។**ថ្វាយបង្គំម្តង

*គាថាសរសើរគុណព្រះធម៌*

**ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ។ តំ ស្វាក្ខាតា ទិគុណសំយុត្តំ ធម្មំ សិរសា នមាមិ តញ្ច ធម្មំ ឥមេហិ សក្ការេហិ អភិបូជយាមិ។**ថ្វាយបង្គំម្តង

*គាថាសរសើរគុណព្រះសង្ឃ*

**សុបដិបន្នោ ភគវតោ សាវកសង្ឃោ**
**ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ**
**ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ**
**សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ**
**យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋ បុរិស បុគ្គលា ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ**

**អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ។ តំ សុបដិបន្នា ទិគុណសំយុត្តំ សង្ឃំ សិរសា នមាមិ តញ្ច សង្ឃំ ឥមេហិ សក្ការេហិ អភិបូជយាមិ។**ថ្វាយបង្គំម្តង

នៅពេលដែលបងប្អូនបានថ្វាយបង្គំគុណព្រះរតនត្រ័យរួចហើយគប្បីសូធ្យគាថាអញ្ជើញគ្រូមកគង់លើអាសនៈ ចូលបងប្អូនធ្វើបែបនៅពេលដែលថ្ងៃទំនេរបានហើយជៀសវៀងប៉ះពាល់ការងារ នាំឱ្យកើតទោសៈ ។

គាថាអញ្ជើញមានច្រើនណាស់សម្រាប់បងប្អូនសូធ្យ តែបើខ្ញុំនិយមប្រើបំផុតនោះ ជាប្រភេទភាសាបាលីសុទ្ធ ។

គាថាអញ្ជើញគ្រូ

**ត្រីនិសន្ទេ សត្តនាគេ បញ្ចា ពិស្ណុ នមេ ខច ចតុទេវា ឆឥទ្ធិរាជា បញ្ចា ឥន្ទ្រា នមេខច ឯកយក្ខា នវទេវា បញ្ចព្រហ្មា សហម្បតី ទ្វេរាជាអដ្ឋ អរហន្តា បញ្ចពុទ្ធា នមាមិហំ** ។សូត្រ៧ចប់តាំងបិត្តផង

គាថាអញ្ជើញគ្រូ

**ឥស្វាសុ ភូមិន្ទ ទេវយំ ឥសាន្តរាជា នមោ មម**។សូត្រ៧

គាថាអញ្ជើញគ្រូ

**ពុទ្ធំគច់ ធម្មំគច់ សង្ឃំគច់ អរហំញាណំគច់ ទេវយំគច់ ឥសីសច្ចំគច់ ទើបគ្រូស្រើ**អញ្ជ្រវន្ទាអារាធនា អស់គ្រប់អង្គព្រះបារមី គ្រប់ទិសទាំង៨ មហាស្វេតឆត្រ័មកគង់ គ្រងទីអាសនៈនៃខ្ញុំព្រះករុណា **សព្វអរហំ បារមីញាណំ ករោមិ ស្វាហះ** ។សូត្រ៧ចប់

គាថាអញ្ជើញគ្រូ

**ឧម្ហៈ អញ្ជើញគ្រូ ព្រះរាហូអគ្គេយ៍ ចាត់អារក្សធំទាំង មួយម៉ឺន លោកធាតុមកជួយទល់ខ្លួន នៃពួកពលអញ្ជខ្ញុំ ស្វាហះ**។សូត្រ៧ចប់

គាថាអញ្ជើញគ្រូ១០០គុណ

**ទើបអញ្ជើញព្រះព្រហស្បតិ៍ ទើបអញ្ជើញគ្រូទេវតា ទើបអញ្ជើញ ព្រះមាតា ព្រះបិតា ព្រះឥន្ទ ព្រះព្រហ្ម ព្រះនាងគង្ហីង ធរណីលោកមកជួយខ្ញុំ ស្តេចយាងចុះមកគង់ពីរលើក្បាល សន្ធិតលើស្មាក្រឡាសាច់ យំ យំ ឥ ថ ច សុ ធរណី គង្គា ល ហ ហុ** ។សូត្រ៧ចប់

គាថាអញ្ជើញគ្រូ១០០គុណ

**ឧកាស អហំ អញខ្ញុំសូមអារាធនាស្តេចកំហែងហុល្លមាន ត ន ណាគ្រូវើយ ឆាប់ណាគ្រូវើយ ដៃអញអើយរឹងដូចដែក ភ្នែកអញ អើយភ្លឺដូចពេជ្រ សាច់អញអើយរឹងដូចថ្ម នគង់សា ៉ាក់ មោគង់សា ៉ាក់ ពុគង់សា៉ាក់ ធ្លាពុគង់សា៉ាក់ យពុគង់ សា៉ាក់ ឧ អ អ៊ឹ នរាធាំង ពុផាយផាត់ នផាត់ មោផាត់ ពុផាត់ ធ្លាផាយផាត់ យផាយផាត់ នម អឧ ឧអនម មអផាយផាត់**។សូត្រ៧ចប់

គាថាអញ្ជើញគ្រូ១០០គុណ

**ឧម នមោ ហុល្លមានកោឡាហល់ មិនានុកល់ ឥ អ ឧ ឧ អ រុល្ល រុល្ល រុល្លរិល្ល ក្រុងមហារំអិលកម្លាំងអញអើយបីដូច ប្រថពី សិល្ប៍ ហើរ ហើរហោះឆ្លាយឆ្លុះព្រះធរណីក្រឡាប់ៗ ក្រឡាឆ័ត្រ ផ្អៀងធ្លាក់ ពួកពលយោធាស្លុតស្លាប់តាន់តាប់ ណាគ្រូវើយ** ។សូត្រ៧ចប់

គាថាអញ្ជើញគ្រូ១០០គុណ

**ឧកាស អរហំ អញខ្ញុំសូមអារាធនានិមន្តគុណ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ព្រះឥន្ទ ព្រះព្រហ្មផង ទើបអញ្ជើញព្រះអាទិត្យ ទើបអញ្ជើញព្រះចន្ទ ស្តេចចុះមកជួយប្រសិទ្ធី ព្រុំប្រក់ ព្រុំពល ដៃស្តាំ អញអើយកាន់នូវទឹកកន្ទី ដៃឆ្វេងអញអើយកាន់នូវលាច គ្រូបាច គ្រូសាចគ្រប់ៗអស់អន្តពួកពលប្រុសស្រី ពុបុត្រ ឆាបុត្រ មោបុត្រ យបុត្រ សា៉ាយគង់ជិត គខន សា៉ាយគង់ជិត យខន សា៉ាយគង់ ជិត ខន សា៉ាយគង់ជិត ជិតគង់ ឥ អ តិ អ សោ សោ ស្វាហាប់**។សូត្រ៧ចប់

គាថាអញ្ជើញគ្រូ១០០គុណ

**ឯហិ ពុទ្ធានុភាវេន ឯហិ ធម្មានុភាវេន ឯហិ សង្ឃានុភាវេន ឧជេឯហិ សព្វ គន្ធ ករោថ មម បសិទ្ធី ហោន្តុ**។សូត្រ៧ចប់

គាថាអញ្ជើញគ្រូ១០០គុណ

**ឧភាស ពុទ្ធំ អារធនំ ករោមិ**

**ឧភាស ធម្មំ អារធនំ ករោមិ**

**ឧភាស សង្ឃំ អារធនំ ករោមិ**

**ឧភាស** ខ្ញុំព្រះករុណា សូមអារាធនា គុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ គុណមគ្គផល គុណអដ្ឋង្គិមគ្គ អង្គ៨ សីល ទាន ភាវនា សូមយាងមកជាទីពឹង

**ឧភាស** ខ្ញុំព្រះករុណា សូមអារាធនា គុណសម្តេចគ្រូតូច ធំ គ្រូសន្ធិសង្ខារ ស្តេចព្រះអប់នមកជំនុំក្នុងអង្គកាយនៃខ្ញុំសូមអារាធនា ស្តេចព្រះគាថា ស្តេចយ័ន្តអក្ខរា មកជុំក្នុងមាត់នៃខ្ញុំ **ឧឧមម ន** បិតជួយរាំង **មោ** បាំងបិត **ពុ** រាំងយាំង **ធា** បញ្ចៀស **យ** សន្ធិតអង្គខ្ញុំ **ស្វាហាៈយៈ**។ ៧ចប់

គាថាអញ្ជើញគ្រូ១០០គុណ

**ឧភាស អរហំ អញ្ជូខ្ញុំសូមអារាធនានិមន្ត គុណ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ព្រះឥន្ទ ព្រះព្រហ្មផង ទើបអញ្ជើញ ព្រះអាទិត្យ ទើបអញ្ជើញព្រះច័ន្ទ ស្តេចចុះមកជួយប្រសិទ្ធី ព្រុំប្រក់ ព្រុំពល ដៃស្តាំអញ្ជូអើយកាន់នូវទឹកកន្ទី ដៃឆ្វេង អញ្ជូអើយកាន់នូវលាដ គ្រូបាច គ្រូសាចគ្រប់ៗអស់អន្ត ពួកពលប្រុសស្រី ពុបុត្រ ធ្វាបុត្រ មោបុត្រ យបុត្រ សារ៉ាយ គង់ជិត គខន សារ៉ាយគង់ជិត យខន សារ៉ាយគង់ជិត ខន សារ៉ាយគង់ជិត ជិតគង់ ឥ អ តិ អ សោ សោ ស្វាហាប់**។៧ចប់

គាថាអញ្ជើញគ្រូ១០០គុណ

**ទើបអញ្ជើញគ្រូព្រះពុ ទើបអញ្ជើញគ្រូទេវតា ទើបអញ្ជើញ ព្រះមាតា ព្រះបិតា ព្រះឥន្ទ ព្រះព្រហ្ម ព្រះនាងគង្ហីងធរណី លោកមកជួយខ្ញុំស្តេចយាងចុះមកគង់ពីរលើក្បាល សន្ធិតលើស្មា ក្រឡាសាច់ យំ យំ ឥ ថ ចសុ ធរណី គង្គា ល ហ ហុ**៕

គាថាអញ្ជើញគ្រូ១០០គុណ

**ឱម្ម: ដាស់កឺង មហាដាស់កឺង ទើបគ្រូប្រើអញ ដាស់ទាំង នាំងអាគមគាថា ដាស់ទាំងកន្សែង លេខ យ័ន្ត អក្ខរា មន្ត គាថា ឱម្ម: ដាស់មហាសារពើរដាស់។**៧ចប់

គាថាអញ្ជើញគ្រូ១០០គុណ

**ឧកាស** ខ្ញុំព្រះករុណាសូមនិមន្តយាង គុណព្រះរតនត្រ័យ គុណអរិយមគ្គ គុណសីល សមាធិ បញ្ញា យាងមកជាទីពឹង ខ្ញុំសូមអារាធនា គុណស្តេចទេវតាធំ គង់នៅ បរនិម្មិតសវតី សូមយាងអញ្ជើញទេវតា ទាំង១សែនកោដិចក្រវាឡ មកជួយ ខ្ញុំគុណព្រះព្រហ្មទាំង១៦ជាន់ **ប ន តុ យា តា ច** ស្តេចយាងមក ព្រមទាំងទាំង **សហស្សនេត្តោ ឥន្ទ្រទេវា ចតុមហារាជិកា** ព្រះបាទវេស្សវ័ណ ព្រះបាទវិរុឡ្ហកៈ ព្រះបាទធតរដ្ឋ ព្រះបាទវិរូបក្ខ សូមយាងមកជាទីពឹង **ខ្ញុំកាស** ខ្ញុំព្រះករុណាសូម អារាធនា សម្តេចព្រះគ្រូធំ ជុំនុំព្រះអច័នធំ ជុំនៅបាតអង្គរ **ឧឧមម នមោពុទ្ធាយ មអឧ ស្វាហៈ** ។ ៧ចប់

គាថាអញ្ជើញទេវតា

**សគ្គេ កាមេ ច រូបេ គិរិសិខរតដេ ចន្តលិក្ខេ វិមានេ ទីបេ រដ្ឋេ ចគាមេ ត រុវនគហនេ គេហវត្ថុម្ហិ ខេត្តេ ភុម្មា ចយន្តុ ទេវា ជលថ លវិសមេយក្ខគន្ធព្វនាគា តិដ្ឋន្តា សន្តិកេ យំ មុ និវរចនំ សាធវោ មេ សុណន្តុ។**

**ធម្មស្សវនកាលោ អយម្ភទន្តា**

**ធម្មស្សវនកាលោ អយម្ភទន្តា**

**ធម្មស្សវនកាលោ អយម្ភទន្តា។**១ចប់ឬ៣ចប់

គាថាអញ្ជើញទេវតា

ទេវតាទាំងឡាយដែលស្ថិតនៅក្នុងស្ថានសួគ៌ ដែលជាកាមភព និងរូបភពក្តី ភុម្មទេវតាទាំងឡាយដែលស្ថិតនៅក្នុងទិព្វវិមាន គឺលើ កំពូលភ្នំ ឬភ្នំដែលដែលដាច់ក្តី ព្វដ៏អាកាសក្តី នៅនាកោះ និងដែន និង ស្រុកក្តី នៅនាដើមព្រឹក្ស និងព្រៃញាតស្បាត ឬទីស្រែចំការក្តី យក្ខ និងគន្ធព្វ និងនាគទាំងឡាយ ដែលស្ថិតនៅនាទីទឹកគោក ឬទី មិនរាបស្មើ ដែលនៅក្នុងទីជិតនេះក្តី សូមអញ្ជើញប្រជុំគ្នា ក្នុងទីនេះ ពាក្យឯណា

ដែលជាពាក្យព្រះសាក្យមុនីដ៏ប្រសើរ ដែលយើង នឹងសូត្រឥឡូវនេះ លោកអ្នកសប្បុរសទាំងឡាយ ចូរស្តាប់នូវពាក្យនោះ ដោយគោរព ។

*គាថាអញ្ជើញទេវតា(បទធំ)*

**សព្វេទេវា** រីទេវតាទាំងឡាយ ទាំងពួង **តិដ្ឋន្តា** ស្ថិតនៅ **សគ្គេភាមេច** នៅពួដ៏ភូមិភពគ្រប់សកលមណ្ឌលដែនដី ក្នុងជ្រុងជ្រោយចន្លោះទួលខ្ពស់របស់ធរណី **គិរិសិគ្ខរដ្ឋដេច** នៅពួដ៏ លើភ្នំលើថ្មតូចធំ ប្រជុំអមអាម៉ហ៍ ជ្រោះជ្រងឈូងធក ក្បាលហុងជង្ហុកមូលមក យើងខ្ញុំបួងសួង រកអ្នកទេវ**តា អន្ត លិក្ខេត** តាំងតែពីដែនដីផ្ទៃភូមិប្រឹថពី ទេវតានៅទីអាកាសពាសមេឃា ទេវតា ទិសទាំង ៨ អាស្រ័យនៅក្នុងគុកគុហា ចូលមកជួយជាកសិណសាក្សី វិមានេប នៅក្នុងវិមានស្ថានតូចធំ ចូលមកប្រជុំដោយសព្វទិសទី ទេពកិន្នរី នៃនាងធិតា **ទីបេ រដ្ឋេច** ទេវតានៅពួដ៏ គោក កោះ ចន្លោះទឹកបឹង ស្ទឹង ទន្លេរ៉ៀមរអូរ ជង្ហុកថ្លុកមាត់ា គ្រប់ស្ថាននានា មូលមកប្រជុំ **គាមេច** នៅពួដ៏កាមភពក្តី ភូមាច ទេវតារក្សាស្រុក ស្រះស្រង់ របស់របងក្នុងបន្ទាយទេពធីតាទាំងឡាយ មូលមកប្រជុំការ **តរុនវនគហនេ គេហវត្ថុម្ហិ ខេត្តេច** ទេវតានៅព្រៃ ពួដ៏ដើមឈើតូច ធំ ពាសពេញក្រមុំ លំពោះលំពង់ ចន្លោះស្រោងស្រោង ក្នុងរបោះរបងដងព្រៃ ព្រឹក្សា នៅក្នុងស្រែចំការស្បារដំណាំទេវតាប្រចាំភូមិភពគ្រប់ សកលជុំចក្រវាឡ ជលធលវិសមេច ទេវតានៅពួដ៏គោកកោះ ចន្លោះទឹកបឹង ស្ទឹងគង្គា អញ្ជើញមកជាអធិបតី យក្ខគន្ធព្វនាគាច រីយក្ខគន្ធព្វ មហោរង់កុជង្គនាគា អញ្ជើញទេវតា តិដ្ឋន្តា ស្ថិតសព្វឋាន **សន្តកេ** មកកាន់សំណាក់ស្នាក់អាស្រ័យនៃយើងខ្ញុំ សុណន្តុធម្មំ ចូរតាំងមកស្តាប់ធម៌ មុនីវរវចណំ នូវព្រះបន្ទូលនៃព្រះដ៏មាន បុណ្យដ៏ប្រសើរ ។ ភន្តោ ទេវសំឃាយោ ហៃម្នាលទេវតាដ៏មានឫទ្ធានុភាពផងទាំងឡាយអើយ អយំកាលោ រីកាលនេះ **ធម្មស្សវនកាលោ** ជាកាលគួរនិងស្តាប់នូវព្រះធម៌ហោង ។

ធតរដ្ឋោ រីព្រះបាទធតរដ្ឋ ស្ថិតឋានកំណត់ទិសបូព៌តំបន់ ព្រះបាទវិរុឡ្ហកៈ ទក្សិណសោ ភ័ណ ព្រះបាទវិរូបក្ខៈ កាន់ទិសបស្ចឹមា ព្រះបាទកុវេរុរាជ្យ រិទ្ធីអំណាចឧត្តរទិសា មហារាជ ទាំង៤ ជាស្តេចនៃទេវតានាឋានចតុមហារាជិកា អញ្ជើញមកជាអធិបតីនៃពិធីនេះ។

ទោះទាំងទេវតាដែលគង់គ្រប់ទិសទី ទាំងគន្ធព្វគ្រុឌនាគ ព្រះឥន្ទ ព្រះព្រហ្ម ព្រះចតុ លោកបាលា ទាំងនាងគង្ហីងទេពព្រះធរណី និងទេព្ដាស្ថិតនៅគិរីទីព្រឹក្សាព្រៃ ទ្វីបកោះជ្រោះជល ស័យ សមុទ្រនោះនៃ ស្ទឹង នទី និងទេវតា ស្ថិតឯសព្វឋានសួគ៌ាវិមាន នាអាកាសស្ថាន យើងខ្ញុំ សូមរំលឹកនឹកប្រកាស អញ្ជើញអ្នកជាអធិបតី សូមអ្នកជួយបំបាត់ទុក្ខសោករោគភ័យ និងក្ដីអន្ដរាយទាំងឡាយទាំងពួង និងសូមឱ្យយើងខ្ញុំបានសុខក្សេមក្សាន្តសួស្ដី ជ័យវុឌ្ឍីទីសប្បាយ ក្នុងអង្គរង់រូកាយ ឱ្យបានចំរុងចំរើន អាយុយឺនយូរ ដោយអំណាចគុណបុណ្យតេជៈ មគ្គផលសីល ទានភាវនា សូមអោយយើងខ្ញុំបានសំរេចនូវសម្បត្តិ ៣ប្រការគឺ សម្បត្តិមនុស្សមួយ សម្បត្តិទេព្ដា មួយ និងសម្បត្តិព្រះនិព្វានមួយ ជាទីអវសាន្ត កុំបីឃ្លៀងឃ្លាតឡើយ។

*គាថាអញ្ជើញទេវតា*

**សមន្តា ចក្កវាឡេសុ អត្រាគច្ឆន្តុ ទេវតា សទ្ធម្មំ មុនិរាជស្សសុណន្តុ សគ្គមោក្ខទំ ភន្តេ ភគវា សុចិរ បរិនិព្វុតោ**

**ពុទ្ធោ មេ នាថោ ធម្មោ មេ នាថោ សង្ឃោ មេ នាថោ។** ១ចប់

*គាថាអញ្ជើញទេវតា*

ទេវតាទាំងឡាយ ក្នុងចក្រវាឡទាំងឡាយ ដោយជុំវិញ សូមអញ្ជើញមកប្រជុំគ្នាក្នុងទីនេះ ចូរស្ដាប់នូវព្រះសទ្ធម្ម ជាធម៌អាចឲ្យនូវស្ថានសួគ៌និងព្រះនិព្វាន (របស់ព្រះសម្មាសម្ពុទ្ធ) ជាស្ដេចនៃអ្នកប្រាជ្ញ ។ ព្រះដ៏មានបុណ្យជាម្ចាស់ដ៏ចម្រើន ព្រះអង្គទ្រង់ចូលបរិនិព្វាន ជាយូរអង្វែងហើយ

ព្រះពុទ្ធជាម្ចាស់ជាទីពឹងនៃខ្ញុំ ព្រះធម៌ជាម្ចាស់ជាទីពឹងនៃខ្ញុំ ព្រះសង្ឃជាម្ចាស់ជាទីពឹងនៃខ្ញុំ ។

*គាថាអញ្ជើញគ្រូ*

**នមត្ថុ** គ្រូអើយទើបអញ្ជើញលោកគ្រូ ព្រះវេស្សវ័ណ មកកាន់អង្គទើបអញ្ជើញលោកគ្រូព្រះខ្លោង មករក្សាណា **ឯហិមម** ។ សូត្រ៣ចប់

គាថាអញ្ជើញគ្រូ

**ឯហិ ឯហិ** គ្រូអើយ ម៉ាម៉ា មកគង់ណា **ស្វាហាយៈ ឥស្វាសុ សុ ស្វាហាយៈ**។ សូត្រ៣ចប់

គាថាអញ្ជើញគ្រូ

**ឱកាស** ខ្ញុំព្រះករុណា សូមអារាធនា និមន្តគុណ ព្រះគាថា ស្តេចយ័ន្តអក្ខរា ករីទេព ជាស្តេចចងព្រះវេទគាថា អញ្ជើញគុណជូនតាព្រះអថ័នធំ មកជុំនៅឯខ្លួនខ្ញុំ ហោង **នមពធ ភគខយចធ ឥស្វាសុ នមោពុទ្ធាយ** យាងមកដូចបំណងហោង។៣ចប់

❖ ចឹងគាថាខាងលើនេះជាប្រភេទគាថាដំបូងនៃការសិក្សា ដើម្បីអារាធនាសម្តេចព្រះគ្រូធំ-តូចមកជួយប្រសិទ្ធីមន្តគាថារបស់យើង។

❖ សេចក្តីចំណាំះបើបងប្អូនសូត្រហើយ មិនអាការៈអ្វីសូមប្តូរគាថា ១ទៀតភ្លាម ព្រោះថាបើមានគ្រូយាងមកយើងនឹងមានអាការៈថា ព្រឺព្រួញ ឬធ្ងន់ស្មា ជាដើម។ល។ ត្រង់ចំណុចនេះ បើបងប្អូនអារាធនាលោកមិនអញ្ជើញមកនោះមាន ន័យថាយើងបានខុសអ្វីមួយហើយ ដូចជាខុសប្រណម ខុសសីល គាថាខុស ឬចិត្ត មិនស្ងប់ រវើយរវាយ ចឹងលោកពិបាកយាងមកគ្រងណាស់។

❖ ឧទាហរណ៍ ៖បើយើងធ្វើកន្លែងណាមួយ ហើយយើងខ្ជិលមិន ឧស្សាហ៍ព្យាយាមការងាររទេ នៅពេលមានរឿងអ្វីប្រធានឬអ្នកគ្រប់គ្រងយើងគេមិន ចង់ជួយទេ ចំពោះមនុស្សប្រភេទនេះ យ៉ាងណាវិញអ្នកសិក្សាមន្តគាថាក៏ដូចគ្នាដែរ បើខ្ជិល មិនបដិបត្តិ មិនឧស្សាហ៍ មិនធ្វើជាមនុស្សថ្មីទេ កុំសង្ឃឹមថា លោកជួយនោះ សមដូចពាក្យមួយគេថា៖ បើចង់ជួយអ្នកក្រៅ ត្រូវរក្សាអ្នកក្នុងសិន។

**នមោពុទ្ធាយ សិទ្ធំ សូមឱ្យការសិក្សាបានសម្រេច**

បន្ទាប់ពីបានទន្ទេញគាថារំលឹកគុណព្រះរតនត្រ័យបានចេះស្ទាត់ហើយគប្បីទន្ទេញគាថាអញ្ជើញគុណគ្រូថែមទៀត តែកុំលំៗណា ប្រយ័ត្នមានភ័យអាសន្នអីសូត្រមិនត្រូវ (រៀនអ្វីរៀនឱ្យប្រកដ) ។បើទន្ទេញចាំហើយមកសិក្សាជំហានទី២ (ខ្ញុំសូមសួរបងប្អូនមួយក្នុងចំណោមគម្ពីរ៣ក្បាល ៖

១. គម្ពីហោរាសាស្ត្រ សម្រាប់ដឹងពីពេលវេលា ជោគជតារាសី

២.គម្ពីមន្តអាគមខ្មៅ ប្រភេទស្នេហ៍ អាចឱ្យនារីទាំងអស់ស្រលាញ់បាន

៣.គម្ពីមន្តអាគមសង្គ្រោះនិងជាខែលការពារ

ក្នុងចំណោមគម្ពីទាំង៣នេះតើបងប្អូនជ្រើសយកមួយណា រយៈឆ្លើយមានពេលត្រឹមតែ៣វិនាទីប៉ុណ្ណោះ ចម្លើយគឺយកពីក្នុងចិត្តបងប្អូន ៖..........................

បើបងប្អូនយកទី១ គ្រូអ្នកបង្រៀនបងប្អូនលោកនិងឱ្យបងប្អូនសិក្សាបន្ទាប់ពីគេ បើយកទី២ លោកមិនបង្រៀនទេ ព្រោះចិត្តបងប្អូន គិតប្រទូស្តគេហើយ បើយកទី៣ បងប្អូននិងបានសិក្សាមុនគេ នេះជាជំហានដែលខ្ញុំសិក្សា កាលពីដើមឡើយគឺខ្ញុំសិក្សា៣នាក់ ដល់ពេលនោះគ្រូលោកសួរថា ក្នុងគម្ពីទាំង៣តើ កូនគិតយកមួយណា ខ្ញុំក៏បានប្រណិធាន សម្បថថា ខ្ញុំព្រះករុណា សិក្សាមន្តវិជ្ជាការមកនេះ គឺសុំយកមកការពារខ្លួន សង្គមជាតិ និងគ្រួសារ សាសនាប៉ុណ្ណោះ ។ពេលនោះលោកក៏បានយកខ្ញុំជាសិស្សទី១ ឬសិស្សច្បងគេ ។

## ជំហានទី២ សិក្សាអំពីការចាក់សោខ្លួនឯង

ជំហាននេះគឺការចាក់សោ ឬរក្សាមន្តគាថាឱ្យនៅក្នុងខ្លួនយើងកុំឱ្យអ្នកដទៃស្រូបគាថារបស់យើង គួរតែសូត្ររាល់ថ្ងៃមុនចូលដេក ៖

គាថាចាក់សោ

**ឧម: ពុទ្ធំ មហាពុទ្ធំ ឧម: ពុទ្ធំ មហាពុទ្ធំ ឧម: គតថេរំ សោធាយ សីល នម សីសោ សីល ពុទ្ធោ នមោពុទ្ធាយ ម.អ.ឧ**។៣ចប់

គាថាចាក់សោ

**ពុទ្ធំ គង់ ធម្មំ គង់ សង្ឃំ គង់** ។៧ចប់

គាថាចាក់សោ

**ពុទ្ធំរឹង ធម្មំរឹង សង្ឃំរឹង** ។ ៣ចប់

**ពុទ្ធំសីមារឹង ធម្មំសីមារឹង សង្ឃំសីមារឹង** ។ ៣ចប់

គាថាចាក់សោ

**ច អ ក** (ឈ្មោះខ្លួនឯង)។ ៣ចប់

គាថាចាក់សោឬការពារឆ្នប់

**នចៈ តិសិ លិយវៈ វត្ត អមៈ កតវី** ។៧ចប់

គាថាចាក់សោឬសីមា៨ទិស

**នមោពុទ្ធាយ ឥស្វាសុ អជ្ជំ ឋិសៈ តចៈ តភា តទំ លិនី រីតំ អអ** ។៧ចប់

គាថាចាក់សោ

**យនៈ យៈនី ឧ**សន្ទឹង **យនី ឥអៈ យនីឧ** ។ ៧ចប់

គាថាចាក់សោ

**បាបៈ សវៈ កអៈ មេឧ និចៈ កលោឧ អរហំឧ** ។ ៧ចប់

គាថាចាក់សោ

**នមោពុទ្ធាយ យឧ ឥមៈ ពៈធី** សន្ទឹង **ឧ ពុពៈ ចឥ** ។៧ចប់

គាថាចាក់សោ

**ឥតិបិសោ តគវា អរហំ គលិ សិតំ យំទំ អំសិ មិតំ ទំឧំ ចតិ** ។

❖ ចំពោះគាថាខាងលើនេះគឺសម្រាប់បងប្អូនសិក្សានៅពេលដែលកំពុងសិក្សាមន្តគាថា ព្រោះខ្ញុំធ្លាប់ឆ្លងកាត់ដំណាក់កាលដំបូងនោះហើយ ដោយពេលនោះខ្ញុំកំពុងស្វាធ្យាយទន្ទេញគាថាអញ្ជើញគ្រូ នោះមុខអាសនៈ ស្រាប់តែមានសត្វដង្កូវមួយយ៉ាងធំប៉ុនមេដៃ មកនៅក្នុងចានសក្ការៈរបស់ខ្ញុំ ពេលនោះខ្ញុំភ័យណាស់ព្រោះតែខ្ញុំឃើញសត្វមួយភ្លែត ស្រាប់តែបាត់វិញភ្លាមៗ ទើបខ្ញុំរត់មកសួរដល់គ្រូ ពេលនោះសម្តេចគ្រូធំលោកយាងមកសន្និតដល់គ្រូខ្ញុំភ្លាម តែខ្ញុំមិនដឹងថាលោកនិយាយអីទេ

ជាភាសាភាផ្សេង  ដល់ពេលដែលសម្តេចលោកយាងទៅវិញទើបគ្រូរបស់ខ្ញុំឆ្លើយថា គេចង់សាកល្បងយើង តើយើងមានឆន្ទៈក្នុងសិក្សាឬទេ ចឹងហើយលោកក៏បានផ្តល់គាថា១មេទៀតឱ្យខ្ញុំសិក្សានោះគឺ ៖

❖ **នមោពុទ្ធាយ មអឧ អសំវិសុលោអបុសពុភ ទាសីនេបវិឧសអមេឧ** ។ភាវនាពេលដេក អាចបញ្ចៀសភ័យ បណ្តេញ ខ្មោចព្រាយបិសាចបាន ចឹងហើយសូមលើកពី  បទពិសោធន៍របស់មកបង្រៀនបងប្អូនដើម្បីបងប្អូនងាយសិក្សា ហើយខ្ញុំក៏ប្រមូលគាថា ពីគម្ពីរដទៃទៀតមកបញ្ចូលគ្នាដែរ ។ ខ្ញុំសូមអភ័យទោសដល់ម្ចាស់ដើមគាថាផង  ដែលមិនសុំការអនុញ្ញាត  តែដើម្បីជាការថែរក្សាកេរ្តិ៍ដំណែលដូនតាដែលលោកបានបន្សល់ទុកឱ្យកុលបុត្រប្រើជាខែលឬអាវុធសម្រាប់ការពារខ្លួននិងអ្នកដទៃ។  បើយើងមិនថែរក្សាតើអ្នកណាជាអ្នកថែរក្សាទៅ  មានតែពួកយើងទេ ចឹងខ្ញុំក៏សង្ឃឹមថា បងប្អូន និងជួយថែរក្សា និងបដិបត្តិតាម។

❖ បន្ទាប់ពីសិក្សាគាថាខាងលើហើយ បងប្អូនអាចរៀនគាថាដទៃបាន រួមមាន គាថាចំណង  ស្តេចអថ័ន  គាថាដាស់ឬបំបួសយ័ន្ត  គាថាផ្សេងៗទៀតដែលបងប្អូនមានបំណងចង់ចេះចង់រៀនសូត្រ ។

❖ តែខ្ញុំសូមផ្តាំថា  កុំសិក្សាគាថាណា  ដែលមិនប្រកពច្បាស់លាស់ជៀសវៀង ខុស១ថ្ងៃ ខុស១ជីវិត *(បំណាន់ល្អពីខ្ញុំ ម្ចាស់ឆាឆៃល អទិទេព ផ្លូវឯងនឹត)*

# (បើចង់បានសម្រេចអ្វីមួយ ត្រូវតែព្យាយាមធ្វើវា)

# អំពីយ័ន្តនិងគាថាដាស់ព្រលឹងយ័ន្ត

យ័ន្ត គឺជាគំនូសដែលគេគូរឡើងដោយមានចង់មន្តអាគមគាថាផ្សេង សម្រាប់សូត្រសេពមន្តគាថា ឬសរសេរតួអក្សរគាថាបាលីអាគមផ្សេងៗទៀតដែលមានក្រឡាធ្លាក់គ្នា នៅជ្រុងមួយទៅជ្រុងមួយ ដើម្បីជាខែលឬអាវគ្រោះការពារទូទៅដូចអាវុធគ្រប់ប្រភេទ ខ្មោចព្រាយបិសាច ជាដើម។ល។



យ័ន្តសីមា៨ទិស សម្រាប់គូរលើក្រណាត់បញ្ចៀសឧបសគ្គនានា អាចបញ្ចៀសអាវុធបានទៀតផង

បាលីក្នុងនោះ គឺមាន ៨ ជាគោលយ័ន្ត ត្រង់ចំណុចកណ្តាលមាន គាថា៖ ឧទ្ធំ អទ្ធោ ជាគាថាមហាឧទ្ធបាញ់អត់មុត ឬបាញ់មិនចេញ

យ័ន្តនេះមានអានុភាពតាមកម្លាំងគ្រូអ្នកដាស់ព្រលឹងរបស់វាដែរ បើគ្រូអ្នកដាស់ខ្សោយ អានុភាពវានិងខ្សោយទៅតាមនិងដែរ ចឹងបានខ្ញុំតែតែងបញ្ជាក់ឲ្យ បងប្អូនបដិបត្តិ ព្យាយាម បរិកម្មដង្ហើមទើប ល្អ.។



**យ័ន្តការពារអាវុធ**



**យ័ន្តព្រហ្មវិហារធម៌**



**យ័ន្តឥសីសិទ្ធ១០០គុណ**



**យ័ន្តអធិទេពទាំង៣**



**អថ័ន**

# យ័ន្តសម្រាប់គូសលើកថាពាក់ដៃឬកន្សែងយ័ន្ត





































# យ័ន្តស្តេចវេស្សវ័ណ (ស្តេចយក្ស)



យ័ន្តនេះមានអានុភាពខាងការពារពពួកផ្លូវងងឹតបាន មានអាប ធ្មប់ ខ្មោចព្រាយ។ គួរនិងក្រណាត់ក្រហមឬលឿងឬស និងមានជ័យជោគឈ្នះមារសត្រូវ



យ័ន្តមហាប្រជុំញាតិ



យ័ន្តក្រៃចក្រ សម្រាប់បន្សាបធ្មប់អាប



**យ័ន្តមហាអំណាច**

យ័ន្តនេះប្រើបាន១០០គុណ តែបច្ចុប្បន្ន វានៅអានុភាពត្រឹមតែ៤០%ទេ

# យ័ន្តព្រះព្រហ្ម



សម្រាប់ឱ្យមនុស្សទូទៅស្រលាញ់ចូលចិត្តច្រើន

# យ័ន្តស្នេហ៍លោកិយ



យ័ន្តនេះសម្រាប់ឱ្យមនុស្សប្រុសស្រីស្រលាញ់ចូលចិត្ត សម្រាប់គួរដាក់កន្លែងរកស៊ី



**យ័ន្តនេះមានអានុភាព១០០គុណប្រើបានទូទៅ**

អាចចារលើកថាក៏បាន ចារលើកន្សែងយ័ន្តក៏បានដែរ ជាពិសេសលើស្លឹករុក្ខជាតិមានម្លូជាដើម ក្នុងករណីខ្លះរកស្លឹកម្លូមិនអាចចារលើស្លឹកដទៃទៀតបានដូចគ្នា។

ខ្ញុំបានប្រើយ័ន្តអស់រយៈពេលយូរមកហើយ អានុភាពរបស់វាមិនបាច់និយាយទេនោះបើជាធ្មប់ អាប ក៏ខ្លាចនិងអានុភាពវាដែរ ជួនកាលក៏គេសាកតែលទ្ធផលនោះគឺវេទនាខ្លួនឯង(កំបិតចិតដងឯង) ។ តែយ័ន្តមួយនេះភាគច្រើនគឺខ្ញុំ ចារនិងស្លឹកម្លូដាក់តាមខ្លួនពេលទៅណាមកណាជាប់ជានិច្ច ។

# យ័ន្តព្រះឥន្ទ្រាធិរាជ




យ័ន្តចារដាក់ផ្ទះបានសុខចម្រើន

# យ័ន្តព្រហ្មវិហារធំ



មនុស្សប្រុសស្រីស្រលាញ់រាប់អាន

# យ័ន្តព្រះនរាយណ៍សម្តែងឫទ្ធិ



ផ្កាញ់អាប ធ្មប់

# យ័ន្តនេះប្រើបាន១០០គុណ



# អំពីអត្ថន័យអក្ខរៈយ័ន្ត

អត្ថន័យអក្សរនីមួយៗក្នុងយ័ន្តសុទ្ធតែមានអត្ថន័យរបស់វា៖

១/ព្រះរតនត្រ័យក្នុងពុទ្ធសាសនា៖

**ម អ ឧ**

**អ** = អរហំគឺព្រះពុទ្ធ

**ឧ** = ព្រះធម៌ដ៏ឧត្តម

**ម** = មហាសង្ឃ ។

១/ព្រះរតនត្រ័យព្រហ្មញ្ញសាសនា

**ម អ ឧ**

**អ** = ព្រះសិវៈឬព្រះឥសូ

**ឧ** = ព្រះនរាយណ៍ ឬព្រះវិស្ណុ

**ម** = ព្រះព្រហ្ម

**ឥ ស្វា សុ**

**ឥ** = ឥតិបិសោ ភគវា អរហំ ។ល។

**ស្វា** = ស្វាក្ខាតោ ភគវតា ។ល។

**សុ** = សុបដិបន្នោ ភគវតោ សាវកសង្ឃោ ។ល។

**ចិ ចេ រូ និ**

**ចិ** = ចិត្ត

**ចេ** = ចេតសិក

**រូ** = រូប

**និ** = និព្វាន

# យ័ន្តការពារពពួកខ្មោច



# យ័ន្តនរាយណ៍សម្តេចឫទ្ធិ



# យ័ន្តឥសីចុះភ្នំ



# យ័ន្តព្រះរាមថ្លែងសរ



# យ័ន្តឥសីសម្ដេចឫទ្ធិ



# យ័ន្តហនុមានសម្តេចឬទ្ធិ



# យ័ន្តហនុមានសរទច់ជ័យ



# យ័ន្តហនុមាន



# យ័ន្តរាជសីហ៍ បង្ការធ្មប់ អាប



យ័ន្តនេះសម្រាប់គូរនិងកន្សែងយ័ន្ត សម្រាប់បង្ការធ្មប់ អាប ពពួក វិញ្ញាណខ្មៅ បានសុខសិរីសុខសប្បាយហោង ។

# យ័ន្តមហាលាភ



យ័ន្តនេះសម្រាប់ចារនៅហាងឬកន្លែងលក់ដូរ

# អំពីគាថាការពារគ្រឿងផ្ទះ និងប្រែក្រឡា

**១. ឥស្វាសុ នមោពុទ្ធាយ: ករ: ករុំ ឥអុំ ឆ្វីអ: មអ: ៚**

គាថាបាញ់មិនឆេះ ធ្វើមិនចូល

**២. ឥតបិក: ឥតបិគុំ ចក្វ វីគ្នាំ មអខ្ញ មម: អ: ៚**

គាថាបាញ់មិនឆេះ ធ្វើមិនចូល

**៣. មអខ្ញ ឥអ: ចច: យអ: មឥ មខ្ញ ៚**

គាថា ការពារមីន កាំភ្លើង សីមា

**៤. ពុទ្ធោអតិវ: កកោ ចុក: មចុគុំ ចុកចុក តាន់តាន់ អរហុំ គ្គចចុកអ: ៚**

គាថា បាញ់មិនឆេះ ប្រែក្រឡា

**៥. នមោពុទ្ធាយ: មអខ្ញ អកវ: ចកកស: ឥអ: បិត មអអ:**

គាថា ប្រក់ពល បាញ់មិនឆេះ

**៦. ឥស្វាសុ យមកុំ ឆ្វីផ្វី អ៊ីអ: ចុក កុំ អរហុំ មអអ: ៚**

គាថាបាញ់មិនឆេះ

**៧. ឥតបិ កគវាក្វ ខ្ញឆ្វី ឥក្វ ខ្យខ្ញីអ: នមសត: បុច្ឆ:ក្វីអ:**

គាថា បាញ់មិនឆេះ មីនមិនផ្ទុះ

**៨. ខ្ញម: មហាវទ្វេចសុច គោន: លាក់ក្វ ទ្រុបទ្រូ នមោពុទ្ធាយ: កគវា វទ្វេចសុច ខ្ញស្វូន្យអ:** គាថា បំបាំងកាយ វង្វេងសុង

**៩. ឃុច្ឆា កលកុំ សន្ធឹច បុទ្ធីស្វាហ: ៚** គាថា សម្រាលខ្លួន រត់លឿន

**របៀបប្រើ៖**

គាថាទាំងអស់ខាងលើនេះគឺអាចការពារបានទាំងកាំភ្លើង និង អាចការពារបានទាំងអំពើអំព័ន្ធ មានទាំងគាថាការពារមីនបាញ់មិនឆេះ ហើយនិងប្រែក្រឡាគាថាបាញ់មិនឆេះ ហើយប្រែក្រឡានេះបានន័យថា

នៅពេលដែលមានអាសន្នភ័យកើតឡើងយើង ភាវនានូវព្រះគាថានេះ ហើយប្រសិនបើមាននូវចៃកាច់ខ្លាយតាន់ ហើយបើសិនជាចៃកាច់និងសុទ្ធ ពេលដែលយើងរស់ចូលទៅក្នុងព្រៃ នៅពេលដែលយើងនឹកដល់ព្រះគាថា និងហើយយើងមានចៃពាក់នូវនិង ក យើងយកមកបៀមឧទាហរណ៍ បើយើងមានចង្កូមខ្លាពេលដែលបៀម ទៅគេក្រឡេកមកយើងឃើញយើងចេញជារូបខ្លាបើយើងមានជាចៃដំរីយើង បៀមទៅគេក្រឡេកមកឃើញយើងជាសត្វដំរីតែម្តង អញ្ចឹងគឺវាមានអនុភាពបែបនិងចំណែកឯគាថាបំបាំងកាយវង្វេងសុង

**ឧទាហរណ៍** ពេលយើងរត់យើងសូត្រគាថាព័ទ្ធបន្ទាប់មកយើងរត់ចេញទៅបាត់ហើយ នៅពេលនោះហើយវាស្មានតែយើងពួននៅកន្លែងនិងតាមពិតយើងរត់ចេញបាត់ហើយ ចំណែកឯគាថាមួយទៀតគឺគាថារត់លឿន នៅពេលដែលយើងនឹកឃើញគាថានោះ គឺវាធ្វើឱ្យយើងស្រាលខ្លួនហើយរត់លឿន ។ដូចបានប្រាប់កន្លងមកហើយរាល់គាថាវេទមន្តទាំងអស់ គឺសំខាន់ណាស់នៃការតាំងសមាធិ ហេតុអ្វីបានជាត្រូវតាំងសីលសមាធិ ពីព្រោះអ្វីគាថាមួយៗគឺសុទ្ធតែមានញ្ញាណបារមីរបស់គេគង់ថែរក្សា គឺយើងត្រូវតាំងសីល ១ សីល ៣ សីល ៥ សីល ៧ សីល ទើបវេទមន្តនិងវារត់ចូលក្នុងខ្លួនព្រោះពេលមានអាសន្នយើងគ្មានពេលសូត្រគាថាឯណាទេ អញ្ចឹងហើយបានជាគេឱ្យតាំងសីលសមាធិ ដើម្បីឱ្យវេទមន្តនោះវាជ្រាបចូលនគរកាយនិងដួងកែវរបស់យើង នៅពេលដែលមានអាសន្នគឺគេគ្រាន់តែរំលឹកគុណគ្រូ និង រំលឹកនូវគាថាវេទមួយណាដែលគេប្រើនៅពេលដែលគេនឹកឃើញវេទនោះវានិងចេញប្រតិបត្តិការនោះ គាថានិងវានិងកក្រើកតែម្តងអញ្ចឹងហើយបានជាគេឱ្យតាំងសីល គាថាទាំងអស់ខាងលើនេះគឺប្រើបានទាំងខាងក្បាច់គុណការពារប្រយុទ្ធ និង ការពារអំពើអំព័ន្ធខ្មោចព្រាយបិសាច និង អាចសម្តែងរិទ្ធបានទៀតផង និង មានរិទ្ធតេជៈនិងមាន

អភិនិហារនៅក្នុងខ្លួនហើយក៏ជាសីមាការពារគេធ្វើអំពើ មកលើយើងហើយមានអនុភាពខាងមន្តស្នេហ៍ផងដែរ ។

ភាសាវេទគេសរសេរខុសពីការសម្រាយយើងធម្មតាហើយការអានក៏ខុសគ្នាដែរ យើងចំណាំបាលីវេទគេកម្រចោល ស្រះ ុំ ជើង ង្ហ ហើយនិង រះមុខ ( ះ ) ទាំងអស់នេះជាវិទ្ធបស់វេទ ។

## អំពីគាថាផ្ចាញ់សត្រូវ

១.**ទ្វីទ្វី អាប់ ទសបារមី។** ៧ ឬ៩ចប់ គាថាបង្អាប់មន្តវិជ្ជាគ្រូដទៃ

២.**ពុទ្ធំតារិសោ អកាំរុំ យន្តិ។** ៧ចប់ គាថាបិទយ័ន្តអ្នកដទៃ កុំឱ្យប្រើ

៣.**ពុទ្ធោ អន្ធាក់ សោចាកចក្ខុខ្ញ។**៧ចប់ គាថាបិទភ្នែកគេ

៤.**សគសទើយថី ទូហាទដ្ត ។**៧ចប់ គាថាជួយបើកអាគមគេ

៥.**ខ្ញមហាបើក អញ្ជបើកសីលនរណា ពូកែជាងអញ្ជ ឲ្យរលាយ ខ្ញមនត សូន្យ ។។**៧ចប់ គាថា បិទអាគមគេ

៦.**មោច តរោ ចតុម ខ្ញមហាកំចាយ។** ៩ចប់ គាថាកំចាយសីលគេ

៧.**សខីយ្យៈ អរហំ នមោមោ។** ៧ចប់គាថាបណ្ដេញសីលអ្នកខ្លាំង

៨.**តមោ មហារលត់ ខ្ញមអចេញ្ជផុត។**៧ចប់គាថារំលាយសីលគេ

៩.មេទី១ **ទិទិ សុសុ ។**៧ចប់ គាថាវិលអំពើគេធ្វើមក

៩.មេទី២ **ឱមសាដាន មហាសាដាន សោទិសោសា សោចមិសា។** ៩ចប់

១០. **ឥស្វាសុ ពោធិ ធម្មោ គោន្ធី ត្រឹខឌ មត្រឹខ អមមៈ ស្វាហៈ**
គាថានេះសូត្រ៧ចប់ សម្រាប់គោបា ឬត្រឹងចាប់គោបាធ្មប់

# អំពីគាថាប្រភេទអថ័ន

◎ អរតំ អរត្ន អរត្ន អរត្ន ។ភាវនា ម្តាយអថ័ន
◎ អរហំ អរតិ អរតិ អរតិ ។ភាវនា ឪពុកអថ័ន
◎ ទាសីនេបវិខសអមេង ។ អថ័នតូច
◎ ទាសីនេបវិខសអមេង ងសថវិបិបសង ។ អថ័នធំ
◎ អដ្ឋាន អទ្ធោ នោអកនំ កសថវិបិបសង។ អថ័ន
◎ សវិចា បរិមិសអុំ ងអបាប ចុមម។ ស្តេចអថ័ន
◎ ងត្តំអឆោ ឆោងត្តំង ងត្តំអឆោអ ។ បាញ់មិនចេញ
◎ បតិត្ថ សមន្ថោ អតោន្ទ ។ ជម្ងឺស្នេហ៍
◎ អរហំសុខកត្តោ ព្រះមុនីសោរិអាថាន់ នំទិមំសំអំង អសំ
វិសុលោ បុភាយចប មអង។អថ័នឆ្លងសីមា
◎ វិខុសវនេ វិសា ព្រហ្ម ពិសអនមោទិន អបតិ យបាំង
ចលោម រលាយពីមុខ រលត់ពីក្រោយរលាយម៉ែឪអាថាន់
ជួយ កំចាយគ្រប់មុខផងទាំងឡាយ វិនាសសន្តិ។អថ័នវិល
◎ ឱមផាត់ មហាផាត់ នមោពុទ្ធាយ សុបតិយោ ទើប
អញ្ជើញស្តេចអដ្ឋានចុះមកចាំឆ្អឹងអញ្ញម្ជួនបីដូចដែក មក
ចាំស្បែកអញ្ញម្ជួនបីដូចស្ពាន់ នៅកាលណាមានអាសន្នអន់
ក្រអឺ សូមលោកចុះមកជួយស្ថិតក្នុងខ្លួនខ្ញុំផង សោសោ តិ
តសោ បតិយោ គបតិយោ ។អថ័នការពារខ្លួន

# អំពីគាថាគ្របចក្រវាឡ

ឱមផាត់ មហាផាត់ នមោពុទ្ធាយ សុបតិយោ ទើបអញ្ជើញស្តេចអថ័នចុះមកចាំឆ្អឹងអញមួនបីដូចដែក មកចាំស្បែកអញមួនបីដូចស្ពាន់ នៅកាលណាមានអាសន្នអន់ក្រអឺ

សូមលោកចុះមកជួយសន្និតខ្ញុំផង សោសោ តិតសោ បតិយោ នបតិយោ។១ចប់ឬ៣ចប់

## គាថាអច័នបន្សាបស្នេហ៍

បតិន្ត សមន្នោ រះតោនុ ។៧ចប់

## គាថាចាញ់មិនចេញ

ឧទ្ធំរះធោ ធោឧទ្ធំឧ ឧទ្ធំរះធោរះ។៧ចប់

## គាថាព័ន្ធសីមា

ពុទ្ធំសីមាយំ រះហំ ព្រហ្មា ចសោធាយ ពុទ្ធោ មេនាថោ ធម្មោ មេនាថោ សង្ឃោ មេនាថោ។៧ចប់

## គាថាព័ន្ធសីមា

សីមាខោ រាជ្ជហោ សីមារំ ។៧ចប់

## គាថាព័ន្ធសីមា

ឥមំ សីមាយំ អធិដ្ឋានមិ

ទុតិយម្បិ ឥមំ សីមាយំ អធិដ្ឋានមិ

តតិយម្បិ ឥមំ សីមាយំ អធិដ្ឋានមិ ។៣ចប់

## គាថាព័ន្ធសីមា

អយំភូម បទេសោមិ ។៧ចប់

## គាថាព័ន្ធសីមា

អដ្ឋមតត្តោ មហាថេរោ បីសាចេរ ឥតិទេវា រាជាព្រហ្មា សីមាកំ កំរក្ខរំ។៧ចប់

# គាថាព័ទ្ធសីមា

ឱម្ម: បូព៌ ទិស្សាយ ពេជ ពេជំ ពុទ្ធំ តីង្សំ តីង្សោ នមោពុទ្ធាយ
ឱម្ម: អាគ្នេយ៍ ទិស្សាយ ពេជ ពេជំ ពុទ្ធំ តីង្សំ តីង្សោ នមោពុទ្ធាយ
ឱម្ម: ទក្សិណ ទិស្សាយ ពេជ ពេជំ ពុទ្ធំ តីង្សំ តីង្សោ នមោពុទ្ធាយ
ឱម្ម: និរតី ទិស្សាយ ពេជ ពេជំ ពុទ្ធំ តីង្សំ តីង្សោ នមោពុទ្ធាយ
ឱម្ម: បស្ចឹម ទិស្សាយ ពេជ ពេជំ ពុទ្ធំ តីង្សំ តីង្សោ នមោពុទ្ធាយ
ឱម្ម: ពាយព្យ ទិស្សាយ ពេជ ពេជំ ពុទ្ធំ តីង្សំ តីង្សោ នមោពុទ្ធាយ
ឱម្ម: ឧត្តរ ទិស្សាយ ពេជ ពេជំ ពុទ្ធំ តីង្សំ តីង្សោ នមោពុទ្ធាយ
ឱម្ម: ឥសាន ទិស្សាយ ពេជ ពេជំ ពុទ្ធំ តីង្សំ តីង្សោ នមោពុទ្ធាយ
ឱម្ម: ភូម ទិស្សាយ ពេជ ពេជំ ពុទ្ធំ តីង្សំ តីង្សោ នមោពុទ្ធាយ
ឱម្ម: អាកាស ទិស្សាយ ពេជ ពេជំ ពុទ្ធំ តីង្សំ តីង្សោ នមោពុទ្ធាយ។

# គាថាព័ទ្ធសីមា

ឥតិបិសោភគវា អរហំ ភគវាតិ ស្វាក្ខាតោ ភគវតា ធម្មោ វិញ្ញូហីតិ សុបដិបន្នោ ភគវតោ សាវគសង្ឃោ លោកសាតិ។

# គាថាព័ទ្ធសីមា

ឱម្ម: វិលវង់ វង់ដូចព្រះអាទិត្យ អញ្ចូសែកអោយជិត ដូចសីមាព្រះវិហារ អញ្ចូសែកមន្តវិជ្ជា ដូចមន្តព្រះសិរអាមេត្រី និមន្តគាថាទាំងមួយសែនកោដិចក្រវាឡ ព្រះឥន្ទ ព្រះព្រហ្ម ព័ទ្ធជុំជិត ដូចបន្លាឬស្សីព្រៃ ភ្នំគិរីវង្កតសត្តបរិភណ្ឌ អញ្ចូសែកអោយជាប់ ឱម្ម:ចាក់មហាចាក់ ឱម្ម:ចង មហាចង ទើបគ្រូប្រើអញ្ចូអោយចង នាងរាគីរាគា វិទ្យាគ្រុឌព្យាធរ ផុសចេញមកពីនគរលង្កា ឱម្ម:សីមាកថាវិលឱម្ម:វិលវង់ ពេញទាំងដី សិទ្ធីស្វាហ:។ពាចប់

# គាថាព័ទ្ធសីមា

ពុទ្ធោ សីមានោ នមោពុទ្ធាយ នមអរឧ នមពទ ធម្មោ សីមានោ នមោពុទ្ធាយ នមអរឧ នមពទ សង្ឃោ សីមានោ នមោពុទ្ធាយ នមអរឧ នមពទ។៣ចប់

# គាថាស្រោចទឹកដោះអំពើ

ឱម្ម ព្រះនរាយណ៍ ព្រះពាយផាត់អញ្ជើញមកកំចាត់រោគពាធាព្រះឥសូរស្រោចស្រពព្រះគង្គា គណនាបីដូចទឹកអម្រឹតឫសិទ្ធីជោគដោយព្រះព្រហ្មទោះជាយក្សយមអារក្ស អ្នកតាខ្មោចព្រាយបិសាចមន្តគាថាឆ្មប់អាបអំពើអំពាន់ផងនានា ខ្លបខ្លាចអំណាចព្រះចេស្តាទើបគ្រូប្រើអញប្រោះព្រំប្វាចសាច ទឹកមន្តនៃព្រះគាថាទៅលើរូបកាយបុសស្រីតូចធំ កំលោះក្រមុះក្តីណា បីដូចព្រះអគ្គីក្តៅក្រហល់ក្រហាយរោលរាល រលត់រលាយពីងហោងទើបគ្រូប្រើអញអញ្ជើញក្រុងឆេះ ឆេះទឹក ឆេះដី ឆេះព្រៃប្រឹក្សាឆេះភ្នំបព្វតា ឆេះទាំងអាកាសវេហាស៍ ឆេះទាំងព្រាយក្រឡា ព្រាយហោះព្រាយហើរព្រាយដើរនៅលើដី ព្រាយស្លាប់កូនក្នុងផ្ទៃ ឆេះទាំងព្រាយក្បាល៥ ព្រាយកន្ទោងខៀវ ព្រាយគ្រូម្តាយដើមពោះធំទ្រនំកំរោលពីងរត់ពីងប្បោលចាកចោលចេញទៅកុំបីពីងនៅក្នុងរូបអង្គប្រាណ ឱម្មព្រះពាយផាត់ មហាផាត់ផាយផាត់ទាំងស្នេហ៍មេម៉ាយកំលោះក្រមុំព្រហ្មចារី សាវកែអស់ប្តីផាត់ផាយផាយផាតើកំចាត់រលាយរលត់ចរណៃចេញទៅ កុំឱ្យពីងនៅពុកពីងកំណើតម្តាយបង្កើតពីងខ្លាចបារមីនៃព្រះនរាយណ៍រលាយពីងហោង ឱម្មសិទ្ធី ស្វាហ ស្វាហាយ អឧម ។១ចប់ ស្រោចទឹកអ្នកជម្ងឺដេញអមនុស្ស

# គាថាស្រោចទឹក

ឧមៈមហារាជ មហាឫទ្ធី ទេវៈមហាតេជៈ ភគវាមហាឫទ្ធី មន្តអញសន្ថិតកកើកចក្រវាឡ អញស្រែកអញថ្លែង អញ

សម្តែងមហាព្រះអគ្គី ឆេះទាំងក្រឡាប្រថពី ឆេះទាំងនគរលង្កា ឆេះទាំងព្រៃព្រឹក្សា ខ្មោចព្រាយអារក្សអ្នកតា ឆេះទាំងមេពីងមេគ្រមី ឆេះទាំងព្រាយរកស៊ីយប់ ឆេះទាំងព្រាយរកស៊ីថ្ងៃ ឆេះទាំងព្រាយដើរលើដី និងព្រៃព្រឹក្សា ឆេះទាំងព្រាយល្បាក់សាមហាវិនាស អឧម នមោពុទ្ធាយៈ ប្ញទ្ធីស្វាហៈ។១ចប់

## គាថាស្រោចទឹក

ឧមៈមហិទ្ធិកា មហាព្រះអគ្គីឆាបឆេះវក់វី អដ្ឋទិសា នមោមហាសម្មា ឥសីចក្រវាឡប្ញទ្ធិក្រឡេកឆេះមនោធម្មោវិជ្ជាឥតិភគវា ធម្មាមហាឆេះ នាគៈសិសិជ្ជីវ្ហាប្បារមី គៈកោឥវរី ឥសីប្ញទ្ធី មអឧស្វាហៈ។៣ចប់

## គាថាស្រោចទឹក

ឧមៈសន្តា មហាសន្តា ទើបគ្រូប្រើមន្តចងដៃឆេះបីដូចភ្លើងកាល ឧមៈក្រឡេកឆេះ ឆេះទាំងទឹក ឆេះទាំងដីឆេះទាំងមេព្រាយកម្លាយទាំងក្បាលអាប គំរាបទាំងមេអម្បល់ចុះភ្លូត អង្គុតផ្ទេញចេញអណ្តាតស្រាតសំពត់រត់ចេញទៅ ។៣ចប់

## គាថាស្រោចទឹក

ពុទ្ធំកំចាត់ ធម្មំកំចាយ សង្ឃំរលាយ កំចាយចេញទៅ កុំបីហោងនៅ អន្តរាយខ្លួនហោង គាថាអញរើយ ឆេះទឹក ឆេះដី ឆេះភ្លើង ឆេះភ្នំរលើង ឆេះថ្មរលាយ ឆេះមេធ្មប់ ឆេះមេអាប ឆេះមេព្រាយ ឆេះខ្មោចទាំងឡាយ អន្តរាយចេញទៅ វិនាស្សន្តិ អសេសតោ។៣ចប់

## គាថាស្រោចទឹកដេញបិសាច

ឧមៈ ប្ញទ្ធីតេជៈ ព្រះមុនីឥសី រាជាធម្មា ចក្រី កំចាត់មារលោកិយ ផុងផុយសូន្យនិញ្ញានំ មអឧ សម្មាសីលេន ពន់ពេនប្ញទ្ធីសេពមន្តព្រះអគ្គី ឆាបឆេះវក់វីខ្មោចព្រាយបិសាច ផុងផុយ ឧសូ

ន្យ ឧផាត់ កំចាត់មារ ខ្មោចព្រាយមាយា ធ្មប់អាប មហាមាត់ កំចាត់សូន្យល្បី ខ្មោចផ្លូវអារក្ខអ្នកតា ខ្មោចព្រាយល្បាក់សារ ឆាបឆេះទាំងពីង ពីងពក ពីងហើម ពីងហាល់ ចុកចាប់ ឆេះពីង ពិស ឆេះពីងនូវក្នុងខ្លួនមនុស្ស ផុងផុយរលាយសូន្យអស់ ឆេះទាំង ខ្មោចភូត្ត ដែលដើររកស៊ីយប់ ឆេះទាំងខ្មោចដែលដើររកស៊ីថ្ងៃ ឆេះទាំងមេរំបល់ដែលដើររក ស៊ីយប់ឆេះទាំងមេរំបល់ដែល ដើររកស៊ីថ្ងៃ ឆេះទាំងមេគ្រូមី ឆេះទាំងអាប ឆេះទាំងធ្មប់ ឆេះ សារពើធ្មប់អាបផុងផុយ និព្វានសូន្យ ពុទ្ធ: ធម្ម: សង្ឃ: ព:ល្ងំ សី ល្ងំ ធម្មសច្ចំ ឫទ្ធីស្វាហាយ: ។១ចប់

## គាថាស្រោចទឹកដេញបិសាច

ពុទ្ធំមហាឆេះ ធម្មំមហាឆេះ សង្ឃំមហាឆេះ ន៍ រិទ្ធិ ព្រះអ គ្គីសន្និតក្រឡេកឆេះ ទើបគ្រូប្រើអញអោយសេពក្រុងឆេះ ឆេះ ទាំងក្រឡាប្រថពី ឆេះទាំងគិរីបុព្វតា ឆេះទាំងនគរលង្ការ ឆេះ ទាំងមហារលាយ ខ្មោចព្រាយបិសាច មហារលាយខ្មោច កំណោចមន្តអញឆេះកគ្រើកចក្រវាឡ ឆេះធ្មប់អាប ឆេះទាំង មហាមាត់ទាំងឡាយ វិនាស្សន្តុ អសេសតោ។១ចប់

## គាថាគាស់រូប

ឧម: គាស់ក្វី គាស់ទាំងចម្រឹង គាស់ក្វីសីមាកប្ប ឧគាស់ ម:គាស់ សីមាដែន គាស់អស់ទាំងផែន ធរណីចក្រវាឡ ពុទ្ធំ កគ្រើក ធម្មំរលើក សង្ឃំរលាយ ឆេះទាំងសីមាព្រាយ អារក្ស អ្នកតា ឧឧឪឫទ្ធី ម:យ:សណ្ឋិត សគ្រាមឆាបឆេះ ពុទ្ធោលោ កគ្រើក ច:គ្រាំងរលើក សន្ធោឫទ្ធី ម:ឧព្រះអគ្គី ទេវ:មុន្នី ថ្លែងឫ ទ្ធីឆេះកាល នមោពុទ្ធាយ មអឧ ឫទ្ធី ស្វាហ:។សូត្ររហូតរលើក

**គាថានេះប្រើ១០០គុណ**

ឧម: កំចាត់ ឧម: កំចាយ កំចាត់ទាំងមេព្រាយអាបកំ រាបមេព្រាយធ្មប់ ឧម: កំចាយ មហាកំចាយ កំចាយទាំងមេ ព្រាយ កំចាយទាំងមេអាប កំរាបទាំងមេធ្មប់ ទើបគ្រូប្រើអញ កំចាត់ក្បាលទាំងក យកមកថ្វាយគ្រូអញ ឧម សិទ្ធិស្វាហៈស្លាប់ បន្ទាប់អញជាគ្រូឬាធ្យាយ ចរណៃចេញទៅ ។៣ចប់

**គាថានេះប្រើ១០០គុណ**

ឯហិ ទកសា បិយំមម ឯហិពេជ្ជធាន បិយំមម ឯហិ ពេជ្ជធាន បិយំមម ឯហិពេជ្ជប្រាន បិយំមម ឯពេជ្ជប្រាញ្ញ បិយំម មម៕៣ចប់

**គាថានេះប្រើ១០០គុណ**

ឥតិ អយ: យន្តិ វតី ករេ ។ សូត្រ៧ចប់

នមោពុទ្ធាយ នមអឧ សីលវា ពុទ្ធោៗ ។សូត្រ៧ចប់

**គាថានេះប្រើ១០០គុណ**

នមោ ឥតិ បិសោ ភគវា អរហំ សម្មាសម្ពុទ្ធោ អរហំន្តំ តេជោ សោតា បដិផលាដេជោរិទ្ធី តេជោសិទ្ធី តេជោ ជយ ជយោ សព្វសត្រូវ វិនាសន្តិ អសេសតោ ។៧ចប់

**គាថានេះប្រើ១០០គុណ**

ឧកាស: ឧកាស: ខ្ញុំព្រះករុណាសូមអារាធនាអង្គអក្ខរា អាគមគាថា លេខយ័ន្តនូវព្រះធម៌ព្រះត្រៃបិដក និង ព្រះធម៌ វិបស្សនាកម្មដ្ឋានទាំង ៨ ម៉ឺន ៤ ពាន់ព្រះធម្មខន្ធ ។ សូមព្រះអង្គ យាងមកសណ្ឋិត ឱ្យមូលក្រឡង់ដូចវង់ព្រះអាទិត្យ ព្រះចន្ទ ពេញបរមី សូមរស្មី៦ពណ៌ សូមឈ្នះចិត្តទ្រីស្ត ឫស្យា ទមិឡអ

ន្យតិរិយ៍កន្លងលែងទុក្ខ កន្លងលែងភ័យ អាសន្នអន់ក្រសូមសុខ ប្រសើរដូចដំណើរព្រះអង្គហោង ។៣ចប់

## គាថាដេញចោរ

យដេសិ យដេសិ គឺករណា យដេសិ អហំ បិតំ ជានាមិ ជានាមិ ។ភាវនាពេលដេក

## គាថាធ្វើទឹកមន្ត

ពុទ្ធំ ប្រសិទ្ធី កំ លកំ អ ធម្មំ ប្រសិទ្ធី កំ លកំអ សង្ឃំ ប្រសិទ្ធីកំ លកំអ ។៧ចប់

## គាថាធ្វើទឹកមន្តឱ្យលក់ដាច់

ពុទ្ធំ ពហូចនានំឯហិចិត្តំ ឯហិមនុស្សានំឯហិលាភ្ភំ ឯហិមេត្តា ឈុមភូទីបេ មនុស្សានំ ឥទ្ធយោ បុរិសោ ចិត្តំ ភ័ន្ទធំ ឯហិ។៧ចប់

## គាថាធ្វើទឹកមន្តលុបមុខ

សិរីសួស្តី សិរីគង្គា សិរីពុទ្ធោ នមោពុទ្ធាយ មម រលើប រលោង នៅមុខអញ ឱម្ម: សិទ្ធីស្វាហ:។ ៧ចប់

## គាថាធ្វើទឹកមន្តឱ្យកូនចៅលុបមុខ

ម៉ាហិ ម៉ាសោ ឯហិមម ណាគ្រូអើយ ។៧ចប់

## គាថាឥន្ទនេត្រ

សហាសនេតោ ទេវិន្ទោ ទិព្វចក្ខុ វិសោធ្នាយេ។៧ចប់

គាថាប្រោះក្បាលទ្បាន

នមោពុទ្ធាយ ឥតិបិសោ ភគវា អរហំ លោកវិទូអនុត្តរោ បុរិសទម្មសារថិ សត្ថានំ ពុទ្ធោ ភគវា ចត្តារោមហារាជចត្តារោ ទេវា បត្តស្វាហ ។៧ចប់

## គាថាសែកផ្កា

នរនរា ហិតំទេវំ នរទេវេហិ បូជិតំ នរានំ កាមបង្កេហិ នរា ជិតំ នមាមិហំ។៧ចប់

## គាថាសេពទឹកមុជឬផឹក

អរហំពុទ្ធោ រាដ្ឋសីហោ អរប៉ៃសិ ។៧ចប់

## គាថាហៅភ្ញៀវ

មុនីចិន្តាមហារលួយ ទន់ត្រួយរលួយចិត្ត ទាន់ត្រួយរលួយ ថ្លើមដើមក ទើបអញ្ជូហៅអ្នកផងមករឿយមកឯហិមម នមុនី ចិន្តា មហារលួយ ណោម ភ្លួយ រលួយចិត្ត ស្វាហៈ ។៧ចប់

## គាថាសុំអ្វីមួយ

ឥមំតថា អធិដ្ឋាមិ សិនានកោទកំ យថាអវមង្គលានំ ឥមំ ហោតុ វិសោធយេ កាយេអវ មង្គលានិ សក្កានិមិស្សតានិវា សព្វ នយន្តធាយន្តុ វិគច្ឆន្តុ អសេសតោ ភយូបទ្ទវុប សត្តា អវមង្គល បច្ចយា អន្តរាយាច អរោគា ច អវមង្គល មាហោសុំ សព្វថា ស ត្តេឥមិនា វសិនា យតំ សព្វត្ថ សោត្ថិភាវោ ច ទីឃាយុ តាទិកប្បិ ច សម្មទេវ សមិជ្ឈន្តុ ឥមិនាវសិនាយតំ កិញ្ចិ សិទ្ធិ កម្មសិទ្ធិ វិធិ សិទ្ធិ យត្តសិទ្ធិ ច អារម្មសិទ្ធិយោហោន្តុ ឥមិនាវសិនា យតំ គតោ គតោ អាគច្ឆន្តា បច្ចត្ថិ កានមិទ្ធិយោ មាកត្ថចិ សម្មុស្សីសុ ឥមិនា វសិនាយតំ យេបិតេទុគ្គហទោសា អាកាសតោបិ អាគតា ផុដ្ឋា ប្បាបន្តរធាយន្តុ ឥមិនា វសិនា យតំ សិទ្ធ មន្តុ សិទ្ធ មន្តុ ឥទំ ផល្លំ ឯតស្មឹ រតនត្តយស្មឹ សម្បសាទនចេតសោ ។៣ចប់

## គាថាបន្សាបស្នេហ៍

ឱអសាបំ អឱសាបំ ស្នេហំសាបំ(ឈ្មោះអ្នកត្រូវស្នេហ៍)នមចឱ ឱចអឱ។៧ចប់ គួរលើកថាឱ្យពាក់

## គាថាកុំឱ្យពស់ចឹក

វិរូបក្ខេហិ មេ មេត្តំ មេត្តំ ឯរាបថេហិ មេ ឆព្យាបុត្តេហិ មេ មេត្តំ មេត្តំ កណ្ហាគោតមកេហិ ច ។អបាទកេហិ មេ មេត្តំ មេត្តំ ទ្វិបាទកេហិ មេចតុប្បទេហិ មេ មេត្តំ មេត្តំ ពហុប្បទេហិ មេ ។មា មំ អបាទកោ ហឹសិ មា មំ ហឹសិ ទ្វិបាទកោ មា មំ ចតុប្បទោ ហឹសិ មា មំ ហឹសិ ពហុប្បទោ ។ សព្វេ សត្តា សព្វេ បាណា សព្វេ ភូតា ច កេវលា សព្វេ ភទ្រានិ បស្សន្តុ មា កិញ្ចិ បាបមាគមា ។អប្បមាណោ ពុទ្ធោ អប្បមាណោ ធម្មោអប្បមាណោ សង្ឃោ បមាណាវន្តានិ សរីសបានិ ។អហិ វិច្ឆិកា សតបទី ឧណ្ណនាភិ សរពូ មូសិកាគតា មេ រក្ខា កតំ មេ បរិត្តំ បដិក្កមន្តុ ភូតានិ ។សោហំ នមោ ភគវតោ នមោ សត្តន្នំ សម្មាសម្ពុទ្ធានំ ។ ភាវនាពេលដើរព្រៃ

## គាថាមហារម្ងាប់

ទើបអញផ្តាញ់ទាំងអាសូរី ទើបអញផ្តាញ់ទាំងអាសូរ៉ាធំ ទើបអញផ្តាញ់ទាំងព្រាយនៅលើភ្នំ ទើបអញផ្តាញ់ទាំងព្រា យនៅលើអាកាស នៅចន្លោះមាត់ដណ្តើរ ទើបអញផ្តាញ់ ទាំងព្រាយហោះព្រាយហើរព្រាយដើរលើដីទាំងព្រាយក្បាល៨ ទើបអញផ្តាញ់នៅមាយាកូនខ្ចី ទើបអញចម្លងគ្រោះកាចនៅភូមិលំអិតដៃយ៉ូវ នៅមេរបស់ដារគម្ពីន្ធយស្សា ទើបអ ញផ្តាញ់ទាំងអាសូរីទាំងអាសូរ៉ា ទើបអញផ្តាញ់ទាំងរោគសា មសិបសង អញផ្តាញ់ទាំងពីមុខ អញផ្តាញទាំងពីក្រោយ អញ ផ្តាញ់ទាំងមេព្រាយរលាយចំណងអាប់ផ្ទប់បន្សាបសីល អញខ្ទប់ហោង វិនាសន្តិ អសេសតោ ។១ចប់

## គាថាមហារម្ងាប់

ទើបគ្រូប្រើអញរម្ងាប់អស់ទាំងចង្រៃសារពើ ឬស្សីឈើ គ្រឿងផ្ទះចាស់ថ្មី បែកដើងរលំរលាយទ្រុឌទ្រោមខ្ពស់ទាប វែងខ្លី សសរចង្រៃមានភ្នែកវេចកោង ប ហោងពាំសំបកប ឡាយលុតសន្ធឹងង៍មានពិសចង្រៃ ទើបគ្រូប្រើអញអោយ រម្ងាប់អស់ទាំងចង្រៃ អំពីមេដំបូលចន្លោះបង្កង់

ចុងផ្លានគ្រប់ រនូតរនាបរណាំង ជញ្ជាំងខ្សែទ្វា បង្អួច ខ្ទួចខ្ទាប់ ស្បូវកណ្តាប់ចាប់កាំបិត ។ ទើបគ្រូប្រើអញ្ជរម្ងាប់អស់ទាំងចង្រៃ សព្វ ជនណាៗ សត្វមានជើង៤ ជើង២ គីកុក ខ្វែក ទីទុយ មៀម មុំ ញញី ស្មាប្នា ស្កាសំពោច ទោច ឪឡារ ចូលមកក្នុងស្រុក រត់ចូលគ្រប់ច្រកល្ហកក្នុងភូមិនេះ រម្ងាប់ទាំងអស់ ។ ទើបគ្រូ ប្រើអញ្ជ រម្ងាប់ទាំងបា្មតកំបុតស្មង ត្រូវសាច់ពីងពង ត្រូវ លោងពីងផ្លាយ ។ ទើបគ្រូប្រើអញ្ជប្នាចសាចប្រវាស់ប្រវែង បណ្តោយទទឹង ទើបគ្រូប្រើអញ្ជប្នាចសាចពីមុខពីក្រោយ អោយរលេះរលួយ សព្វ សត្រូវ វិនាសន្តិ អសេសតោ ។១ចប់

## គាថាមហារម្ងាប់

នមោពុទ្ធាយ សិទ្ធិកិច្ចំ ធម្មោ សង្ឃោ ទើបអញ្ជកាន់តេជ អំណាច ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ស្តេចមានជ័យព្រះអង្គ បើកព្រះឱស្ឋមានព្រះបន្ទូលព្រះអង្គប្រើ អញ្ជអោយប្នាចសា ចនៅទិព្វមន្ត អញ្ជប្នាចសាចចេញទៅត្រូវអ្នករលេះរលួយ រំដោះអស់គ្រោះដោគ គ្រោះដាំគ្រោះកាចឧទ្ទបា្មទចង្រៃទាំង ខ្មោចណាៗ ខ្មោច ដាច់សង្វែង ខ្មោចវេច ខ្មោចវែង ខ្មោច តែងតែធ្វើគោរកស៊ីនៅផ្លូវរបង ខ្មោចដែលចម្លងចតុភូតជើង ថ្ក នមោពុទ្ធាយ នមអឧ ឥស្វាសុ សុស្វាត ទើបគ្រូប្រើអញ្ជ អោយប្នាចសាចនៅទិព្វមន្តដ៍ឆើតឆាយ អញ្ជប្នាចសាចចេ ញទៅ ត្រូវក្បាលពីងបែកត្រូវភ្នែកពីងខ្វាក់ ត្រូវជើងពីងបា្មក់ កំបុតត្រឹមស្មង ត្រូវសាចពីងពង ត្រូវលោងពីងផ្លាយ ត្រូវ ដោះពីងខ្វាយបែកទាំងថ្លើម ហើមទាំងប្រម៉ាត់សសៃស្លូត ទើបប្រើឆេះរ៉ា ឱម្មឆេះរ៉ា មហាឆេះរ៉ា ឆេះទាំងសង្ក្រាគូនពីង ឯនាយ ឆេះទាំង ក្បាលខ្មោច ឆេះទាំងក្បាលព្រាយ ន ម អ ឧ សោ ឆេះទាំងដែន ឆេះទាំងឌិន ឆេះទាំងឥន្ទទាំងព្រហ្មទាំង យមបាល ឆេះទាំងព្រះកាល សព្វ សត្រូវ វិនាសន្តិ អសេសតោ ។

## គាថាមហារម្ងាប់

ឥតិបិសោ ហឹងខាព្រះថៅ(ខ)ឧតិត្តូព្រះគាថា ព្រះទិព្វ មន្តឆើតឆាយ ចង្រៃដៃហឹងទាំងពួងទាំងត្បូងកុំបីពីងនៅពីង ចេញតែម្តង ពីងស្រាយ ចំណោង ពីងអោយ ឆាប់ ពីងនៅនិង ស្លាប់ពុំលែងហោង រីមន្តប្រសើរគន្លង អញ្ជបា្មញ់ទៅម្តង ត្រូវ ក្បាលពីងបែក ត្រូវភ្នែកពីងខ្វាក់ ត្រូវជើងពីងបា្មក់

កំបុតត្រឹម ស្មង ត្រូវសាចពីងពង ត្រូវលោងពីងធ្លាយពីងចេញទៅអោយឆាប់ អញ្ជាត្រូបាធ្យាយ ពីងកុំរីងនៅ អញ្ជពត់ដែកមកវៃ ពុំមានអាសូដាច់ខ្នងពោះទ្រូងធ្លាយលោង ឈាមហូរ រដាច់រដោច ឈើចាប់ខ្លោចផ្សារ អញ្ជស្គាល់ពីងឯងហើយ ពីង ឯងមកស្ថិតនៅលើត្បូង ហោរ៉ាពោះខ្នងឆ្អឹងសសៃរោមស្មា គ្រឿសាច់ អញ្ជបាញ់ពីងបាចពីងផ្លាត ទៅពានលើជញ្ជាំង អញ្ជបាញ់ពីងបាំងពីងរត់ចូលដេក អញ្ជបាញ់ពីងម៉ក់ ពីងរត់ចូលមុង អញ្ជបាញ់ពីងពុង ពីងរត់ចូលបុស្សី ពីងរត់គ្រប់ច្រក ល្អកចន្លោះ អញ្ជបាញ់ពីងរស់ ទាំងទ្រព្យរបស់កន្ទេលខ្នល់ ខ្នើយជ្រៀបពូកផែ្ន ព្រំរនាំងវាំងនន់ សំពត់អាវសាប៉ៃចង្អៃ ៗលំពែងដាវ អញ្ជបាញទាំងក្នុង អញ្ជបាញ់ទាំងក្រៅ អញ្ជបាញ់ទាំង ទាណោង រនូតរនាប ជញ្ជាំងទ្វាខ្សែបិទបង្អួចខ្នួចខ្នាច់ អញ្ជបាញ់ពីងបាំងពីងរត់ចូលក្រម៉ា អញ្ជបាញ់ពីងម៉ក់ ពីងរត់ ចូលស្បូវ អញ្ជបាញ់ពីងត្រូវពីងចេញតាមបង្អួច អញ្ជបាញ់ពី ងពួចពីងធ្លាក់ដល់ដី អញ្ជបាញ់ពីងបី ពីងខ្នាត់ទៅរបង អញ្ជ តាមទៅចាប់ អញ្ជតាមទៅចង ពីងរត់ខ្នាត់ខ្នាយ សព្វ សត្រូវ វិនាសន្តិ អសេសតោ ៕១ចប់

## គាថាមហារម្ងាប់

ឱ ម នមោ ពុទ្ធំ ឥតិបិសោ ភគវា អរហំ សម្មាសម្ពុទ្ធោ បារមីតានុភាវេន ទសពលា មហាតេជោ បញ្ច ពុទ្ធា មហាមុ នី សិរសា ពេជ្ជហុនៗ ព្រះពុទ្ធង៍មានបុណ្យ អ្នកអប្បលោក មកខ្ញុំ ទើបអញ្ជរម្ងាប់ទាំងផែនដីយុងយុទ្ធា ទាំងទ្វាទសារាសី រម្ងាប់ទាំងចតុអនុព្ពិសី រម្ងាប់គ្រោះផ្ទៃក្រោមរម្ងាប់ទាំងព្យាម អំពរនគរលង្កា រម្ងាប់ទាំងឆ្នេរសមុទ្រជលសា រម្ងាប់ទាំងឡា មហាប្រឹថពី រម្ងាប់ទាំងគិរីសត្តបរិភណ្ឌ រម្ងាប់ទាំងចក្រវាឡ ទើបគ្រូប្រើអញ្ជ រម្ងាប់ទាំងកុកទំផ្ទះ រន្ទះបាញ់ភូមិ រម្ងាប់ទាំង ព្រាយមាយា រម្ងាប់ទាំងអ្នកធ្វើយោគី នៅអ្នករើសធាតុគាត់ សង្កត់សង្កៀតធ្មេញ វិញព្រះកាំដាំព្រះនេត្រ បាំងស្វេតឆ័ត្រ បិទផ្លូវត្រឡែងកែងខ្វែងខ្សែសិន ព្រោមឃុំទំផ្ទះ ទើបគ្រូប្រើ អញ្ជរម្ងាប់ទាំងអ្នកពុះផ្តុំ ប្រមុំភ្លឺស្រែ ប្រែផ្ទៃក្រោម លើកភូមិ ង៍ជាថ្មី កសាងព្រះរូប ស្តូបចេតិយ ជិកស្រះ ច្រេះដីតបន្ទាយ វាយនូវប្រឹថពី គ្រវីភ្លើងរន្ទើនដំណាប់ ដង្កាប់ញញួរ ទើបគ្រូ ប្រើអញ្ជរម្ងាប់ទាំងដំបូល រលកទំ ឃុំ ពង្រួតទំផ្ទះ ជម្រះរបង រម្ងាប់ទាំងគងស្គរង៍លាន់ព្យងង

ដោយកកើក រម្ងាប់ទាំង អណ្ដើក ត្រសេះ ចូលភូមិលំនៅ រម្ងាប់ទាំងស្វា ឱស្វាគ្រេះ ចូលមកចតសម្រាន រម្ងាប់ទាំងផ្សិតដុះក្បៀរជើងគ្រានពុំសុខ រម្ងាប់ទាំងមាន់ព្រៃ មាន់ស្រុកចូលដល់ត្នាតតាំង រម្ងាប់ទាំង ស្រាំងទាំងឱ ម៉ាល់ចូលទិចរន្ទក រម្ងាប់ទាំងកុកក្រសាទំផ្ទះ ស្មៀរស្រែក រម្ងាប់ទាំងកុក រម្ងាប់ទាំងខ្វែក ទៀវ ទីទុយ មៀមមុំ ចូលមកទំក្នុងលំនៅ ។ សិទ្ធិគិច្ចំ សិទ្ធិកម្មំ សិទ្ធិកំចា ត់ តថាគតោ សិទ្ធិតេជោ សិទ្ធិជយោ និយោនិយំ សិទ្ធីកម្មំ សព្វទុក្ខំ វិនាសន្តិ អសេសតោ ។

ទើបគ្រូប្រើអញ្ជ អោយរម្ងាប់ទាំងឈ្លូះឆ្លកចចកអប្រីយ៍ រម្ងាប់ទាំងសត្វស្រុក រម្ងាប់ទាំងសត្វព្រៃ ទីងទាំងរមាំងរមាស ប្រើសព្រាយ ទន្សាយ ទន្សោង តោ ខ្លាធំ ខ្លាឃ្មុំ រម្ងាម់ទាំង សត្វតូច សត្វធំ នូវសត្វកង្អែន កំប្រុក ឆ្កែស្រុក ឆ្កែព្រៃ ចផ្ងៃ ឡើងមកកើតកូនទុកក្នុងត្រីស្ថាន រម្ងាប់ទាំងពស់វែក ពស់ជា ពស់ក្រាយ ពស់វែកក្ដាំងបាយ ពស់ស្នាទន្សោង កន្ត្រោង ភ្លើងចចើងផ្ទះ ទើបអ្នកមានឈ្មោះ ឈ្នះអស់មារសត្រូវចង្រៃ ទើបគ្រូប្រើអញ្ជ រម្ងាប់ទាំងត្មាតភ្លើង ត្មាតផេះ ត្រសេះ ប្បាក់ ទៀវ ត្រដេវរិុច ហិចហើរមកទំលំនៅឥតក្រែង រម្ងាប់ទាំង រទេះដើរដ៍លាន់ពុពេកក្រៃ រម្ងាប់ទាំងបូសបម កម រមាស់ អុត អាត់ នូវសត្វពង្រូលពស់ព្រៃ រម្ងាប់ទាំងសត្វបក្សាបក្សី ក្ងួច ក្មៀល ចង្មៀលខ្យង ត្រយ៉ង កងកេង តាដក់ រនាល កន្ត្រៃ ឃ្មុំបណ្ដាលអោយហើរមកពន្លឹក រម្ងាប់ទាំងមាន់ទោ មាន់ទឹក ប្រវឹង ប្រវែក ខ្វែកត្រោក ប៉ោលតោក តាវ៉ៅ សត្វ ស្វិតចៅ នូវសត្វកាំប្រម៉ា សេកសារិកាហើរមកក្នុងលំនៅ ទើបគ្រូប្រើអញ្ជ អោយរម្ងាប់ទាំងថ្លាន់ផ្លុងថ្លាន់ភ្លី អក អារអូត ខ្លែងស្រាក ចាកបផ្លាក ដីរក់ដីវាត់ ទាំងសត្វប្រម៉ាកខ្លា តោចរចូលក្នុងត្រីស្ថាន ជាឋានលំនៅយើងនេះ ទើបគ្រូប្រើអញ្ជ រម្ងាប់ទាំងក្រយ៉ៅគោក្របីចង្រៃដ៍ចម្លែក ទើបគ្រូប្រើអញ្ជ រម្ងា ប់ទាំងសព្វជននានាដែលមានចិត្តមិនល្អ រម្ងាប់ទាំងសត្វជើ ងបួនជើងពីគី កុក ខ្វែក ទីទុយ មៀមមុំ ចចក ស្វនស្វា តោ ខ្លែងស្រាក ខ្មោចតូច សំពោច ឆ្មាប្បា លាញ់ពស់ព្រៃចូល មកក្នុងស្រុក រត់រត្រុកក្នុងភូមិ កណ្ដៀរមកពោម ទើបគ្រូប្រើអោយរម្ងាប់រោគាព្យាធិ កុំបីពីងមកយាយី ពីងមកពីទិសទាំង ប្រាំបី ពីងដើរទាំងថ្ងៃ ពីងដើរទាំងយប់ ពីងឈរពីងឈប់ សព្វម្លប់ណាៗ ពីងមក

ម្នាក់ឯង ពីងមកមានគ្នា ទើបអញសូត្រ ដែងនៅព្រះគាថា សភោ មេ ពុទ្ធ ពុទ្ធ វញ្ចា លោកេ តេ ព្រហ្មា តា ហ កេ ក តេមំ សព្វ កម្មំ ប្រសិទ្ធិ មេ ឱម្មារម្ងាប់ មហារម្ងាប់ ទាំងទេ្វបាទ ចតុប្បាទផង រម្ងាប់ទាំងគិរី សត្តបរិភណ្ឌ រន្ទត់ ទាំងភ្នំព្រះសុមេរុ ភ្លូកដំបូករលើងភ្លើងរលត់ អង្គត់រលាយ ខ្មោចព្រាយ របឹងរឹងរូស អោយរលាយជាផេះ ឆេះពាសវាល ពាសកាលង៍រាបបន្ទាក់ ទាំងមេព្រាយហោះបណ្តើរកូន នូវ ខ្មោចព្រាយស្លាប់ប្តី កូនខ្ចីម្តាយដើម ទើបគ្រូប្រើអញផាតទៅ ក្រោមនាយ ផាយទៅក្រោមទឹក ផាត់ទៅក្រោម នាយ ផាយ ទៅក្រោមព្រះធរណី រម្ងាប់ទាំងសារពើ ឫស្សីឈើគ្រឿងផ្ទះ ប្លាក់ដាច់ជើង រលំរលើងទ្រេតទ្រោត ទ្រូងញែកវែងខ្លី សសារ ចង្កៃ មាន ភ្នែករៀចកោង ប្រហោងពាំសំបកប្រឡៃសកសិក ង៍មានពិសខ្លាំងក្រៃ ពុទ្ធំមកជួយកំចាត់កំចាយ ធម្មំមកជួយ កំចាត់កំចាយ សង្ឃំមកជួយកំចា ត់កំចាយ សព្វេ អន្តរាយ វិនាស្សន្តិ អសេសតោ ។

## គាថាកោសម្លី(ស្នេហ៍)

ព្រះសិម្ពលី ច មហាថេរោ ពុទ្ធោ ឯហិ ឯហិ មម មនុស្ស ប្រុសស្រី ផងទាំងឡាយ អោយចូលមករករអញជាគ្រូ តិវត្ត ញ៉ោ អាគច្ឆាយ អាគច្ឆា ហិ មម ។

## គាថាមហារំសាយ

សម្ពុទ្ធេ អដ្ឋវី សញ្ចា នមក្ការានុភាវេន ហន្ត្វា តេសំ នមាមិហំ ៗ៣ចប់

## គាថាសីមាអំបោះ

មអអឱ អឱម ឱមអអ សីមាយំពន្ធនំ អ ៗ១២ចប់

## គាថាចារនិងស្លឹកម្លូ

វីរិហោរខម

## គាថាសីមាភ្លើង

ទ្ធំ អត្តនោឆា ធម្មំ អត្តនោ ឆាសង្ឃំ អត្តនោឆា ឯហិមៈមៈ។

## គាថាការពារ

ពុទ្ធោ កំផែងវាំង ធម្មំកំផែង កែវសង្ឃំ កពោពុទ្ធំ ពេជ្រៗ ពន្ធំ ពេជ្រៗ ពន្ធំ ៗ៧ចប់ អង្កែលដើមទ្រូង

## គាថាចាក់សោរ

ពុទ្ធំ សោសំ ធម្មំ សោច: ច: សោតិ រ: វិតិ ប:ត: និសោច:។

## គាថាស្បែកគង់

ទ: ភ: ផាត់ មោ ភ:វ:ហំ សោតំ ព្រះរាម ម៉ាបិតំ គង់លើកេសាព្រះជព្រះអង្គគង់លើកេសា ឥមស្មឹ កាយេ កេសា លោមា នខា ទន្តា តចោ មំសំ គង់ សរសៃទាំង ៣០ មិតិ គង់កាយ មិតិ គង់កាយ កាយតិ កាយតិ។៧ចប់ ផ្លុំលើខ្លួន

## គាថាហៅយក្សចូលសណ្ឋិតមេទី១

**ឱម: មហាផង្គ គ្រលេកឆេះ ឆាក់ដីគ្រឡាប់ ធរណី ក្រុង មារា រាជា នុំ អហិ មម។** ៧ចប់ ត្រូវសូត្រ៧សីលស្ដេចយក្សឃើញចាំឈប់សូត្រ (រួចសូត្រគាថាឱ្យចំណើខាងក្រោម បើសូត្រ៧ថ្ងៃហើយមិនអាចនិមិត្តឃើញក្រុងយក្សទេ ត្រូវធ្វើពិធីម្ដងទៀត។

## គាថាឱ្យចំណើយក្សមេទី២

**គុច្ឆ: អ: មុំ អហិ មម។**៧ចប់ ត្រូវសូត្រ៧សីល(សរុប១៤សីល)

គាថាស្ដេចយក្សនេះ ចូលប្រើដោយមានសតិ និងមានភាពទទួលខុសត្រូវ ព្រោះថាកាលណាបើយើង បានជោគជ័យជាមួយពីធីហៅស្ដេចយក្សចូលមក សណ្ឋិតក្នុងខ្លួនយើង នៅពេលដែលមាននរណាម្នាក់ គំរាម សម្លុត រករឿងយើង នោះម្ចាស់គាថានឹងចូលសណ្ឋិតក្នុងខ្លួនយើងឯគឯងមិនបាចសូត្រទៀតទេ តែខ្ញុំសូមបញ្ជាក់ម្ដងទៀតមុននឹងរៀន ត្រូវប្រកាន់ខន្តី ហាមផឹកសុរា ។ព្រោះពេលផឹកយើងមិនអាចគ្រប់គ្រង់ខ្លួនឯងបានទេ ណាមួយមនុស្សដែលផឹកជាមួយគ្នា អាចនិងនិយាយរអូតរអាង ឬមើលងាយយើង ពេលនោះយក្សនិង

ចូលសណ្ឋិតភ្លាម ។ កម្លាំងឃើញពេលនោះដូចយក្សចឹង មើលទៅមនុស្សទូទៅដូចស្រមោចចឹង ។មុននិងសិក្សាពិចារណាសិនទៅ រៀនអប់រំចិត្ត រក្សាសីល រក្សាខន្តី ទើបល្អ ព្រោះខ្លាចមានអន្តរាយដល់ខ្លួនរឿងច្បាប់ប្រទេស និងមានគ្រោះថ្នាក់ដល់អ្នកដទៃ ចឹងហើយបានជាខ្ញុំឱ្យបងប្អូនរក្សាខន្តី (ពេលចង់ឱ្យយក្សចូលត្រូវធាក់ដី៣ជើង។

◎បំណាងល្អពី អទិទេព ផ្លូវងងឹត◎

## ប្រភេទគាថាស្ដោះផ្លុំឬព្យាបាលរាងកាយ

គាថាស្ដោះផ្លុំ មានអានុភាពខាងផ្លូវកាយ វាអាចជួយព្យាបាលជំងឺក្នុងកាយយ៉ាងដូចជា៖ ថ្លោះជើង-ដៃ គ្រេចហើម ឬបាក់ឆ្អឹងជាដើម មួយវិញទៀត សម្រាប់ព្យាបាលបាលជម្ងឺប្រភេទអរូបិយ ជាដើម.។ល។

## គាថាតឆ្អឹងឬបាក់ឆ្អឹង

តាណោតាយំ យក្ខណោទុក្ខំ យក្ខខទុត:(ដាច់សសៃ)ទើបត្រូវប្រើអញ(តសសៃ)ឱម្ម:សិទ្ធី ស្វាហាប់ស្ដាប់បន្ដាប់អញជាត្រូបាធ្យាហោង។៧ចប់ បើដាក់ឆ្អឹង សូមសូត្រថា បាក់ឆ្អឹង និងតឆ្អឹង

## គាថាតឆ្អឹងឬបាក់ឆ្អឹង

***យំ នចោមំសំ នលោហូ អដ្ឋិ សហសេត្វា ទត្ថំ ពន្ធនំ សហស្សតិ។*** ៧ចប់ សម្រាប់តឆ្អឹង

## គាថាតឆ្អឹងឬបាក់ឆ្អឹង

ពុទ្ធំតសាច់ ធម្មំតសាច់ សង្ឃំតសាច់

ពុទ្ធំតឆ្អឹង ធម្មំតឆ្អឹង សង្ឃំតឆ្អឹង

ពុទ្ធំតសសៃ ធម្មំតសសៃ សង្ឃំតសសៃ

តទាំងបាក់ជើង តទាំងបាក់ដៃ តទាំងសសៃ ទាំងសាមសិបសង តទាំងព្រះសុរង សិទ្ធីស្វាហៈ។៧ចប់

## គាថាតឆ្អឹងឬបាក់ឆ្អឹង

ឱម្ម: បិទ ឱម្ម:បាំង បិទទ្វារាំង បាំងទ្វារថ្មី ទើបគ្រូប្រើអញ អោយយកពែង សំរិទ្ធ បិទមុខដំបៅ ឱម្ម: សិទ្ធីស្វាហៈ សរសៃ គប់ច្បាក់អោយអណ្ដែតឡើង ៧ចប់

## គាថាតឆ្អឹងឬបាក់ឆ្អឹង

ឥតិបិសោ ភគវាអរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណ សម្បន្នោសុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសា រថិសត្ថា ទេវមនុស្សានំពុទ្ធោភគវាតិ។

ពុទ្ធំកំចាត់ធម្មំកំចាត់សង្ឃំកំចាត់

ពុទ្ធំកំចាយធម្មំកំចាយសង្ឃំកំចាយ

ពុទ្ធំរលាយធម្មំរលាយសង្ឃំរលាយ ឱមសិទ្ធីស្វាហៈ។៧ចប់

## គាថាស្ដោះពិសត្រី។ល។

ឱម្ម:អញស្ដោះសារ៉យអណ្ដែតអញស្ដោះដំបូករលំ ស្ដោះភ្នំរលីងស្ដោះឡើងរលត់អញស្ដោះពិសទៅឱ្យត្រជាក់ដូច ទឹកអម្រិត ឱម្ម:សិទ្ធីស្វាហៈ។៧ចប់

## គាថាស្ដោះពិសត្រី។ល។

ភ៊ឺយអាដែងកំពែងខ្លី ត្រីកីបួនខ្លួនឥតស្រកា ឯងបានមក ពីណា បានមកពីពស់វែក ពស់វែកបានមកពីណា បានមកពី ពស់ថ្លាន់ គ្រូអញតាមទាន់ ឱមសិទ្ធីស្វាហៈ ៧ចប់

## គាថាស្ដោះគ្រិចឬថ្លោះ

ឧកាស បច្ចុក្ខាមិ។ ៧ចប់

## គាថាស្តោះគ្រិចឬថ្លោះ

ឱម: លីដីឯទៅកាប់ដំបូក លូកដីឥដ្ឋ យកមកបិទដំបៅ ញាណពីង ដីងពីណា ពីកូនស្តេចកូនទេវតា ពីតាមហាឥសី ដាច់ស្បែកតស្បែក ដាច់សាច់តសាច់ ដាច់ឆ្អឹង តឆ្អឹង ដាច់ សរសៃតសរសៃ ឱម្ម:សិទ្ធីស្វាហ: ត្រូវស្តាប់បង្គាប់អញជា គ្រូបាធ្យាយ ។៧ចប់

## គាថាស្តោះហើមមិនដឹងមុខឬគ្រិច

ស្វំហ្វំ លោហិតំ អវិសុតុ តរិវេ។៧ចប់

## គាថាស្តោះពិសក្តៅ

ពុទ្ធំកំចាយ ធម្មំកំចាយ កំចាយពិសព្រាយ កំចាយពិស អាវ័ត្ត អន្តរាយខ្លួនហោង មេត្តញ្ចសព្វលោកស្មឹមានសម្ភារយោ អបរិមានំ ឱទ្ធំ អទ្ធោ ចតិរិយញ្ចអសម្ភាធំ ឱមពិសស្លោ ពិស ស្លៅ ពិសក្តៅក្រហាយ វិនាស្សន្តិ អសេសតោ ។៧ចប់

## គាថាស្តោះពិសក្តៅ

នមពទ មពទន ឱមអមិ មហិសុតំ សុនពុទ្ធំ អសុនអ ។៧ចប់

## គាថាស្តោះរើម

ពុទ្ធំ កំចាត់ ធម្មំ កំចាត់ សង្ឃំ កំចាត់ ពុទ្ធំ កំចាយ ធម្មំ កំចាយ សង្ឃំ កំចាយ ពុទ្ធំ រលាយ ធម្មំ រលាយ សង្ឃំ រលាយ ពុទ្ធំ សរណេ សោលំ ធម្មំ សរណេ សោលំ សង្ឃំ សរណេ សោលំ ។

## គាថាផ្លុំរើម

ខ ឝា វ: ត: ។៧ចប់

## គាថាហើមមិនដឹងមូលហេតុ

ពុទ្ធំរាប ធម្មំក្រាប សង្ឃំខ: ក្រាបដូចរនាប រាបដូចកន្ទេល ឱមសិទ្ធីស្វាយ: ស្តាប់បង្គាប់អញជាគ្រូបាធ្យាយហោង។៧ចប់

**គាថាស្តោះរើម**

ឱម្ម: ម ពួន តន ពួន វ៉ន ស្វហ ។ព្ធចប់

**គាថាធ្វើទឹកលាប**

ឱម្ម: នហោតិ ។៧ចប់ ក្លរទឹកទៅស្លាំ

## គាថាគាថនាពេលចូលព្រៃការពារពស់

*ភាវៈជាមិត្ររបស់អាត្មាអញ នឹងត្រកូលស្តេចនាគឈ្មោះវិរូបក្ខៈទាំងឡាយផង ភាវៈជាមិត្ររបស់អាត្មាអញ (ចូរមានជាមួយ) នឹងត្រកូលស្តេចនាគឈ្មោះឯរាបថៈទាំងឡាយផង ភាវៈជាមិត្ររបស់អាត្មាអញនឹងត្រកូលស្តេចនាគឈ្មោះ ឆព្យាបុត្តទាំងឡាយផង ភាវៈជាមិត្ររបស់អាត្មាអញ នឹងត្រកូលស្តេចនាគឈ្មោះកណ្ហាគោតមកៈទាំងឡាយផង ភាវៈជាមិត្ររបស់អាត្មាអញ នឹងសត្វឥតជើងទាំងឡាយផង ភាវៈជាមិត្ររបស់អាត្មាអញនឹងសត្វជើងពីរទាំងឡាយផង ភាវៈជាមិត្ររបស់អាត្មាអញនឹងសត្វជើង ៤ ទាំងឡាយផង ភាវៈជាមិត្ររបស់អាត្មាអញនឹងសត្វជើង សត្វឥតជើងកុំបៀតបៀនអាត្មាអញឡើយ សត្វជើងពីរកុំបៀតបៀនអាត្មាអញឡើយ សត្វជើង ៤ កុំបៀតបៀនអាត្មាអញឡើយ សត្វជើងច្រើនកុំបៀតបៀនអាត្មាអញឡើយ សព្វសត្វទាំងឡាយផង សព្វប្រាណទាំងឡាយផង សព្វភូតទាំងឡាយផង ទាំងអស់គ្នា សូមសព្វសត្វ (ទាំងនោះ) ឃើញនូវសេចក្តីចំរើនទាំងឡាយ សេចក្តីលាមកអាក្រក់តិចតួច កុំមកដល់*

ឡើយ គឺថា កុំកើតមានដល់សត្វទាំងនោះឡើយ។ ព្រះពុទ្ធមានគុណ ប្រមាណមិនបាន ព្រះធម៌មានគុណប្រមាណមិនបាន ព្រះសង្ឃមានគុណប្រមាណមិនបាន សត្វលូន ឬសត្វវារទាំងឡាយ គឺពស់ ខ្ទួយ ក្អែប ពីងពាង តុកកែ និងកណ្ដុរ សុទ្ធតែមានប្រមាណ (មិនច្រើនដូចគុណព្រះរតនត្រ័យ) កិរិយារក្សាអាត្មាអញបានធ្វើហើយ កិរិយាការពារ អាត្មាអញបានធ្វើហើយ ពួកសត្វ (កាច) ទាំងឡាយ ចូរចៀសចេញទៅ អាត្មាអញ (ធ្វើ) នូវនមស្ការ ចំពោះព្រះមានព្រះភាគ នមស្ការចំពោះព្រះសម្មាសម្ពុទ្ធទាំងឡាយ ៧ ព្រះអង្គ។ ខន្ធបរិត្តជាតក

## គាថាដោះចំណង

ភ្លើង គឺរាគៈនោះ រលាកនូវអញផង ចិត្ត ដ៏សម្បយុត្តដោយរាគៈក៏ញ៉ាំងអញឲ្យក្ដៅផង បពិត្រព្រានសំណាញ់ទាំងឡាយ សូមអ្នកទាំងឡាយលែងខ្ញុំទៅ សត្វដែលបិតនៅ ក្នុងកាម អ្នកទាំងឡាយកុំបៀតបៀនក្នុងហេតុនីមួយ ។

## គាថាឃាត់ឈាម

ពុទ្ធំ រាំង ធម្មំ រាំង សង្ឃំ រាំង ពុទ្ធំ បិទ ធម្មំ បាំង បិទថ្នាំង បិទបាំងទំនប់ទឹក ។៧ចប់ ផ្លុំលើមុខរបួស

## គាថាឃាត់ឈាម

នរ ររហំ ។៧ចប់

## គាថាឃាត់ឈាម

ររច ភច ។៧ចប់

**គាថាឃាត់ឈាម**

*ពុទ្ធំ បិ ធម្មំ បិ សង្ឃំ បិ ចសោ ទ្វាយ មអឱ ។៧ចប់*

**គាថាឃាត់ឈាម**

*អាវ: សុ ស: ថុ ស: សិ វិ មំ សិ លោហិតំ វត្តំ ។៣ចប់*

**គាថាឃាត់ឈាម**

*អាវ: សុ សៈតុ សរីអ: មំសំ លោហិតំ។៣ចប់*

**គាថាឃាត់ឈាម**

*អរហំ វិចុ ទុក្ខតោ ស្វាហៈ។ ៧ចប់*

**គាថាឃាត់ឈាម**

*វភោ វរញ្ញូ វរទោ វរាហរោ។ ៧ចប់*

**គាថាឃាត់ឈាម**

*ឱកាស ដោយអំណាចគុណ កតញ្ញូ ចំពោះព្រះមាតាបិតា គ្រូបាធ្យាយ ទានបារមី សីលបារមី មេត្តាបារមី សូមជួយខ្ញុំផង ឱម្មៈចតុលោកបាល សិទ្ធីស្វាហាយ:។៣ចប់*

- *ចំពោះគាថាស្តោះផ្លុំខាងលើ មុននឹងបងប្អូនសូត្រ សូមពិសារម្លូស្លា សូត្រផ្លុំទើបពូកែ .។*
- *ចំពោះគាថាឃាត់ឈាម សូមបងប្អូន ផ្លុំលើកន្លែងហូរឈាម បើ១មេ មិនបាត់ សូមប្តូរ១មេទៀត ។*
- *គាថាទាំងអស់មិនចេះសាបរលាបទេ មានតែអ្នកប្រើគាថាទេដែលសាបរលាបនោះ ចឹងហើយសូមបងប្អូនមេត្តាបដិបត្តិឱ្យបានខ្ពស់ ។ អទិទេពផ្លូវងងឹត*

## នមោពុទ្ធាយ សិទ្ធំ

# អំពីពពួកអមនុស្សឬអទិស្សមានកាយ

- *អៈមៈនុស បា.; សំ ( ន. ) (អមនុស្ស) សត្វអទិស្សមានកាយ មិនមែនមនុស្ស គឺទេវតា, ភូត, បិសាច, ខ្មោច, យក្ស, អសុរកាយ,... (ច្រើនសំដៅភូត, បិសាច, ខ្មោច, អសុរកាយ) : ពួកអមនុស្ស; ព្រៃមានអមនុស្សកាន់កាប់ ។ អមនុស្ស ! ខ្មោច ! (ព. ស្ន. ឬ ព. ម.)។ អមនុស្សធម៌ (--នុស-សៈ--) អំពើឬសន្ដានចិត្តកាចសាហាវឃោរឃៅដូចសត្វតិរច្ឆាន ។*
- *ធ្មប់ ឈ្មោះមន្តអាសិរពិសមួយប្រភេទ ជាគូគ្នានឹងអាប : ស្រូវធ្មប់, មេធ្មប់ (ជាចំណោះអាក្រក់ក្រៃ ហៅថា ទុព្វិជ្ជា ឬ ទុព្វិទ្យា; សំ. ទុរ្វិទ្យា) ។*
- *ព្រាយ ភូត, បិសាចពួកមួយដែលគេច្រើនជឿថាតែងចូលជ្រែកយាយីមនស្សឲ្យឈឺចាប់ ។ ព្រាយហោះ ពន្លឺដែលភ្លឺព្រោងព្រាយរតាយៗ ឬភ្លឺឆ្លោងអាកាសក្នុងវេលាយប់ម្ដងៗ ។ ស្លាប់ព្រាយ ស្លាប់ដោយសម្រាលកូនពុំរួចឬស្លាប់ទាំងកូននៅក្នុងផ្ទៃ ។*
- *អាប ឈ្មោះសិល្បវិទ្យាទុរាចារមួយយ៉ាងរបស់មនុស្សស្រីមានពិធីចងបិសាចឲ្យកាន់កាប់ សម្រាប់ប្រើធ្វើគេឲ្យឈឺចាប់ចុកសៀត: រៀនចាប់អាប ។ អាបប្រពៃណី ខ្មោចអាបដែលគេបោះបង់លែងថែរក្សាទៅហើយ ។ ស្រីពូជអាប ស្រីដែលជាប់ពូជពីស្រីចេះអាបពីមុនៗមក ។ អាបគឺសម្ដៅទៅលើមនុស្សស្រីណាដែលរៀនមន្តគាថា (ឬអាចហៅថាធ្មប់)*

ខ្លាំងរហូតបែកកម្មដ្ឋាន។ អាបចូលចិត្តស៊ីរបស់ណាដែលស្អុយរលួយ ឬឈាមជាដើម។

## ធ្មប់

ឈ្មោះសិល្បវិទ្យាទុរាចារមួយយ៉ាងរបស់មនុស្សស្រី មានពិធីចងបិសាចឲ្យកាន់កាប់ សម្រាប់ប្រើធ្វើគេឲ្យឈឺចាប់ចុកសៀត : រៀនចាប់អាប ។ អាបប្រពៃណី ខ្មោចអាបដែលគេបោះបង់លែងថែរក្សាទៅហើយ ។ ស្រីពូជអាប ស្រីដែលជាប់ពូជពីស្រីចេះអាបពីមុនៗមក ។ អាបគឺសម្តៅទៅលើមនុស្សស្រីណាដែលរៀនមន្តគាថា (ឬអាចហៅថាធ្មប់) ខ្លាំងរហូតបែកកម្មដ្ឋាន។ អាបចូលចិត្តស៊ីរបស់ណាដែលស្អុយរលួយ ឬឈាមជាដើម។

ឈ្មោះសិល្បវិទ្យាទុរាចារមួយយ៉ាងរបស់មនុស្សស្រី មានពិធីចងបិសាចឲ្យកាន់កាប់ សម្រាប់ប្រើធ្វើគេឲ្យឈឺចាប់ចុកសៀត : រៀនចាប់អាប ។ អាបប្រពៃណី ខ្មោចអាបដែលគេបោះបង់លែងថែរក្សាទៅហើយ ។ ស្រីពូជអាប ស្រីដែលជាប់ពូជពីស្រីចេះអាបពីមុនៗមក ។ អាបគឺសម្តៅទៅលើមនុស្សស្រីណាដែលរៀនមន្តគាថា (ឬអាចហៅថាធ្មប់) ខ្លាំងរហូតបែកកម្មដ្ឋាន។ អាបចូលចិត្តស៊ីរបស់ណាដែលស្អុយរលួយ ឬឈាមជាដើម។

វិជ្ជាធ្មប់ត្រូវបានគេប្រើក្រោមហេតុផលធំ ២ គឺ៖

១. គំនុំផ្ទាល់ខ្លួន ឬ មហិច្ឆតារបស់គ្រូធ្មប់

២. មានគេពឹងឱ្យដាក់អំពើធ្មប់ ឬ ដួលគ្រូធ្មប់

**ចាស់បុរាណខ្មែរ លោកខ្លាចញញើតនឹងអំពើធ្មប់នេះណាស់ ជាពិសេស «គ្រូធ្មប់ប្រភេទអ្នកដាក់អំពើ» ព្រោះរាល់អ្នកដែលពាក់ព័ន្ធ ឬ ត្រូវអំពើរបស់គ្រូធ្មប់ណាមួយហើយ បើរកគ្រូណាមួយព្យាបាលមិនត្រូវឈ្មោះអាគមគេដាក់ និង**

ដោះអំពើទាន់ពេលទេ អ្នកនោះនឹងក្ស័យជីវិតយ៉ាងវេទនាជាទីបំផុត ព្រោះវាជាការស្លាប់ដែលលឿន គ្មានដាន និង វេទនាជាទីបំផុត គ្មានថ្នាំទេវតាណាអាចជួយទាន់ឡើយ គឺជាការស្លាប់ដែលមិនអាចគេចបាន មានតែទៅស្វែងរកគ្រូដែលមានមន្តវិជ្ជាខ្លាំងពូកែជាងគ្រូដែលដាក់អំពើយើង ឱ្យគាត់ជួយដោះឱ្យលឿនបំផុតតែប៉ុណ្ណោះ ទើបយើងអាចមានសង្ឃឹមរស់។ ប្រជាជនខ្មែរកាលសម័យបុរាណ គ្រប់គ្នាសែនភ័យបាក់ស្បាតនឹងប្រភេទធ្មប់នេះក្រៃលែង ស្របពេលដែល «ធ្មប់គំរង់» មិនចូលចិត្តធ្វើឱ្យនរណាម្នាក់ស្លាប់ទេ ផ្ទុយទៅវិញមេធ្មប់នេះរៀនវិជ្ជាដាក់ស្នេហ៍ ឬ បំបែកបំបាក់ស្នេហាគេ ហើយចូលចិត្តសាកសពមនុស្សស្លាប់ជាទីបំផុត ជាពិសេសខ្មោចដែលស្អុយរលួយរ៉ល់ចេញខ្លាញ់ និង ដង្កូវ។ រាល់សាកសពដែលស្លាប់តៃហោង គ្រោះថ្នាក់ចរាចរណ៍ ស្លាប់ដោយសត្វសាហាវខាំ ឬ សពអនាថា កប់យូរថ្ងៃហើមប៉ោងស្ដឹង ប្រេះដោរហូរទឹកហើមរលួយណែនដោយដង្កូវក្លិនអាសោចស្អុយប្រហោងជ្រៅសុទ្ធតែខ្ទុះ ដូនតាខ្មែរតែងសម្គាល់មើលនៅពេលកណ្ដាលរាត្រីស្ងាត់យើងនឹងឃើញធ្មប់នេះដើរចេញពីផ្ទះ ជាមួយចបជីក និង កាដុងច្រកទឹកទៅគាស់ផ្នូរខ្មោចនោះ ដើម្បីរីតពូតយកយកខ្ទិះខ្លាញ់សាកសពទាំងនោះច្រកទុកផឹក។

ចាស់ៗដំណាលថា គ្រូធ្មប់ទាំងនោះមានវិជ្ជាងងឹតខ្លាំងរហូតផឹកទឹកគំរង់សពមានរសជាតិផ្អែមដូចទឹកឃ្មុំ និង ឱជារសឆ្ងាញ់ពិសា។ ជាទូទៅធ្មប់ស្អប់សំឡេងក្មេងណាស់ ធ្មប់ខ្លះរះ

ពោះខ្មោចស្រីពោះធំ យកកូនក្នុងផ្ទៃធ្មើរធ្វើកូនក្រក វាជាហេតុផ្ទះគ្រូធ្មប់ ឬ គ្រូអាគម រមែងក្រោយផ្ទះមានដើមឫស្សី ស្ទេកស្កះ ត្រូវបានគេឃើញសង់នៅឆ្ងាយពីតំបន់ដែលមានអ្នកភូមិរស់នៅ ឬ ជាព្រៃដែលគ្មានមនុស្សទៅដល់ គ្មានសូម្បីជានកង់រទេះជិតផ្លូវកាត់ ឬ សំឡេងសត្វយំ រហូតមានពាក្យចាស់បុរាណតែងនិយាយថា ផ្ទះណាគ្មានសំឡេងក្មេងយំ ផ្ទះនោះគេហៅផ្ទះធ្មប់ ហេតុផលមិនមែនគ្រូទាំងនោះស្រឡាញ់ភាពស្ងប់ស្ងាត់ឡើយ តែមូលហេតុនោះគឺ ខ្មែរពីដើមឱ្យតែដឹងថាផ្ទះណាមានគ្រូធ្មប់ ជាពិសេសរាល់គ្រាដឹងថាអ្នកជិតខាងជាប់របងខ្លួនជាគ្រូធ្មប់ ព្រលឹមមិនទាន់ ដូនតាខ្មែរសម័យមុន នឹងរួបរួមគ្នាសាមគ្គី សែងខ្ទម រើផ្ទះ ប្រមូលរបស់របរផ្ទុកគោមាន់ទា និរទេសភៀសកាយនាំកូនពចៅ និយាយពាក្យថាលាហើយលំនៅចាស់ យាត្រាឆ្ពោះទៅទីស្ថានសុវត្ថិភាពដោយមិនចាំបាច់មានអ្នកបង្គាប់ មិនមែនរើសអើងបុព្វហេតុដោយសារជាតិនេះអស់និស្ស័យបន្តរាប់គ្នាជាអ្នកជិតខាងៗ ជាពិសេសចាស់ៗបុរាណលោកជឿថា អ្នកកាន់វិជ្ជាអាបធ្មប់នេះ មិនអាចដាំដុះអ្វីបានផ្លែផ្កាឡើយ សូម្បីតែដើមឈើហូបផ្លែក្នុងបរិវេណផ្ទះគ្រូធ្មប់ទាំងនេះ ក្រៅពីដើមឫស្សីភាគច្រើនគ្មានរស់ ឬ ចេញផ្កាអ្វីឡើយ លោកហាមកូនចៅ មិនត្រូវរាប់គ្នា ឬ ប្រវាស់ដាំដំណាំធ្វើស្រែចម្ការ ដាក់ទុនរកស៊ីដាំដុះ កសិកម្មជាមួយអ្នកចេះវិជ្ជាធ្មប់នេះជាដាច់ខាត

ចឹងហើយបានជាបងប្អូន ត្រូវតែសិក្សាគាថាខ្លះៗដើម្បីការពារ ក្នុងករណីប្រពន្ធឬគ្រួសារមានជម្ងឺរំលែកសូមបងប្អូនយកសីមាចងកដៃកជើងនិងករបស់គាត់រួចសូត្រថា៖
**ពុទ្ធំ ពន្ធំ សោឆាយ ធម្មំ ពន្ធំ សោឆាយ សង្ឃំ ពន្ធំសោឆាយ**
គាថានេះបងប្អូនសូត្រនៅពេលចងរំប្ដោះរួចរាល់ ។

## អាប

អាបគឺជាប្រភេទខ្មោចព្រាយបិសាចមួយប្រភេទ ដែលកើតឡើងចំពោះមនុស្សស្រីដែលរៀនអាគមអំពើស្នេហ៍ឬធ្មប់អាប តែងតែដក់ជាប់នៅក្នុងផ្នត់គំនិតប្រជាជនខ្មែរយើងតាំងពីដើមមក ហើយមិនមែនមានតែខ្មែរនោះទេ នៅតំបន់អាហ្វ្រិកអូស្ត្រាលី ឥណ្ឌាឥណ្ឌូណេស៊ី ម៉ាឡេស៊ី ថៃ ឡាវ វៀតណាម ក៏មានជំនឿលើអំពើអាបធ្មប់នេះដែរ និយាយទៅវាមានឥទ្ធិពលខ្លាំងនៅតាមតំបន់ បុកុលសម្ព័ន្ធណាដែលនៅដាច់ឆ្ងាយពីទីប្រជុំជន ឬវិទ្យាសាស្ត្រ។ បើក្នុងព្រះពុទ្ធសាសនាហៅថា តិច្ឆានអំពើ បុគ្គលទាំងឡាយមិនគួររៀនអំពើទាំងនេះទេ ព្រោះវាជាអំពើអាក្រក់នាំតែសេចក្ដីទុក្ខវេទនាដល់អ្នកដទៃ ហើយនាំអ្នកប្រព្រឹត្តនោះឱ្យធ្លាក់នរកអបាយដោយអំពើរបស់ខ្លួន។
អាបដែលគេតែងតែឃើញនោះជាតួអង្គស្នងអាប។ កាលដើមឡើយរូបអាបអាចរៀនស្នេហ៍មុខ ដល់ពេលរៀនយូរៗទៅសិល្បិ៍ស្នេហ៍នេះចូលជោកគជាំពេញខ្លួនទៅក៏កើតទៅជាអាប។ ព្រលឹងអាបនឹងស្ថិតនៅក្នុងខ្លួនស្ត្រីនោះជានិច្ច ហើយបើសិនជារូបអាបនោះខឹងនរណាម្នាក់ ព្រលឹងអាបនោះនឹងអាចធ្វើឱ្យបុគ្គលនោះឈឺ ឬចុកពោះមិនខាន។ ចាស់និយាយៗថា

ពេលយប់ឡើងមនុស្សដេកលក់អស់រូបអាចនោះតែងតែដកកទៅរកស៊ី ភក់ ផ្សាំ គម្រង់ កូនកង្កែប ដោយហោះប៉ប្រះដីមានភ្លើងភ្លឹបភ្លែត ពេលខ្លះភ្លឺឆ្លោ ហើយបើវាជួបឧសគ្គអ្វីមួយវានឹងពន្លត់ភ្លើងសិន ពេលសភាពការណ៍ប្រក្រតីឡើងវិញវានឹងបើកភ្លើងបន្តដំណើរទៅមុខទៀត។ ពេលខ្លះបើវាដឹងថាមាននរណាម្នាក់សម្រាលកូននោះ វានឹងហោះទៅលិទ្ធឈាម ឬស៊ីសុកមិនខានប្រសិនបើអ្នកសម្រាលកូន ឬគ្រួសារនោះប្រហែស។ អាបខ្លាចដាងគេបន្លាប្ញស្សីនិងបន្លាស្អិត ហើយគេថាប្រសិនបើអាបនោះត្រូវគេចាប់បាននិងដាប់បន្លាស្អិតនោះ តួរូបអាបនោះនឹងស្លាប់មិនខាន។

ត្រឡប់ទៅអតីតកាលកាលពីជាង ២០ ឆ្នាំមុន យប់មួយប្រហែលម៉ោង៣ព្រឹក បងស្រីខ្ញុំគាត់បានចេញទៅក្រៅផ្ទះបត់ជើងតូច ស្រាប់តែគាត់ឃើញភ្លើងខៀវភ្លឹបភ្លែតៗប៉ប្រះដីពីផ្ទះខ្ញុំប្រហែល២០-៣០ម៉ែត្រ គាត់បានឈរមើលភ្លើងនោះដោយងឿងឆ្ងល់ ពេលនោះប្រហែលអាបវាដឹងខ្លួនវាក៏ពន្លត់ភ្លើង ស្រាប់តែបន្តិចក្រោយមកបងខ្ញុំថាឃើញភ្លើងនោះម្ដងទៀតវាហោះសំដៅមកដល់ជិតគាត់ទៅហើយ ឃើញក្រោមភ្លើងនោះមានអីអន្ដេរអន្ដាយប្រហែលជាពោះវៀនអាប តែដោយសារយប់ងងឹតមើលមុខអាបនោះអត់ច្បាស់ ហោះមកជិតដល់សល់ប្រហែល៤-៥ម៉ែត្រ បងស្រីខ្ញុំក៏ដាក់មេប្រូចគ្មានងាកក្រោយទេ ហើយបុកក្បាលនឹងទ្វារពកក្បាលប៉ុនណាណើ។ ការពិតអាបនោះវាចង់មកច្រាស (ខាំ) បងខ្ញុំ ដែលមើលឃើញវា តែដោយសាររបងផ្ទះនោះមានបន្លាអីចឹងហើយទើបវាហោះមកមិនដល់។

បើផ្ទះអីនិងយាយខ្ញុំវិញ យប់ឡើងទុកអីរអស់បានទេ ឬាយ ធ្វើ
ជ្រក់អីទុកតែព្រឹកឡើង ឡើងអន្លាយៗទាល់តែចាក់ចោល មើល
ទៅចាស់ៗថាដោយសារអាបលិទ្ធ។ ការពិតនៅក្នុងភូមិអ្នកខ្លះ
ដឹង ខ្លះក៏មានដឹង មានមនុស្សម្នាក់ដែលជាតួរូបអាប និយាយ
ទៅខ្ញុំដើរកាត់មុខផ្ទះគាត់មិនដែលហ៊ានមើលមុខគាត់ចំពេញ
ភ្នែកទេ។ មុខគាត់ញញឹមពព្រាយ បើមើលទៅប្រហែលគាត់
រៀនស្នេហ៍មុខនោះមែនហើយទើបក្លាយជាអាបដូចគេថាមែ
ន។ រាល់ពេលខ្ញុំដើរកាត់មុខផ្ទះគាត់ បើឃើញគាត់ពីចម្ងាយ
ដេកលើប្ញៅអីរ(គៅអី) ហើយ ខ្ញុំទម្លាក់ភ្នែកមិនហ៊ានមើលមុខ
គាត់ទេ ហើយបើចំពេលយប់ទៀតកាន់តែភ័យ។ តែមកដល់
ពេលរឿងអាបនេះវារាងសាបរលាបច្រើនហើយ តែរំពើធ្លប់
អីនោះនៅតែមានរហូតមកដល់សព្វថ្ងៃ។
អាបនេះ កម្រមានរូបជាមនុស្សប្រុសណាស់ ភាគច្រើនជា
មនុស្សស្រីរៀនមន្តអាគមស្នេហ៍ រហូតដល់មេព្រាយចូល
សណ្ឋិតក្នុងខ្លួនអ្នកប្រើគាថានោះ ។

**តាមករណីខ្លះ៖** យើងមានជំនឿថាអាបនៅពេលដែលវា
ចេញរកស៊ីរមែងតែដកក្បាលចេញពីខ្លួន ដើម្បីរកស៊ី ខ្ញុំសូម
បញ្ជាក់បន្តិចថា នៅម៉ោង៩ឬ១០យប់អាបនោះគឺវាដក់ក្បាល
មកស៊ីមែន តែរំលងដល់ម៉ោង២ឬ៣យប់ជិតភ្លឺ គឺចេញមក
ទាំងរូបរាងតែម្តង សូមបងប្អូនប្រយ័ត្នឱ្យខ្ពស់ ព្រោះថាមិនទាន់
ដាច់ពូជទេ ព្រោះខ្ញុំមានបទពិសោធន៍ ជួបផ្ទាល់ កាលពី ខែ៥ ឆ្នាំ
២០២២នេះ គឺថ្មីៗមែនទែន ចំពោះធ្មប់ ក៏បានប្រទះរួចហើយ
សូម្បីតែវិជ្ជាសំខាន់ដូចជា លាក់ដែកគោលឬម្ជុលក្នុងម្ហូប
អាហារ នៅមានអ្វីច្រើនទៀត ។

នៅខាងលើបងប្អូនអាចសិក្សាគាថាបើកនេត្របាន ដើម្បីមើលពីម្ហូបអាហារ បើមើលទៅមិនទុកចិត្តបុគ្គលដែលឱ្យរបស់យើងបរិភោគ ។

# ព្រាយ

- ព្រាយជាប្រភេទកូនម៉្យាង ដែលមានកំណើតមិនច្បាស់លាស់ទេ តាមដូនតាគាត់និយាយថា កើតពីមនុស្សពោះធំឬសម្រាលកូន ហើយស្លាប់ដោយប្រការណាមួយ
- តាមបទពិសោធន៍ដែលខ្ញុំបានសិក្សា និងបានប្រទះដោយផ្ទាល់ខ្ញុំ បរិយាយដោយសង្ខេប៖
- តាមអ្នកដែលរៀនគាថាជាមួយគ្នាគាត់និយាយថា ព្រាយក៏ចូលចិត្តអាហារដែលស្អុយរលួយដូចអាប នៅពេលដែលមានអ្នកណាម្នាក់ទើបតែសម្រាលកូនរួច គេតែងតែរកបន្លាមកបិទលើទ្វា ឬបង្អួច ដើម្បីការពារពីពពួកអាប ព្រាយ ធ្មប់គំរង
- តាមដែលខ្ញុំបានជួប ខ្ញុំសូមបែងចែកតាមប្រភេទភ្លើងរបស់ព្រាយ៖ ក្រហមនៅកាច បៃតងខ្ចី នៅកាច តែនិយាយគ្នាស្តាប់ ពណ៌លឿងដូចមាស ព្រាយនោះគេ កាន់សីលហើយ តែង បៀតបៀនអ្នកណាហើយ ព្រោះកាលពីថ្ងៃទី១៩ ខែឧសភា ឆ្នាំ ២០២២ ខ្ញុំនិងឃើញភ្លើងនៅទំលើដើមព្រីងមួយដើម ខ្ញុំក៏បាន សួរទៅមិត្តរបស់ខ្ញុំថា តើជាភ្លើងអ្វី លោកឆ្លើយថា ភ្លើងនិងករុណា ឃើញរាល់តែយប់និង គ្រាន់តែស្តាប់ចប់ខ្ញុំក៏បានដើរទៅកន្លែង នោះភ្លាម គ្រាន់តែខ្ញុំទៅដល់ភ្លាមភ្លើងនោះក៏សួរទៅក្នុងដើមព្រីង វិញ ពេលនោះខ្ញុំសួរថា **ណាំងគរុវា សុិនថ: ទ្បៃ មីខាំង ច:ឡូគរុ សុីងថាវា** នេះជាប្រភេទភាសាផ្លូវងងឹតសម្រាប់ចរចារជាមួយ ពពួកវិញ្ញាណ ។ ប្រែជាខ្មែរ ខ្ញុំសូមអញ្ជើញលោកគ្រូមកសួរថា តើ នេះជាប្រភេទអ្វីដែរ ។ នៅពេលដែលខ្ញុំសួរពាក្យនឹងហើយ

ស្រាប់តែលឺសម្លេងចេញពីដើមព្រីង ជាសម្លេងគ្រហឹម ហឹម ហឹម ខ្ញុំក៏បានយកដុំដី រួចបញ្ឆុះអច៌នភ្លើងដើម្បីគប់ តែពេលនោះគ្រូរបស់ខ្ញុំលោកនិយាយថា កុំហៀតហៀនគេអី ។ អទិទេព ផ្លូវងងឹត

យ័ន្តដែលខ្ញុំនិយមប្រើនោះគឺ យ័ន្តរតនត្រ័យ ខ្ញុំសូមណែនាំបងប្អូនឱ្យយ័ន្តប្រភេទនេះដែរ ព្រោះថាខ្ញុំបានប្រើវាជាច្រើនដងហើយ គឺថាប្រសិទ្ធិភាពប្រកបមែន ។

ក្ដីស្រមៃរបស់ខ្ញុំគឺ ចង់មានគោលបំណងពនេចរ កុំគិតរឿងក្នុងលោក ដើរប្រមាញ់អាបធ្មប់ព្រាយដែលឃោរឃៅសាហាវហៀតហៀនមនុស្សលោក ។

ខ្ញុំសរសេរសៀវភៅនេះ គឺចង់បានបងប្អូនឱ្យបានសិក្សាដូចខ្ញុំដែរដើម្បីបានគួរដៃបង្រាប ដើរប្រមាញ់អមនុស្សជាមួយគ្នា និយាយលេងទេ បងប្អូនសិក្សានេះគឺ ទុកការពារគ្រួសារនិងប្រពន្ធកូន ង្កកភូមិល្អជាង ពាក្យមួយដែលខ្ញុំតែងតែនិយាយនោះគឺថា **កើតមកជាប្រុសកុំឱ្យអន់ពេក ។**

**ឧទាហរណ៍៖** បើយប់ឡើងប្រពន្ធឈឺឬគ្រួសារឈឺមិនដឹងពីមូលហេតុ ខ្ញុំចង់សួរថាបងប្អូនជាប្រុសប្រភេទណា ឬបានត្រឹមតែជិះម៉ូតូទៅអញ្ជើញគ្រូដទៃមកមើលទេ ។កុំអន់ពេក

# សិក្សាអ្វីក៏ដោយត្រូវតែបដិបត្តិ

## គាថាការពារចោរ

## យដេសិ យដេសិ កឹករណោ យដេសិ អហំ មិតំ ជានាមិ ជានាមិ។

## គាថារំលឹកគុណព្រះពោធិសត្វ

១.ឥតិបិ ទាន បារមី សម្បន្នោ សោ ភគវា
ឥតិបិ ទាន ឧបបារមី សម្បន្នោ សោ ភគវា
ឥតិបិ ទាន បរមត្ថបារមី សម្បន្នោ សោ ភគវា ។
២.ឥតិបិ សីល បារមី សម្បន្នោ សោ ភគវា
ឥតិបិ សីល ឧបបារមី សម្បន្នោ សោ ភគវា
ឥតិបិ សីល បរមត្ថបារមី សម្បន្នោ សោ ភគវា ។
៣.ឥតិបិ នេក្ខម្ម បារមី សម្បន្នោ សោ ភគវា
ឥតិបិ នេក្ខម្ម ឧបបារមី សម្បន្នោ សោ ភគវា
ឥតិបិ នេក្ខម្ម បរមត្ថបារមី សម្បន្នោ សោ ភគវា ។
៤.ឥតិបិ បញ្ញា បារមី សម្បន្នោ សោ ភគវា
ឥតិបិ បញ្ញា ឧបបារមី សម្បន្នោ សោ ភគវា
ឥតិបិ បញ្ញា បរមត្ថបារមី សម្បន្នោ សោ ភគវា ។
៥.ឥតិបិ វិរិយ បារមី សម្បន្នោ សោ ភគវា
ឥតិបិ វិរិយ ឧបបារមី សម្បន្នោ សោ ភគវា
ឥតិបិ វិរិយ បរមត្ថបារមី សម្បន្នោ សោ ភគវា ។
៦.ឥតិបិ ខន្តី បារមី សម្បន្នោ សោ ភគវា
ឥតិបិ ខន្តី ឧបបារមី សម្បន្នោ សោ ភគវា
ឥតិបិ ខន្តី បរមត្ថបារមី សម្បន្នោ សោ ភគវា ។
៧.ឥតិបិ សច្ច បារមី សម្បន្នោ សោ ភគវា
ឥតិបិ សច្ច ឧបបារមី សម្បន្នោ សោ ភគវា
ឥតិបិ សច្ច បរមត្ថបារមី សម្បន្នោ សោ ភគវា ។

**៨.ឥតិបិ អធិដ្ឋាន បារមី សម្បន្នោ សោ ភគវា**

**ឥតិបិ អធិដ្ឋាន ឧបបារមី សម្បន្នោ សោ ភគវា**

**ឥតិបិ អធិដ្ឋាន បរមត្ថបារមី សម្បន្នោ សោ ភគវា ។**

**៩.ឥតិបិ មេត្តា បារមី សម្បន្នោ សោ ភគវា**

**ឥតិបិ មេត្តា ឧបបារមី សម្បន្នោ សោ ភគវា**

**ឥតិបិ មេត្តា បរមត្ថបារមី សម្បន្នោ សោ ភគវា ។**

**១០.ឥតិបិ ឧបេក្ខា បារមី សម្បន្នោ សោ ភគវា**

**ឥតិបិ ឧបេក្ខា ឧបបារមី សម្បន្នោ សោ ភគវា**

**ឥតិបិ ឧបេក្ខា បរមត្ថបារមី សម្បន្នោ សោ ភគវា តិ ។**

គាថានេះសូត្ររាងរាល់ថ្ងៃពិតជាល្អណាស់ ចម្រើនលាភ ចម្រើនឫទ្ធិតេជះ

## គាថាឱ្យពរ

**ហោតុ សព្វំ សុមង្គលំ**

សុមង្គលគឺសេចក្តីចម្រើន ដ៏ល្អគ្រប់យ៉ាង ចូរមានដល់ខ្ញុំ

**រក្ខន្តុ សព្វទេវតា**

ទេវតាទាំងពួងទាំងឡាយចូររក្សានូវខ្ញុំ

**សព្វពុទ្ធានុភាវេន**

ដោយអានុភាពនៃព្រះពុទ្ធគ្រប់ព្រះអង្គ

**សព្វធម្មានុភាវេន**

ដោយអានុភាពនៃព្រះធម៌ទាំងពួង

**សព្វសង្ឃានុភាវេន**

ដោយអានុភាពនៃព្រះសង្ឃទាំងពួង

**សោត្ថី ហោតុ និរន្តរំ**

សូមសិរីសួស្តីចូរមានដល់ខ្ញុំ ឲ្យបានគ្រប់ពេល កុំបីមានចន្លោះឡើយ ។

# គាថាផ្សាយមេត្តាចិត្ត

គាថានេះត្រូវប្រើមុនគាថាណាៗទាំងអស់តែបើលេងធម៌គ្រដាក់មិនស្តាប់ចាំលេងធម៌ក្តៅ

**សព្វេ បុរត្ថិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ**
**សព្វេ បុរត្ថិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ ។**
**សព្វេ ទក្ខិណាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ**
**សព្វេ ទក្ខិណាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ ។**
**សាប់ពេ បច្ឆិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ**
**សព្វេ បច្ឆិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ ។**
**សព្វេ ឧត្តរាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ**
**សព្វេ ឧត្តរាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ ។**
**សព្វេ ឧបរិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ**
**សព្វេ ហិដ្ឋិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ ។**
**សព្វេ សត្តា អវេរា ហោន្តុ សុខិតា ហោន្តុ និទ្ទុក្ខា ហោន្តុ**
**អព្យាបជ្ឈា ហោន្តុ អនិឃា ហោន្តុ ទិឃាយុកា ហោន្តុ**
**អរោគា ហោន្តុ សម្បត្តីហិ សមិជ្ឈន្តុ សុខី អត្តានំ បរិហរន្តុ**
**ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា សោកប្បត្តា**
**ច និស្សោកា ហោន្តុ សព្វេបិ បាណិនោ ។**

មុនពេលដែលបងប្អូនដោះអំពើឬបណ្តេញខ្មោចព្រាយ បងប្អូនគួរតែផ្សាយមេត្តាចិត្តជាមុនសិនព្រោះថា យើងជាអ្នកគោរពព្រះពុទ្ធសាសនាបឹងគួរតែមានមេត្តាធម៌ចំពោះសព្វសត្វ ។ តែបើនៅតែក្បាលរឹងទេ ចាំលេងធម៌ក្តៅ តែកុំទាន់ប្រើគាថាធំៗ អីព្រោះអាចស្លាប់បាន ។តាមបទពិសោធន៍ខ្ញុំនៅពេលដែលទប់ទល់ជាមួយពពួកធ្មប់ខ្ញុំតែតែងនិយាយ **ខន្តី ខន្តី ខន្តី** ខ្ញុំនិយាយតែ៣មាត់ទេ បើនៅតែរឹងមិនព្រមចេញ ខ្ញុំប្រើគាថាចងទុកហើយ ១អាទិត្យទើបស្រាយវិញ ១។

# គាថាផ្ចាញ់មារ

១) ពាហុំ សហស្សមភិនិម្មិតសា វុធន្តំ គ្រីមេខលំ ឧទិតឃោ រសសេនមារំ ទានាទិ ធម្មិវិធិនា ជិតវា មុនិន្ទោ តន្តេជសា ភវតុ តេ ជយមង្គលានិ ។

២) មារាតិរេកមភិយុជ្ឈិតសព្វរត្តឹ ឃោរម្បនា ឡវក មក្ខមថទ្ធយក្ខំ ខន្តីសុទន្ត វិធិនា ជិតវា មុនិន្ទោ តន្តេជសា ភវតុ តេ ជយមង្គលានិ ។

៣) នាឡាគិរី គជវរំ អតិមត្តភូតំ ទាវគ្គិចក្កមសនីវ សុទារុណន្តំ មេត្តម្ពុសេក វិធិនា ជិតវា មុនិន្ទោ តន្តេជសា ភវតុ តេ ជយមង្គលានិ ។

៤) ឧក្ខិត្តខគ្គ មតិហត្ថសុទារុណន្តំ ធាវន្តិយោ ជនបថង្គុលិមា លវន្តំ ឥទ្ធីភិសង្ខ តមនោ ជិតវា មុនិន្ទោ តន្តេជសា ភវតុ តេ ជយមង្គលានិ ។

៥) កត្វាន កដ្ឋមុទរំ ឥវ គព្ភិនីយា ចិញ្ចាយ ទុដ្ឋវចនំ ជនកាយ មជ្ឈេ សន្តេន សោមវិធិនា ជិតវា មុនិន្ទោ តន្តេជសា ភវតុ តេ ជយមង្គលានិ ។

៦) សច្ចំ វិហាយមតិ សច្ចកវាទកេតុំ វាទាភិរោ បិតមនំ អតិអន្ធ ភូតំ បញ្ញាបទី បជលិតោ ជិតវា មុនិន្ទោ តន្តេជសា ភវតុ តេ ជយមង្គលានិ ។

៧) នន្ទោបនន្ទភុជគំ វិពុធំ មហិទ្ធឹ បុត្តេន ថេរភុជគេន ទមាបយន្តោ ឥទ្ធូបទេស វិធិនា ជិតវា មុនិន្ទោ តន្តេជសា ភវតុ តេ ជយមង្គលានិ ។

៨) ទុគ្គាហទិដ្ឋិ ភុជគេន សុទដ្ឋហត្ថំ ព្រហ្មំ វិសុទ្ធិ ជុតិមិទ្ធិ ពកាភិធានំ ញាណាគទេន  វិធិនា ជិតវា មុនិន្ទោ តន្តេជសា ភវតុ តេ ជយមង្គលានិ ។

៩) ឯតាបិ ពុទ្ធជយមង្គលអដ្ឋគាថា យោ វាចនោ ទិនទិនេ សរតេ មតន្ទី ហិត្វាន នេកវិ  វិធានិ ចុបទ្ទវានិ មោក្ខំ សុខំ អធិគមេយ្យ នរោ សបញ្ញោ ។

## ពុទ្ធជ័យមង្គលរបស់ព្រះពុទ្ធ

# គាថាថ្វាយបង្គំព្រះសារីរិកធាតុ

វន្ទា មិ ចេតិយំ សព្វំ សព្វដ្ឋា នេសុ បតិដ្ឋិតំ សារីរិកធាតុមហាពោធឹ ពុទ្ធរូបំ សកលំ សទា។ ចម្រើនកុសល

# គាថាឱ្យអមនុស្សស្រឡាញ់

**ករណីយមត្ថកុសលេន, យន្តសន្តំ បទំ អភិសមេច្ច សក្កោ ឧជូ ច សុហុជូ ច, សុវចោ ចស្ស មុទុ អនតិមានី ។**

**សន្តុស្សកោ ច សុភរោ ច, អប្បកិច្ចោ ច សល្លហុកវុត្តិ សន្តិន្ទ្រិយោ ច និបកោ ច, អប្បគព្ភោ កុលេស្វននុគិទ្ធោ ។**

**ន ច ខុទ្ទមាចរេ កិញ្ចិ, យេន វិញ្ញូ បរេ ឧបវទេយ្យុំ សុខិនោវ ខេមិនោ ហោន្តុ, សព្វេសត្តា ភវន្តុ សុខិតត្តា នបរោ បរំ និកុព្វេ**

**យេ កេចិ បាណភូតត្ថិ, តសា វា ថាវរា វនវសេសា ទីឃា វា យេវ មហន្តា , មជ្ឈិមា រស្សកា អណុកថូលា ។**

**ទិដ្ឋា វា យេវ អទិដ្ឋា , យេ វ ទូរេ វសន្តិ អវិទូរេ ភូតា វ សម្ភវេសី វ , សព្ពសត្តា ភវន្តុ សុខិតត្តា ។**

**ន បរោ បរំ និកុព្ពេថ, នាតិមញ្ញេថ កត្ថចិ ន កញ្ចិ ព្យារោសនា បដិឃសញ្ញា, នាញ្ញមញ្ញស្ស ទុក្ខមិច្ឆេយ្យ. ។**

**មាតា យថា និយំ បុត្តមាយុសា ឯកបុត្តមនុរក្ខេ ឯវម្បិ សព្វភូតេសុ, មានសំ ភាវយេ អបរិមាណំ ។**

**មេត្តញ្ច សព្ពលោកស្មិ, មានសំ ភាវយេ អបរិមាណំ ឧទ្ធំ អធោ ច តិរិយញ្ច, អសម្ពាធំ អវេរមសបត្តំ ។**

តិដ្ឋំ ចរំ និសិន្នោ វ, សយានោ យាវតាស្ស វិតមិទ្ធោ ឯតំ សតឹ អធិដ្ឋេយ្យ, ព្រហ្មមេតំ វិហារមិធមាហុ ។

ទិដ្ឋិញ្ច អនុបគ្គម្ម, សីលវា ទស្សនេន សម្បន្នោ កាមេសុ វិនយ គេធំ, ន ហិ ជាតុគ្គព្ភសេយ្យ បុន រេតីតិ។

## គាថាហាមឃាត់អមនុស្ស

យស្សានុភាវតោ យក្ខា នេវ ទស្សេន្តិ ភីសនំ យម្ហិ ចេវានុ យុញ្ជន្តោ រត្តិន្ទិវម តន្ទិតោ សុខំ សុបតិ សុត្តោ ច បាបំ កិញ្ចិ ន បស្សតិ ឯវមាទិគុណូបេតំ បរិត្តន្តម្ភណាម ហេ។

## គាថាជយបរិត្ត

ជយន្តោ ពោធិយា មូលេ សក្យានំ នន្ទិវឌ្ឍនោ ឯវំ ត្វំ វិជយោ ហោហិ ជយស្សុ ជយស្សុ ជយមង្គលេ  អបរាជិតបល្លង្កេ សីសេ បឋវិបោក្ខរេ អភិសេកេ សព្វពុទ្ធានំ អគ្គប្បត្តោ បមោទតិ សុនក្ខត្តំ សុមង្គលំ សុបភាតំ សុហុដ្ឋិតំ សុខណោ សុមុហុត្តោ ច សុយិដ្ឋំ ព្រហ្មចារិសុ បទក្ខិណំ កាយកម្មំ វាចាកម្មំ បទក្ខិណំ បទក្ខិណំ មនោកម្មំ បណីធី តេ បទក្ខិណា បទក្ខិណានិ កត្វាន លភត្តត្ថេ បទក្ខិណេ។ ចម្រើនជ័យមង្គល

## គាថាផ្សាយកុសល

យេកេចិ ខុទ្ទកា បាណា មហន្តាបិ មយា ហតា យេ បាណេកេ បមាទេន កាយវាចា មនេហិវា បុញ្ញំ មេ អនុមោទន្តុ គណ្ហន្តុ ផលមុត្តមំ វេរិនោ ចា បមុញ្ចន្តុ សព្វទោសំ ខមន្តុ មេ ។ សូត្រពេលធ្វើពិធីអ្វីមួយចប់

# ឯកសារស្រាវជ្រាវ

- វចនានុក្រម សម្តេចព្រះសង្ឃរាជ ជួន ណាត
- ប្រភព ពីគម្ពីសាស្ត្រាបុរាណ
- ប្រភព ពីអ្នកសង្ខំ
- ប្រភព ពី YOUTUBE – FACEBOOK
- ប្រភព ពី វិគីភីឌា
- ប្រភព ពី ភីនធ័ររេស្ត
- ប្រភព ដទៃទៀត

## បញ្ចប់សៀវភៅ

ខ្ញុំសង្ឃឹមថាសៀវភៅ១ក្បាលនេះ និងជួយសម្រួលដល់បងប្អូនដែលមានគោលបំណងចង់សិក្សាពី មន្តអាគមខ្មែរ បានងាយស្រួល និងជោគជ័យ។

ខ្ញុំគ្មានអ្វីដែលអាចជួយដល់បងប្អូនក្រៅពីសរសេរគម្ពី១ក្បាលនេះទេ

ហើយខ្ញុំក៏សង្ឃឹមថាបងប្អូននឹងអានពីរបៀបដែលខ្ញុំបានសរសេរក្នុងសៀវភៅនេះ ចូរបងប្អូនក្នុងប្រញាប់សិក្សាគាថាធំៗពេកបងប្អូន បងប្អូនត្រូវសិក្សាតាមលំដាប់ដែលខ្ញុំបានសរសេរព្រោះថាវាជាបទពិសោធន៍ដែលខ្ញុំបានសិក្សា មកក៏ចឹងដែរ ខ្ញុំមិនចង់ឃើញបងប្អូនដែលជាវសៀវភោនេះទៅហើយ មិនបានផលនោះទេ

ខ្ញុំសូមអភ័យទោសចំពោះអក្ខរាវិរុទ្ធផង បើមានត្រង់ណាឆ្វេសប្រហែស ក្នុងការសរសេរ សមដូចពាក្យមួយគេ ដំរីជើងគងតែភ្លាត់ អ្នកប្រាជ្ញចេះស្ទាត់គង់តែមានភ្លេច ចំណែកខ្ញុំវិញមិនមែនដំរីឬអ្នកប្រាជ្ញអ្វីទេចឹងការខុសឆ្គងគង់តែមាន.។

## សូមជួយថែរក្សាផង

## សិក្សាហើយយកទុកឱ្យខ្ពស់កុំឱ្យអ្នកដទៃឬខ្លួនដើររំលង

តម្រាវិញ្ញាណទី៦



# ឱម្ហា ឱម្ហា
# រក្សាវប្បធម៌ខ្មែរបុរាណ

ចិរញ្ញាណោ រុន វ៉ាណា